# ព្រលឹងនាយរោង

គង្គ ប៊ុនឈឿន



គង្គ ប៊ុនឈឿន

សូមជូនរឿង

# ព្រលឹងនាយអោង

ប្រលោមលោកបែបចិត្តវិទ្យា មនោសញ្ចេតនា

អាថ៌កំបាំង អរូបិយ)

រំលឹកពីវិញ្ញាណខ្លួននាង ពិសិដ្ឋ ពាលីកា

013559

ក្រោយពេលស្លាប់

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.

ការផ្សាយរបស់

បណ្ណាល័យ ឆព្វណ្ណរង្សី

2004

រក្សាសិទ្ធិគ្រប់បែបយ៉ាង

ចេញផ្សាយឆ្នាំ ២០០៦

# អារម្ភកថា

**កាល**ពីឆ្នាំ ១៩៩៤ ខ្ញុំបានថតខ្សែវីដេអូរឿងព្រេងបូរាណប្រឌិតមួយរឿង ឈ្មោះថា "**បុប្ផាពស់វែក**" ដែលជាភាគបន្តពីរឿង "**ឥន្ទ្រីកុមារ**" ។

រឿងនេះ ខ្ញុំបានតម្រូវឱ្យនាង ពិសិដ្ឋ ពាលីកា ដើរជាតួនាងបុប្ផាពស់វែក រួមជាមួយតួប្រុសស្រីសំខាន់ៗឯទៀតជាច្រើន ។ ប៉ុន្តែ ខៃ ប្រសិទ្ធិ ដែលកាលក្នុងរឿង "ឥន្ទ្រីកុមារ" ដើរជាតួរាហ៊ូ ដល់មកក្នុងរឿង "បុប្ផាពស់វែក" មិនបានដើរជាតួនេះទៀតឡើយ ខ្ញុំបានប្ដូរដាក់ ទេព រិទ្ធដារ៉ូ ជំនួសវិញ ដោយសារ ខៃ ប្រសិទ្ធិ ជាប់រវល់ត្រូវទៅសំដែងសិល្បៈនៅប្រទេសអូស្ត្រាលី ។

ជួនជា នៅពេលដែលថតចប់ រឿងនេះមិនបានដាក់បញ្ចាំងជាសាធារណៈនៅរោងទេ ដោយសារពេលនោះ សិល្បៈភាពយន្តវីដេអូខ្មែរបានធ្លាក់ចុះយ៉ាងខ្លាំង បន្ទាប់ពីមានការលើកទឹកចិត្តឱ្យខ្សែវីដេអូបរទេសហូរចូលពេញទឹកពេញដី ។

ខ្ញុំបង្ខំចិត្តទុករឿងនោះរហូត ក្រោយពីបានសាកល្បងទាក់ទងលក់ឱ្យស្ថានីយ៍ទូរទស្សន៍ជាច្រើន តែគេមិនទិញ ព្រោះគេមើលងាយសិល្បៈខ្មែរ ថាមិនដល់បរទេស ។

ដល់ឆ្នាំ ១៩៩៨ ដោយនឹកស្ដាយទឹកដមសិល្បៈដែលបញ្ចូលទៅក្នុងស្នាដៃនោះ ខ្ញុំក៏សំរេចយកទៅផ្ញើទុកឱ្យស្ថានីយ៍ទូរទស្សន៍មួយ ទោះជាគេចង់បញ្ចាំងពេលណាក៏តាមចុះ ប៉ុន្តែរហូតដល់ឆ្នាំ ១៩៩៩ ក៏ស្ថានីយ៍ទូរទស្សន៍នោះនៅតែរកឱកាសល្អនឹងបញ្ចាំងរឿងនេះមិនបានដែរ ។

ស្រាប់តែដល់ថ្ងៃទី ៦ ខែកក្កដាឆ្នាំដដែល នាងពិសិដ្ឋ ពាលីកា

ដែលជាតួនាងបុប្ផាពស់វែក ក្នុងខ្សែវីដេអូរបស់ខ្ញុំបានត្រូវគេធ្វើឃាតដោយការបាញ់ប្រហារយ៉ាងមហារន្ធត់ ។

ក្រោយពីនាងស្លាប់ផុត មានអ្នកខ្លះមកឱ្យប្រាប់ខ្ញុំថា គួរតែរកមធ្យោបាយបញ្ចាំងរឿង "**បុប្ផាពស់វែក**" នោះឡើង ប្រហែលជាមានផ្លូវ ? ។ មុនដំបូងខ្ញុំគិតឃើញយ៉ាងនេះដែរ ប៉ុន្តែក្រោយមកក៏លះបង់គំនិតនេះចោលវិញ គឺមិនគប្បីឆ្លៀតធ្វើអាជីវកម្មទៅលើព្រលឹងវិញ្ញាណរបស់សិល្បការិនី ដែលត្រូវគេលបពិឃាតយ៉ាងអយុត្តិធម៌បែបនេះទេ...

ទោះបីព្រឹត្តិការណ៍សោកនាដកម្មដ៏រញ្ជួយចិត្តនេះ កន្លងទៅច្រើនឆ្នាំហើយក្តី ក៏ព្រលឹងរបស់តារាឯកភាពយន្តវីដេអូខ្មែររបស់សាស្ត្រាចារ្យរបាំ និងរបស់នាយរោងប្រចាំក្រុមរបាំបូរាណ នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈរូបនេះ នៅតែឋិតក្នុងអារម្មណ៍ប្រជាពលរដ្ឋខ្មែរជាប់ជានិច្ច ហើយក៏ឋិតនៅជារឿងរហូតក្នុងកម្មវត្ថុនៃការនិពន្ធរបស់ខ្ញុំ ។

អ្វីៗហាក់ដូចជាមិនទាន់ហួសពេលទេ ព្រោះមានពេលមួយនោះ ក្រោយពីខ្ញុំបានយកវីដេអូរឿង "បុប្ផាពស់វែក" មកចាក់បញ្ចាំងមើលឡើងវិញ ហើយក្នុងយប់នោះ ខ្ញុំក៏យល់សប្តិឃើញដូចជាព្រលឹងរបស់នាងពិសិដ្ឋ ពាលីកា ស្លៀកពាក់ជាតួនាង "បុប្ផាពស់វែក" មកឈរនិយាយដោយក្រៀមក្រំនៅក្បែរតុសរសេររបស់ខ្ញុំថា «ប្រហែលជាដោយសារតែចុងបញ្ចប់នៃរឿង "បុប្ផាពស់វែក" លោកអ៊ំបានឱ្យបងដារ៉ូ ចាប់លើកខ្ញុំបោះទម្លាក់ទៅក្នុងរណ្តៅភ្លើងទេដឹង ទើបបានខ្ញុំត្រូវគេបាញ់សម្លាប់ដោយគ្មានអាណិតអាសូររបៀបនេះ ?...» ។

នៅមានរឿងហេតុជាច្រើនទៀត ដែលខ្ញុំបានជួបជាមួយព្រលឹង

នាយរោង ពាលិកា នៅក្នុងយល់សប្តិ រហូតដល់ពេលដែលខ្ញុំត្រូវឃ្លាតពីមាតុភូមិទៅឆ្ងាយទៀត ក៏ខ្ញុំនៅតែជួបព្រលឹងនាងមិនដែលដាច់ដែរ ។

អ្វីៗដែលមាននៅក្នុងសៀវភៅនេះ គឺជាការចងក្រងនូវខ្សែរឿងនិងចំរៀងក្នុងសុបិន ដែលខ្ញុំបានឮព្រលឹងនាងពាលិកា ស្រែកច្រៀងដង្ហោយមកកាន់ប្រជាជនខ្មែរថា នាងពិតជាសោកស្តាយខ្លាំងណាស់ចំពោះឃាតករដែលបាញ់ប្រហាររូបនាង តើគេបាញ់ប្រហារនាងដើម្បីផលប្រយោជន៍អ្វី ? ។ តាមពិត គេអាចសំលាប់នាងតែរាងកាយដែលជាសភាវៈអនត្តារបស់នាងប៉ុណ្ណោះ ឯព្រលឹងពេញដោយតម្លៃវប្បធម៌របស់នាង គេពិតជាមិនអាចសំលាប់បានឡើយ វានឹងរស់នៅជាអមតៈក្នុងខួរក្បាលមនុស្សដែលបរិបូរណ៍ដោយមនសិការៈ សច្ចៈ យុត្តិធម៌ និងគុណធម៌សន្តោសប្រណី ។ ហើយពួកឃាតករព្រៃផ្សៃទាំងនោះ គង់តែទទួលផលជាក់ស្តែងទៅតាមអំពើដែលគេបានធ្វើក្នុងថ្ងៃណាមួយ តាមទម្ងន់កម្មផលនៃឈាមស្រែកស្បែកហៅ ជៀសមិនរួចឡើយ ព្រោះមនុស្សល្អមិនដែលបន្ទំខ្លួនធ្វើអាក្រក់ទេ មានតែពួកមនុស្សអាក្រក់ទេដែលបន្ទំខ្លួនខំធ្វើល្អ ដើម្បីបំភ័ន្តភ្នែកតុលាការរាល់ថ្ងៃនោះ ! ។

ក្រុងបាងកក, ថ្ងៃ ០១ វិច្ឆិកា ២០០៣

**គន្ធ ប៊ុនឈឿន**

# ១

## ប្រផ្នូលអាថ៌កំបាំង

ថ្ងៃមួយ នៅឆ្នាំ ១៩៩៤ ក្រុមថតវីដេអូរបស់ខ្ញុំដែលមានឈ្មោះថា ផលិតកម្ម **ឆពណ្ណរង្សីភាពយន្ត** បានប្រមូលអ្នកធ្វើការ អ្នកបច្ចេកទេសផ្សេងៗ និងតួសំដែង សំដៅទៅទទួលនាងពិសិដ្ឋ ពាលីកា ចុងក្រោយគេ ដែលកាលណោះផ្ទះនាងនៅម្តុំក្បែរបរិវេណរដ្ឋសភាជាតិ ។

គោលបំណងរបស់ខ្ញុំ គឺក្រោយពីទទួលនាង ពិសិដ្ឋពាលីកា ហើយនឹងចេញដំណើរទាំងព្រលឹម ឆ្ពោះទៅរមណីដ្ឋានភ្នំបាសិដ្ឋតែម្តង ដើម្បីថតបញ្ចប់រឿង "**ទុង្គពស់វែក**" បន្ទាប់ពីបានផ្អាកពុះពារថតមកអស់រយៈជាច្រើនខែ ។

ខ្ញុំនៅចាំបានថា កាលណោះនាង ពិសិដ្ឋពាលីកា មិនមែនចេញមករកឡានដែលចតចាំនៅមាត់ច្រកផ្លូវតែម្នាក់ឯងទេ គឺមាន ខៃប្រសិទ្ធ ប្តីនាងជូនដំណើរ ជួយកាន់ប្រអប់ម៉ាកគីយ៉េរមកជាមួយដែរ ។

ដោយខានឃើញបុរសនេះជាយូរ ខ្ញុំក៏លាន់មាត់តាំងពីចម្ងាយថា ÷

-« អ្ហែ៎... សិទ្ធថ្ងៃនេះ ទៅលេងជាមួយពាលីដែរមែនទេ ?..»

ខៃប្រសិទ្ធ ក៏ឆ្លើយដោយញញឹមខ្លួចថ្ពាល់ម្ខាង តាមទម្លាប់ដែលគេធ្លាប់និយាយមករកខ្ញុំជាយូរមកហើយ នៅពេលដែលជូនប្រពន្ធមកឈរ

ប្របមាត់ទ្វារឡានប្រុងឡើង ÷

-«ខ្ញុំប្រុងឱ្យប៉ាអ៊ីនាំគ្នាទៅមុនដែរ ហើយខ្ញុំបើកឡានជូនអាកាទៅតាមក្រោយ ព្រោះឮថាថ្ងៃនេះ ប៉ាអ៊ីថតបញ្ចប់រឿង បុប្ផាពស់វែក មានឆាកបង្ស៊ូ ចាប់លើកអាកាបោះទៅក្នុងរណ្ដៅភ្នក់ភ្លើង ខ្ញុំចង់ទៅមើលដែរ តែ,,, ទាស់ជាប់រវល់បន្តិច,,,,! »

ពិសិដ្ឋពាលីកា ក៏ឆ្លើយបន្ទរប្រយោគរបស់ប្ដី ដោយខ្សែនេត្រាដ៏ស្រទន់មានស្នេហ៍ ÷

-«ពីល្ងាច បងគាត់គ្រោងថាយ៉ាងនេះឯង ប៉ុន្តែដល់យប់ជ្រៅបន្តិច មានគេទូរស័ព្ទមកប្រាប់ថា គាត់ត្រូវជាប់ទៅបំពេញទំរង់បែបបទត្រៀមចេញទៅសំដែងនៅក្រៅទៀត បានជាខកខានទៅវិញ !,,,»

ប្រពន្ធខ្ញុំ ដែលអង្គុយក្បែរខ្ញុំដែរ ក៏ឆ្លើយស្នងដោយនិស្ស័យរាប់អាន ÷

-«ព្រោះតែកូនសិទ្ធ គេជាប់រវល់ចេញទៅសំដែងនៅក្រៅប្រទេសញឹកញាប់បែបនេះហើយ បានជាតួរាហ៊ូ ឪរាគេប្ដូរឱ្យមកដើរជំនួសវិញ បើនឹងរង់ចាំកូនក្រៅខោឯង ខ្វាចខកណាំ !,,,»

-«អ៊ូ,,, ល្អណាស់ម៉ាក់ !,,,» ខែប្រសិទ្ធឆ្លើយតបវិញ ដោយញាក់កន្ទុយភ្នែកទៅកាន់ទេពវិន្ទដារ៉ូ ដែលអង្គុយមិនឆ្ងាយពីខ្ញុំប៉ុន្មាន «,,,បានបង្ស៊ូដើរជាតួនេះ កាន់តែប្រសើរជាងខ្ញុំ ដូចបានកុយពុកអញ្ចឹង ! ចាំបាច់រង់ចាំខ្ញុំ,,, ធ្វើអី ?,,,»

តារាកំលោះចាស់ប្រជ្រុយស្នេហ៍ ញញឹមទទួលកន្ទុយភ្នែក ខែប្រសិទ្ធ ហើយឆ្លើយទៅវិញពីរបីម៉ាត់ ក្រោយពីងាកមកសម្លឹងតួឯកស្រី

ដែលប្រុងឈានជើងឡើងឡានថា ÷

-«ខ្ញុំឆ្ងល់ពាលី បណ្តោយឱ្យសិទ្ធទៅរកស៊ីនៅស្រុកឆ្ងាយៗពេកអីចឹង មិនខ្លាចដូចសត្វចាបជៀបកប្បាសពេញ្ញាលក្នុងរឿងសព្វសិទ្ធិទេអ្ហ៎ !... ត្រូវផ្កាឈូកក្តោបក្នុងស្រទាប់ជាប់ពេញមួយយប់ណាំ ទាល់តែព្រឹកឡើងទើបរើខ្លួនរួច ?...»

ពិសិដ្ឋពាលីកា ដែលអ្នកផងតែងស្គាល់ថែមទៀត ថាជាតួនាយរោងដ៏ល្អឆើតប្រចាំក្រុមរបាំបូរាណនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈញញឹមសែនស្រស់ ហើយរលាស់សក់រំសាយខ្មៅរលើប និងបង្អើរវាចាមកវិញយ៉ាងប្លែមត្រជាក់ ÷

-«មុនដំបូងខ្ញុំបារម្ភខ្លះដែរ បង៉ូ តែក្រោយពីជញ្ជីងគិតយូរទៅ ក៏នឹងនរក្នុងចិត្ត ព្រោះទោះបីយ៉ាងណាក៏ជៀបកប្បាសថ្កាល់ខ្លួចនេះ មិនបណ្តោយឱ្យផ្កាឈូកឯនាយសមុទ្រ ក្តោបទុកចោលប្រពន្ធកូននៅទីនេះដែរ !...»

នាង សុខស្រីមុំ ដែលអង្គុយនៅក្បែរ យុត្តាភាឆានី ឮដូច្នោះក៏ឆ្លៀតបន្ទីដោយរួសរាយ ទៅកាន់ ទេពវិន្ទដារ៉ូ ដែរ ÷

-«...ចុះបង៉ូដឹងទេ ថាអ្វីដែលរាំងមិនឱ្យបងសិទ្ធបណ្តោយឱ្យផ្កាឈូកឯនាយសមុទ្រ ក្តោបក្រសោបបាននោះ ?...»

នៅពេលដែលឃើញ ទេពវិន្ទដារ៉ូ រាងអិអាក់ រលោស់មាត់មិនទាន់នោះ យុត្តាភាឆានី ដែលអ្នកផងតែងស្គាល់ថាជាព្រលឹងអាចន្ទ ក្រពើទេវតាក្នុងរឿង "នាងរំសាយសក់ " ឬធិតាកោះកែវនោះ ក៏បន្ទីឡើងភ្ញាមរបៀបកំប្លែងលេងថា ÷

-«នែ៎ បើបងរ៉ូមិនដឹង ខ្ញុំដឹង ! គឺគ្មានអ្នកណាក្រៅពីអាតូចថ្មីម្នាក់ ដែលឈររនៅមាត់ទ្វារផ្ទះនោះទេ មើលចុះរាងវាសង្ហារដូចជាឪវាបេះបិទ អីចឹងបានជាគេហៅវាថា អាដូចៗ !,,,»

គ្រប់គ្នាក៏ផ្តោតខ្សែភ្នែកទៅតាមសំដីរបស់តារារូបស្រស់ ឃើញកុមារម្នាក់អាយុប្រមាណជាងបីឆ្នាំ កំពុងឈរតោងដៃស្រីកណ្តាលវ័យម្នាក់ ដែលទំនងជាឈ្នួលបំរើឬបងប្អូន ហើយដែលសុទ្ធតែសម្លឹងមកកាន់ពិសិដ្ឋពាលីកា និង ខៃប្រសិទ្ធ ដូចគ្នា ។

ឃើញដូច្នោះ តារាថ្កាល់ខ្លួចក៏ប្រញាប់បន្ទឹឡើងទៀតថា ÷

-«មែនហើយ ឆានីនិយាយមិនខុសទេ កូនហ្នឹងគឺជានិមិត្តរូបនៃជីវិតស្នេហារបស់យើងទាំងពីរ ដែលមិនអាចមានអ្វីមកធ្វើឱ្យប្រេះឆាបានឡើយ ទោះជាត្រូវឃ្លាតគ្នាមួយពេលៗ ព្រោះបញ្ហាជីវភាពយ៉ាងនេះក៏ដោយ !,,,»

សម្លេងហ៊ោរកញ្ជៀវចាប់ផ្តើមលាន់រំពងក្នុងឡាន ដោយរំភើបនឹងសំដី ខៃប្រសិទ្ធ នាំឱ្យបង្កើតឡើងនូវបរិយាកាសរីករាយពេញដោយសុភមង្គលភ្លាមៗ ។

ទំនងជាអៀនខ្មាស់ខ្វះៗចំពោះមិត្តរួមអាជីព ពិសិដ្ឋពាលីកាប្រញាប់ឡើងលើឡានឱ្យផុត និងរកកន្លែងអង្គុយសមរម្យ បន្ទាប់ពីចោលខ្សែភ្នែកចុងក្រោយ ពេញដោយភក្តីភាពចំពោះបុរសគូជីវិត និងកូនប្រុសសម្លាញ់ ដែលតាមសំលឹងមើលរថយន្តរំកិលចេញទៅ ។

ដោយពិតនោះ រថយន្តដែលយើងកំពុងជិះនេះ ពុំមែនជាកម្មសិទ្ធិរបស់ផលិតកម្មធពណ្ណរង្សីខ្ញុំនោះទេ គឺជារថយន្តរបស់នាយកដ្ឋានបោះ

ពុម្ពផ្សាយនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលខ្ញុំបានជួលមកដឹកជញ្ជូនក្នុងការថតវីដេអូ ដូចជាផលិតកម្មនានាធ្លាប់ជួលអីចឹងដែរ ។

ជាយូរមកហើយ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈតែងបានទទួលជំនួយជារថយន្តសំរាប់ដឹកជញ្ជូនផ្សេងៗពីសហភាពសូវៀត និងបណ្ដាប្រទេសសង្គមនិយមនានាជាច្រើនដែរ កាលក្នុងសម័យសាធារណរដ្ឋប្រជាមានិត និងរដ្ឋកម្ពុជា ។ ប៉ុន្តែរហូតមកដល់ពេលនេះ ឃើញដូចជានៅសល់តិចតួចណាស់ ។ ឯរថយន្តដែលនៅរឹងប៉ឹងមាំមួនជាងគេ គឺជារថយន្តដែលបើកបរដោយបុរសម្នាក់រាងក្រមាប់ៗ ដូចចិនកាប់ជ្រូកឈ្មោះ ហួរ ដែលផលិតកម្មនានាធ្លាប់តែជួលថត តាំងពីពេលដែលវិស័យភាពយន្តនិងវីដេអូខ្មែរ ចាប់រស់ឡើងវិញនោះឯង ។

មូលហេតុដែលគេចូលចិត្តជួលឡាននេះ មកពីឡាននេះរាងធំ ដឹកជញ្ជូនតួនិងសំភារៈបានច្រើន ហើយអ្នកបើកជាមនុស្សឧស្សាហ៍ព្យាយាមមិនប្រកាន់ខ្លួន តែងជួយលើកដាក់សំភារៈរបស់ផលិតកម្មនានាមិនរើសអើង ចេះបង្កបរិយាកាសឱ្យបានរីករាយសប្បាយ ពិសេសជាងនេះ នៅពេលដែលផលិតកម្មខ្វះខ្វះតួសំដែងភ្លាមៗ ដូចជានាម៉ឺនមន្ត្រីក្នុងរឿងបូរាណ ឬក៏ចៅកែក្នុងរឿងសម័យ អ្នកបើកឡានដ៏ប្រជាប្រិយ៍នេះតែងត្រូវគេចាប់ឱ្យសំដែងបាន និងប្រកបដោយទេពកោសល្យទៀតផង ។

ស្រាប់តែពេលដែលឡានរំកិលចេញផុត ពីបរិវេណវិមានរដ្ឋសភា និងបត់កាច់ទៅតាមផ្លូវមាត់ទន្លេមុខព្រះបរមរាជវាំង អ្នកបើកឡានដែលធ្លាប់តែនាំយករឿងកំប្លែងមកកំដរបរិយាកាស ពេលនោះបែរជាបន្ទឺយ៉ាងស្រងូតស្រងាត់ថា ៖

-« លោកតាំងអី រឿងបុប្ផាពស់វែកនេះ ទោះបីអ៊ំឈៀនមិនទាន់ថាតចប់ស្រួលបួលក្ដី ក៏ខ្ញុំយល់ថាមុខជាមិនអន់ជាងរឿងមុនៗដែរ !... ប៉ុន្តែ ខ្ញុំដូចស្រងាកចិត្ត មិនអស់មិនហើយ គឺឆាកដែលយើងត្រូវថតនៅថ្ងៃនេះ ! បើកុំឱ្យតួអង្គបុប្ផាពស់វែកនោះស្លាប់បានទេ ព្រោះតាមខ្ញុំធ្លាប់ចំណាំមកច្រើនរឿងហើយ ឱ្យតែរឿងដែលមានតួប្រុសឬស្រីស្លាប់នៅចុងបញ្ចប់ ហាក់ដូចជាប្រផ្នូលមិនល្អសោះ គឺអ្វីៗក៏ត្រូវចប់... ទាំងអស់ដែរ !...»

សំដីនេះ មិនបានត្រូវទទួលសំលេងបន្ទរហោរកញ្ឆៀវដូចពេលមុនៗឡើយ ព្រោះម្នាក់ៗបែរជាថ្ងរហឹម ហើយនាំគ្នាចោលភ្នែកក្រឡេកមកកាន់ខ្ញុំភ្លាម ប្រហែលជាគេចង់ស្ដាប់សំដីប្រតិកម្មរបស់ខ្ញុំ តបទៅអ្នកបើកឡាននោះវិញ ។ ប៉ុន្តែពេលនោះខ្ញុំនៅស្ងៀម មិនបានឆ្លើយអ្វីឡើយ ព្រោះខ្ញុំយល់ថាការស្ដាប់មតិរបស់អ្នកដទៃយកមកត្រិះរិះពិចារណាប្រសើរជាងការគ្រាន់តែភ្លាម ហើយឆ្លើយទាំងទទឹងទិស មិនបានគិតមុខគិតក្រោយ ។

ប៉ុន្តែ នៅចន្លោះពេល ដែលខ្ញុំមិនទាន់បានបញ្ចេញយោបល់អ្វីនោះ ប្រពន្ធខ្ញុំក៏ឆ្លៀតនិយាយបន្ទរថា ÷

-« មែនហើយ ប្អូនហួរនិយាយនេះ ដូចជាត្រូវចិត្តខ្ញុំណាស់ ខ្ញុំមិនចង់ឱ្យតួនាងបុប្ផាពស់វែកស្លាប់នៅចុងបញ្ចប់ទេ តែឪវាគេមិនព្រមដោយខ្លាចសាច់រឿងបាត់តុល្យភាព ! ចំពោះខ្ញុំ ធ្លាប់ចំណាំមកច្រើនដងហើយ ឱ្យតែរឿងមានតួស្លាប់ មានទឹកភ្នែកនៅខាងចុង ដូចជាមិនស្រួលសោះ !...»

នៅពេលដែលខ្ញុំនៅតែមិនទាន់ឆ្លើយថាអ្វីយ៉ាងនេះ ស្រាប់តែមានសំលេងឮមកពីខាងក្រោយឡាន ដែលខ្ញុំមិនបានជាងាកមើល និងចំណាំថាជាសំលេងអ្នកណាច្បាស់ឡើយ លាន់ឮឡើងថា ÷

-«...តែសំរាប់ខ្ញុំ មិនយល់យ៉ាងនេះទេ ព្រោះរឿងនិមួយៗតែងតែមានការជួបជុំ និងព្រាត់ប្រាស់គ្នានៅចុងបញ្ចប់ជាធម្មតា !... ម៉្យាងទៀត ខ្ញុំពេញចិត្តណាស់ បើសិនជាគេឱ្យដើរជាតួស្លាប់នៅចុងបញ្ចប់ ! នោះវានឹងធ្វើឱ្យឆាប់ល្បី !...»

ពិសិដ្ឋពាលីកា នៅស្ងៀម រក្សាទឹកមុខញញឹមពេញដោយអាថ៌កំបាំងតាមរយៈការជជែកគ្នានៅលើឡានពេលនោះ ប៉ុន្តែគ្មានអ្នកណាដឹងថា នាងគិតអ្វីខ្លះនោះឡើយ ។.....

ᨦᨧ ᨦᨧ ᨦᨧ

**នៅ**ពេលទៅដល់រមណីយដ្ឋានភ្នំបាសិដ្ឋ ខ្ញុំក៏ចាត់ចែងរៀបចំការងារភ្លាម គឺបានប្រគល់ភារកិច្ចឱ្យអ្នក **Costume** និងអ្នក **Maquiller** ចាប់សំអិតសំអាងមុខមាត់ និងស្លៀកពាក់ឱ្យតួសំដែង ៥ រូប គឺនាងពិសិដ្ឋពាលីកា ទេពវិន្ទដារ៉ូ យុត្តារ៉ាឆានី សុខស្រីមុំ និង ប៊ុនឈឿនសូរីយ៉ាន ដើម្បីរួមគ្នាថតបញ្ចប់ឆាករឿង បុប្ផាពស់វែក ហើយទន្ទឹមនោះខ្ញុំក៏បានដឹកនាំអ្នកបច្ចេកទេសផ្សេងទៀត ទៅរៀបចំទីកន្លែងសំរាប់ថត ដែលត្រូវជ្រើសរើសយកជំរាលថ្មភ្នំជ្រៅខ្ពស់មួយ ធ្វើជារណ្តៅភ្លើងសិល្ប៍ តាមសាច់រឿងដែលបានកំណត់ ។

ជួនជានៅពេលដែលខ្ញុំរៀបចាប់ផ្តើមថត ស្រាប់តែមានអ្នកយកពតិ

មានរបស់វិទ្យុទូរទស្សន៍មួយក្រុម បានបើកឡានទៅដល់ទីនោះដែរ ហើយជនម្នាក់ដែលទទួលខុសត្រូវជាមេក្រុម បាននិយាយមកកាន់ខ្ញុំថា ÷

-«ខ្ញុំបានទទួលពត៌មានថា លោកអឺរៀបចំថតបញ្ចប់រឿងបុប្ផាពស់វែកនៅថ្ងៃនេះ ហើយជាឆាកពិសេស ដែលតម្រូវឱ្យនាងពិសិដ្ឋពាលីកា ដែលសំដែងជាតួអង្គបុប្ផាពស់វែក ត្រូវតួរាហ៊ូដែលសំដែងដោយលោកទេពរិទ្ធដារ៉ូ ចាប់បោះពីលើជ្រោះភ្នំ ទៅក្នុងរណ្តៅភ្លើងសិល្ប៍ !...ខ្ញុំនាំគ្នាមកនេះ ដើម្បីចង់សុំអនុញ្ញាតថតយកព្រឹត្តិការណ៍ជាក់ស្តែងខ្លះក្នុងពេលដែលលោកអឺថត និងចង់បានពត៌មានបន្ថែមពីមនោសញ្ចេតនានៃតួសំដែងម្នាក់...។ ចំពោះការថតដែលប្រកបដោយគ្រោះថ្នាក់របៀបនេះ ?...»

ខ្ញុំសើចតិចៗតបទៅជនទាំងនោះវិញ ហើយឆ្លើយថា ÷

-«...គ្មានគ្រោះថ្នាក់អីទេ ព្រោះខ្ញុំថតនេះ ធ្វើ **Truquage** បន្លំភ្នែក មិនមែនចាប់បោះតួសំដែងពីលើជំរាលភ្នំសុទ្ធៗឯណា ?...! »

និយាយរួច ខ្ញុំក៏ចោលភ្នែកទៅម្ខាង ហាក់ដូចជាចង់នាំខ្សែភ្នែកអ្នកយកពត៌មានទាំងអស់ឱ្យសម្លឹងតាម ទៅកាន់រូបមនុស្សជ័រមួយ ដែលគេកំពុងតុបតែងពាក់សក់ជាស្រី និងស្លៀកពាក់ឱ្យដូចគ្នានឹងតួនាងពិសិដ្ឋពាលីកា ÷

-«...អស់លោក លោកស្រីជ្រាបទេ រូបមនុស្សជ័រនេះ ខ្ញុំបានខ្ចីមកពីរោងជាងភាពយន្ត ដើម្បីយកមកធ្វើជាជំនួយក្នុងការថតឆាកនេះ !...»

អ្នកយកពត៌មានស្រីម្នាក់អាយុប្រហែល ៣៥ឆ្នាំប៉ុណ្ណោះ ដើរយឺតៗ ទៅពិនិត្យសម្លឹងរូបនោះកាន់តែជិត ដោយយកដៃទៅស្ទាបអង្អែលមុខ និងសក់របស់វា ក្នុងសម្លេងរាងភ្ញាក់ផ្អើលថា ÷

-«យី ចុះរូបមនុស្សជ័រអី ក៏ដូចរូបមនុស្សពិតៗយ៉ាងនេះ អ្នកធ្វើ ចំជាប៉ិនប្រសប់មែន ខុសតែកែវភ្នែកសស្លាំងដូចមនុស្សស្លាប់ ឬដូច ភ្នែកពួកអ៊ីរ៉ុបបន្តិចប៉ុណ្ណោះ ?,,,»

ខ្ញុំញញឹម រៀបឆ្លើយបញ្ជាក់ទៅកាន់នារីនោះវិញ តែរលាស់មាត់មិន ទាន់ បុរសម្នាក់ដែលជាអ្នកជួយតុបតែងកាយឱ្យរូបមនុស្សជ័រ បាន និយាយកាត់មុន ÷

-«ត្រូវហើយ ព្រោះម៉ាណឺកាំងនេះ មិនមែនខ្មែរយើងធ្វើឯណា គឺជាអំណោយរបស់ក្រុមផលិតកម្មភាពយន្ត របស់ប្រទេសឆេកូស្លូវ៉ាគី កាលគេមកសហការជាមួយយើង ថតរឿង "នរក ៩ជាន់" !,,, រូប មនុស្សជ័រទាំងនេះ គេយកមកច្រើនណាស់សំរាប់ធ្វើជាមនុស្សស្លាប់ក្នុង ជំនាន់ប៉ុលពត !,,,»

ខ្ញុំក៏បញ្ជាក់បន្តពីបុរសនោះ ÷

-«អស់លោក លោកស្រី គង់បានឃើញថា មុនដំបូងខ្ញុំនឹងឱ្យ ប្អូនវ៉ា ដែលជាតួរាហ៊ូ ចាប់បីនាងពាលិកា ក្នុងតួបុប្ផាពស់វែក ដែល ប្រឡាក់ដោយឈាមក្រោមស្នូរចំរៀងដ៏សោករន្ធត់មួយ មកឈរលើផ្ទាំង ថ្មខ្ពស់នោះ ពោះទម្លាក់នាងទៅក្រោម ដែលមានកំពស់ប្រមាណ ៤-៥ ម៉ែត្រប៉ុណ្ណោះ !,,, នាងគ្មានគ្រោះថ្នាក់អ្វីទេ ព្រោះខ្ញុំបានឱ្យគេយកពូក ច្រើនផ្ទាំងចាំទ្រពីក្រោម និងមានមនុស្សជួយទប់ទ្រ ចាប់ការពារឆ្វេង

ស្អាំ មិនឱ្យនាងរមៀលធ្លាក់ទៅប៉ះទង្គិចនឹងថ្មទៀតផង ! ឯអណ្ដាតភ្លើង ខ្ញុំក៏បានឱ្យគេដុតបន្តិចបន្តួច ដាក់ពីមុខកែវកាមេរ៉ា ដល់ពេលធ្វើ Effect ទៅ វានឹងឃើញដូចជាភ្លើងឆេះសន្ធោរសន្ធៅមែនទែន នៅក្នុងរណ្ដៅនោះ !,,,»

អ្នកយកពត៌មានទាំងអស់ ខំបើកភ្នែកប្រឹងស្ដាប់ខ្ញុំនិយាយក្នុងអាការៈយកចិត្តទុកដាក់ពន់ប្រមាណ ដោយមានខ្លះរុញក្បាលមីក្រូមកជិតមាត់ខ្ញុំ និងខ្លះទៀតខំផ្ចិតកាម៉េរ៉ាវីដេអូ ថតយកអ្វីទាំងអស់ដែលមាននៅទីនោះ ÷

-«មិនមែនតែមនុស្សទេ ដែលខ្ញុំប្រយ័ត្នមិនឱ្យប៉ះអណ្ដាតភ្លើង,,» ខ្ញុំបញ្ជាក់បន្ថែម «,,,សូម្បីតែរូបមនុស្សជ័រនេះ ក៏ខ្ញុំប្រយ័ត្នមិនឱ្យប៉ះភ្លើងដែរ ពិសេសគឺពេលពោះ លៃយ៉ាងណាមិនឱ្យបែកកែវភ្នែកវាទៀតផង !,,,»

មួយភ្លែតនោះ ស្រាប់តែអ្នកយកពត៌មានស្រីដដែលនោះរភ្នែកចុះឡើង ប្រទះឃើញប្រពន្ធខ្ញុំជាមួយស្រីចំណាស់ម្នាក់ កំពុងដាក់ចេកទុំមួយស្និត ដុតទៀនធូប និងដាក់ផ្កាថ្វាយរូបសំណាកអ្នកតាមួយ ដែលថិតនៅក្នុងខ្នមក្បែរនោះ ទើបនាងបែរមកសួរខ្ញុំដោយឆ្ងល់ទៀតថា ÷

-«បើគ្មានបញ្ហាអ្វីដែលគួរឱ្យភ័យព្រួយ ម៉េចក៏ឆាំចាច់មានដុតទៀនធូបបន់ស្រន់អ្នកតាដែរ ? ,,, តើ,,,,នេះជាទម្លាប់នៅពេលលោកអីមុនរៀបចាប់ថតប្រចាំថ្ងៃម្ដងៗ ឬក៏ជាវិធីការពារនូវប្រផ្នូលអាថ៌កំបាំងអ្វីមួយ,, ?,,,»

សំនួរនេះ ស្រីនោះចោទសួរមកខ្ញុំទេ តែប្រពន្ធខ្ញុំដែលស្ដាប់ឮទាន់

ក៏បែរមកឆ្លើយថ្លស ក្រោយដែលដាក់កូនចាសគ្រឿងសក្ការៈបូជានៅពីមុខអ្នកតារួចហើយ ÷

-«ចាជាទម្លាប់ប្រចាំថ្ងៃមុនចាប់ថតម្តងៗក៏បានដែរ ប៉ុន្តែពេលដែលថតឆាកមានតួស្លាប់នៅក្នុងរណ្តៅជ្រោះភ្នំបែបនេះ ចាំបាច់ត្រូវតែបន់ស្រន់ សែនព្រេនបួងសួង ដើម្បីសុំស្រណុកសុខសប្បាយ ពិសេសកុំឱ្យលោះព្រលឹងដល់តួសំដែង !,,,»

ខ្ញុំក៏បន្តរប្រយោគបន្ទាប់ពីឃ្លាប្រពន្ធខ្ញុំទៀតថា ÷

-«,,,មែនហើយ ! ដូចកាលជំនាន់ខ្ញុំថតរឿងជំនោរប៉ៃលិន ដែលតម្រូវឱ្យនាង ចាន់តារាទី ដេកនៅក្នុងផ្នូរនោះ ខ្ញុំក៏បានឱ្យគេរៀបចំផុតទៀនធូបបួងសួងរបៀបនេះដែរ មុនចាប់ផ្តើមថត ដើម្បីកុំឱ្យលោះព្រលឹងដល់តួសំដែង ! ប៉ុណ្ណឹងផងនៅតែលេចឮថា នាងចាន់តារាទីយល់សប្តិអាក្រក់ស្ទើររាល់យប់ បន្ទាប់ពីថតឆាកនោះចប់ !,,,,»

ឮដូច្នោះអ្នកយកពត៌មានទាំងអស់ដកដង្ហើមធំព្រមគ្នា ប្រកបមនោរម្មណ៍គិតវែងឆ្ងាយ ។ ជួនពេលនោះ នាងពិសិដ្ឋពាលីកាបានដើរទៅដល់មុខ អ្នកយកពត៌មានប្រុសម្នាក់ក៏ឆ្លៀតសួរនាងភ្លាមថា ÷

-«តើបងស្រីមានអារម្មណ៍យ៉ាងម៉េចដែរ ដែលត្រូវមកថតឆាកគេបោះទម្លាក់ឱ្យស្លាប់ក្នុងជ្រោះជ្រៅនេះ ?,,,»

តារាឯកស្រីរូបស្រស់ ក្នុងសំលៀកបំពាក់បូរាណរំលេចដោយត្បូងពេជ្រភ្លឺរន្ទាល បង្ហើរសំណើចស្រាលៗចេញពីក្នុងបំពង់កអមដោយសំនៀងប្លែមត្រជាក់ ÷

-«,,,ចាំស ខ្ញុំដូចជាគ្មានអារម្មណ៍អ្វីប្លែកទេ ព្រោះយល់ថានេះជា

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY

រឿងមិនពិត ហើយខ្ញុំក៏ធ្លាប់ថតឆាកស្រដៀងៗនេះមកជាច្រើនរឿងដែរ ប្លែកគ្រាន់តែនេះជារឿងបូរាណ ហើយឆាកមហន្តរាយជីវិតនេះ វាចិត នៅខាងចុងបញ្ចប់តែប៉ុណ្ណោះ !,,,»

-«ចុះបងស្រី មិនយល់សប្តិឃើញអ្វីៗ,,,» អ្នកយកពត៌មានស្រី សួរបន្ថែម «,,,ដែលធ្វើឱ្យបងស្រីព្រឺស្មើប រហូតដល់គិតថា បើសិន ជារឿងនេះក្លាយជាការពិតវិញនោះ,,,, ទេឬ ?,,,»

ខ្ញុំឃើញពាលីកា នៅតែញញឹមស្រាលៗ ឆ្លើយតបមកទៀតថា ÷

-«,,,ខ្ញុំគិតថា រឿងក្នុងឆាករបៀបនេះ មិនអាចក្លាយជារឿងពិត នៅក្រៅឆាកបានឡើយ សំរាប់ជីវិតរបស់ខ្ញុំ ! ដូច្នេះមិនមានអ្វីធ្វើឱ្យខ្ញុំ ព្រឺស្មើបបានទេ ប៉ុន្តែ,,,»

តារារូបឆើត វាចាចោលកន្ទុយឃ្លា ហាក់ដូចជាមិនចង់បន្តទៅទៀត ជាហេតុធ្វើឱ្យក្រុមអ្នកយកពត៌មានទូរទស្សន៍ មានការងឿងឆ្ងល់ ហើយ កាន់តែចង់ដឹង ។ ចំពោះខ្ញុំ ហាក់ដូចមិនចាប់ភ្ញីកនឹងចុងឃ្លានោះប៉ុន្មាន ទេ ព្រោះនឹកស្មានតែនាងគិតព្រួយបារម្ភខ្លះៗដល់បញ្ហា ក្រែងនាងធ្លាក់ ទៅខុសពូកទ្រ ឬអ្នកចាំការពារខាងក្រោម មិនបានប្រុងប្រយ័ត្នតែ ប៉ុណ្ណោះ ។

មួយសន្ទុះក្រោយ នាងក៏ចាប់ផ្តើមរលាស់បបូរមាត់សាជាថ្មីថា ÷

-«,,,យប់មិញ ខ្ញុំយល់សប្តិឃើញប្លែកជាងសព្វមួយដងដែរ គឺ ឃើញដូចជាព្រលឹងខ្ញុំ ប្តីខ្ញុំនិងកូន ដើរទៅលេងដល់លើកំពូលភ្នំដ៏ធំ ខ្ពស់មួយ ស្រាប់តែពេលនោះ មានព្យុះសង្ឃរាកំណាចបក់ពីលើស្រទាប់ ពពកមក បង្កើតជាខ្យល់គួចយ៉ាងខ្លាំង ធ្វើឱ្យប្តីនិងកូនខ្ញុំ មិនដឹងប៉ើង

រសាត់បាត់ទៅទីណា ឯព្រលឹងខ្ញុំវិញ ដូចជាប៉ើងធ្លាប់ទៅក្នុងជ្រោះមួយយ៉ាងជ្រៅ ដែលមានសុទ្ធតែសិល្បករ-សិល្បការិនី ដែលបានស្លាប់ទៅយូរៗហើយ ហុចដៃព្រោងព្រោងចាំទទួលខ្ញុំ !... ហើយខ្ញុំភ័យពេកក៏ស្រែកភ្ញាក់ទាំងកណ្ដាលយប់ !...»

នៅពេលដែលខ្ញុំឃើញទឹកមុខអ្នកយកពត៌មានទាំងនោះ ប្រែប្រួលទៅតាមចង្វាក់ពាក្យរបស់ពាលីកា ដែលហាក់ដូចជាបង្កប់ដោយភាពភ័យខ្លាចខ្លាំងណាស់នោះ ខ្ញុំក៏ប្រញាប់និយាយបន្ថែមដោយអារម្មណ៍ធម្មតាថា ÷

-«ឱ !... បើតាមខ្ញុំយល់ ថានេះមកពីពាលីនឹកភ្នកដល់ឆាកដែលត្រូវថតនៅថ្ងៃនេះពេកហើយ បានជាយល់សប្តិឃើញផ្ដេសផ្ដាស់បែបនោះ !...»

ស្រីស្រស់ ក៏ងក់ក្បាលយឺតៗតាមសំដីរបស់ខ្ញុំដែរ ហើយវាចាបន្ថែមដោយសំលឹងមើលទៅមនុស្សដែលឈរជុំវិញបណ្ដើរ ÷

-«មែន !... ក្រោយពីខ្ញុំនិយាយប្រាប់ម៉ាអាដូចទៅ គេក៏ថាដូចអ៊ីអ៊ីចឹងដែរ !... គឺប្រហែលមកពីខ្ញុំគិតដល់ឆាកថត ដែលត្រូវគេទម្លាក់ទៅក្នុងរណ្ដៅជ្រោះនោះហើយ បានជានាំឱ្យយល់សប្តិឃើញបែបហ្នឹង !... តែការពិត ខ្ញុំគ្មានបានគិតដល់សោះ !...»

នៅពេលដែលក្រុមយកពត៌មានរារែក ប្រុងសួរនាងពិសិដ្ឋពាលីកាអ្វីទៀតនោះ ស្រាប់តែកំលោះទេពវិន្ទដារ៉ូ ដែលទើបតែងខ្លួនរួចក៏មកដល់ជាបន្ទាប់ ជាហេតុធ្វើឱ្យក្រុមនេះបែរមកសួរតារាប្រជ្រុយស្នេហ៍វិញតាមលំអានដែលពួកគេបានសួរនាងពាលីកាខ្លះៗកន្លងមកហើយ ÷

-«ខ្ញុំគ្មានយល់សប្តិឃើញអ្វីទេយប់មិញ គឺគេងលក់តាំងពីក្បាលព្រលប់ ! ឯឆាកដែលត្រូវមកថតថ្ងៃនេះ គិតទៅគិតមក ខ្ញុំដូចជានឹកអាណិតតួនាងបុប្ផាពស់វែកនោះវិញ ដែលខំតាមស្រលាញ់តួរាហ៊ូ ស្ទើរមួយចប់រឿង ដោយប្រើកលល្បិចគ្រប់បែបគ្រប់យ៉ាង ទីបំផុតបែរជាត្រូវទទួលកំហុសយ៉ាងធ្ងន់ធ្ងរ និងមានវិប្បដិសារីព្រោះការបំបែកបំបាក់គូស្នេហ៍របស់គេ ហើយសុខចិត្តលាងបាបកម្មនៅក្នុងរណ្តៅភ្នក់ភ្លើងសិល្ប៍ដ៏គួរឱ្យសោកស្តាយ !...»

ប្រធានក្រុមអ្នកយកពត៌មានសួរបន្ថែម ក្រោយពីឮតារាប្រជុំយស្នេហ៍ ពោលរបៀបស្រងេះស្រងោចដូច្នោះ ÷

-«ចុះបើដឹងថាអីចឹងដែរ ម្តេចក៏បងចាប់នាងបោះទៅក្នុងរណ្តៅភ្លើងសិល្ប៍ ធ្វើអី ?...»

ទេពវិន្ទដារ៉ូ តារាប្រជាប្រិយ៍ ឆ្លើយដោយភ្ជាប់សរសៃសំណើចបណ្តើរ ÷

-«មិនមែនតួរាហ៊ូខ្ញុំ ចង់បោះនាងទម្លាក់ដោយចិត្តឯងឯណា គឺនាងអង្វរខ្ញុំឱ្យបោះនាងទៅក្នុងរណ្តៅភ្លើងនោះ ដើម្បីជាមធ្យោបាយអាចឱ្យនាងជ្រះអកុសលកម្ម ដែលនាងបានធ្វើកន្លងមកក្នុងនាមជាតួនាងបុប្ផាពស់វែកស្រេកឃ្លានតណ្ហា !...»

ភ្ជាប់នឹងប្រយោគនេះ ខ្ញុំក៏បានបញ្ជាក់បន្ថែម ÷

-«មូលហេតុដែលខ្ញុំឱ្យតួនាងបុប្ផាពស់វែកនេះស្លាប់នៅខាងចុង ក៏មកពីចង់ឱ្យនាងភ្ញាក់រលឹកស្គាល់កំហុសខ្លួនឯង !... ព្រោះមនុស្សដែលធ្វើខុស ហើយស្គាល់កំហុសខ្លួនឯង និងចេះកែប្រែកំហុសនោះ គឺជា

មនុស្សល្អប្រពៃណាស់ !! ខ្លាចបំផុត តែមនុស្សដែលធ្វើខុសហើយ ចចេសថាខ្លួនធ្វើត្រូវ និងបំពានធ្វើខុសតទៅទៀតតែប៉ុណ្ណោះ !.,»

តារាប្រជ្រុយស្នេហ៍ ឧទានបន្ថែម ដោយចោលភ្នែកទៅកាន់ពួកអ្នកយកពត៌មានទាំងអស់ ÷

-«ហើយការពិតនោះ តួនាងបុប្ផាពស់វែកនេះ ក៏មិនមែនស្លាប់ទៅរហូតដែរ គឺព្រលឹងរបស់នាងនៅចាំថែរក្សាមាត់រណ្ដៅសិល្ប៍នេះមួយរយៈកាលដែលព្រះអាទិត្យ ៧ រះឡើងតែប៉ុណ្ណោះ នាងនឹងមានជីវិតរស់មកជាមនុស្សវិញជារៀងរហូត !.,.»

.,.បន្ទាប់ពីក្រុមអ្នកយកពត៌មាននោះ បានសាកសួរបន្ថែមជុំវិញបញ្ហាសិល្បៈទី៧របស់ខ្មែរ ដែលរះឡើងនិងឈានទៅកាន់ទីអស្ដង្គតនោះខ្ញុំក៏បាត់ចែងចាប់ថតដំណើររឿងតាមផែនការណ៍ ដែលបានគ្រោងទុកគឺថតឆាករាហ៊ូចាប់បីពរនាងបុប្ផាពស់វែក បោះទៅក្នុងរណ្ដៅភ្លើងមុនទើបថតឆាកទម្លាក់រូបជ័រពីជំរាលថ្មភ្នំជាបន្តបន្ទាប់ ។

ក្រោយពេលដែលតាមដានការថតឆាកទាំងពីរនេះចប់ ក្រុមយកពត៌មានសំរាប់វិទ្យុ ទូរទស្សន៍ ក៏បានសុំលាពួកខ្ញុំត្រឡប់ទៅវិញ ពេញដោយអាការៈស្កប់ស្កល់ក្នុងចិត្ត ព្រោះស្រង់បានពត៌មានសំបូរណ៍បែបសំរាប់យកទៅចាក់ផ្សាយ ដោយឥតបានដឹងថា ពេលដែលត្រូវតួរាហ៊ូបោះទម្លាក់ទៅក្នុងរណ្ដៅភ្លើងនោះ នាងពិសិដ្ឋពាលីកាបែរជាបានឃើញអ្នកធ្វើការទាំងអស់ដែលចាំទ្រនាងពីក្រោម និងពួកពីរបីផ្ទាំងនោះក្លាយទៅជាពួកមនុស្សទាំងអស់ ដែលនាងបានឃើញក្នុងយល់សប្ដិនោះឡើយ ។

រឿងនេះ មានតែខ្ញុំម្នាក់គត់ជាអ្នកដឹង ព្រោះពេលសំរាកថត ញ៉ាំបាយ នាងពាលីកាបានខ្សឹបប្រាប់ខ្ញុំដោយស្ងាត់ៗ គឺមើលមួយភ្លែតទៅឃើញសុទ្ធតែពួកសិល្បករ-សិល្បការិនីដែលស្លាប់ទៅហើយ បានហុចដៃត្រហេបត្រហុបមកចាំទទួលនាង ។,,,

# ២

## អព្ភូតហេតុនៃឆាកបញ្ចប់

ក្រោយពីរឿងនេះបានថតចប់ ខ្ញុំមិនសូវបានជួបនាងពិសិដ្ឋពាលីកាញឹកញាប់ដូចមុនឡើយ ព្រោះទាំងនាងទាំងខ្ញុំសុទ្ធតែមានការរវល់រៀងៗខ្លួន ។

លុះមកដល់ចុងឆ្នាំ១៩៩៥ នៅសាលមហោស្រពចតុមុខមានរៀបចំការសំដែងសិល្បៈរបាំបូរាណខ្មែរមួយ ក្រោមការចាត់ចែងរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីអបអរសាទរពិធីបុណ្យជាផ្លូវការមួយរបស់រដ្ឋ ។

ឱកាសនោះ ខ្ញុំក៏មានភ័ព្វវាសនាបានទទួលប័ណ្ណអញ្ជើញមួយសន្លឹកឱ្យទៅចូលរួមទស្សនាសិល្បៈនារាត្រីនោះដែរ ហើយក៏បានជួបនឹងនាងពិសិដ្ឋពាលីកា ដែលខែប្រសិទ្ធបើកឡានជូនទៅសំដែង នៅមាត់ទ្វារចូលដោយចៃដន្យ ។

ក្រោយពីសំដែងការគួរសមរកគ្នា និងសាកសួរសុខទុក្ខទៅវិញទៅមករួចហើយ ខ្ញុំក៏ឆ្លៀតសួរទៅកាន់នាងពិសិដ្ឋពាលីកាបន្ថែមថា ÷

-«ពាលីកា ចុះម្តេចទៅ បានធ្វើតាមពាក្យអ៊ំផ្តាំទេ ?,,,»

តារាឯក ញញឹមងាកទៅប្ដី ហើយបុរសថ្កាល់ខ្លួចម្នាងនេះ ក៏ឆ្លើយបញ្ជាក់ភ្លាម ÷

-«អ្ហ៎ុ... រឿងហ្នឹងអីចាអ៊ំ ក្រោយពីឮអាកាគេនិយាយប្រាប់ ខ្ញុំក៏បានផ្ញៀតនាំគ្នាទៅវត្តសំរោងអណ្ដែត និមន្តលោកឱ្យសូត្រធម៌រំដោះគ្រោះ និងស្រោចទឹកលើករាសីជាច្រើនដងហើយ ឃើញថា តាំងពីពេលនោះរហូតមក បានសុខសប្បាយល្អណាស់ ពុំមានអីប្រែប្រួលទេ !..»

ខ្ញុំក៏ញញឹម នៅពេលដែលតារាឯកស្រី ឆ្លើយបន្ទរពីឃ្លារបស់ប្ដី ÷

-«ចុះរឿង បុប្ផាស់វែករបស់លោកអ៊ំនោះ បានដាក់បញ្ចាំងហើយនៅ ?...»

ខ្ញុំក៏ឆ្លើយតបភ្លាមៗ ដោយមិនចាច់ឱ្យម្ចាស់សំនួររង់ចាំយូរ ÷

-«...បញ្ចាំងឯណា អាកាអើយ បើរំឮតចប់ចំពេលដែលរីដេអូខ្មែរធ្លាក់ចុះយ៉ាងខ្លាំងនេះ !... អាកា និងសិទ្ធដឹងហើយ បើបុស្តិ៍ទូរទស្សន៍កាន់តែច្រើន បញ្ចាំងសុទ្ធតែរឿងបរទេស ទោះបីជាយកទៅបញ្ចាំងនៅរោង ក៏គ្មានអ្នកណាមើលដែរ !... អ៊ំសំរេចចិត្តទុកមួយរយៈសិន ចាំស្ដាប់មើលសភាពការណ៍ !...»

ពេលនោះ ខ្ញុំជួបនិយាយគ្នាជាមួយពិសិដ្ឋពាលីកា និងប្ដីនាងបានតិចតួចណាស់ ព្រោះនាងប្រញាប់ចូលទៅខាងក្រោយឆាកដើម្បីរៀបចំតុបតែងខ្លួន ។

ខ្ញុំនៅចាំបានថា រាត្រីនោះ ពិសិដ្ឋពាលីកា បានចេញសំដែងជាតួនាយរោង គឺតួអង្គព្រះរាមដ៏ពោរពេញដោយទេពកោសល្យ ។ កាយវិការកាច់ក្បាច់រាំ តាមរយៈម្រាមដៃដ៏ទន់ល្វតល្វៃ និងក្បាច់ប្រយុទ្ធធ្វើ

សង្គ្រាមជាមួយក្រុងភាពដើម្បីការពារនាងសិតា បានធ្វើឱ្យទស្សនិកជនទាំងអស់ទះដៃកោតសរសើរស្ងប់ស្ងែងជាខ្លាំង ។

គិតតាំងពីភ្ញៀវកំប៉ិកកំប៉ុកធម្មតាដូចជារូបខ្ញុំ និងមន្ត្រីអ្នកមុខអ្នកការរហូតទៅដល់ថ្នាក់ដឹកនាំកំពូលៗរបស់រដ្ឋាភិបាល ក៏កោតសរសើរទេពកោសល្យសំដែងរបស់ពិសិដ្ឋពាលីកា មិនដាច់ពីមាត់ដែរ ។ ហើយនៅពេលចប់ការសំដែង តំណាងរបស់រដ្ឋាភិបាល បានឡើងជូនបាច់ផ្កាកិត្តិយសដល់នាង ដែលជាតំណាងឱ្យសិល្បករ-សិល្បការិនីទាំងអស់ពោរពេញដោយការលើកទឹកចិត្តយ៉ាងខ្លាំងក្លា ។

ឆ្លៀតឱកាសនោះ ខ្ញុំក៏បានពោលខ្សឹបៗទៅកាន់ខែប្រសិទ្ធ ដែលអង្គុយមើលនៅជិតខ្ញុំដែរថា ÷

-«...សិទ្ធ ឯងជាប្រុសម្នាក់ចំជាមានភ័ព្វវាសនាខ្ពស់ណាស់ ដែលបានភរិយា ទាំងរូបស្អាត ទាំងពោរពេញដោយសមត្ថភាព ! ទោះបីពេលនេះវីដេអូខ្មែរស្រុតចុះយ៉ាងណាក៏ដោយ ក៏ប្រពន្ធឯងមិនស្រុតបានដែរ ព្រោះនាងជាដួងព្រលឹងនៃសិល្បៈបូរាណរបស់ខ្មែរនាពេលបច្ចុប្បន្ននេះ !... ចូរសិទ្ធ...ខំថែរក្សានាងឱ្យបានម៉ាំទាំល្អល្អះបំផុត ឱ្យដូចជាតួអង្គព្រះរាមខំថែរក្សាការពារនាងសិតាយ៉ាងនោះដែរ !..»

៚ ៚ ៚

**ពីរ**ឆ្នាំក្រោយមក ខ្ញុំក៏មិនសូវបានឃើញតារារូបស្រស់នេះផ្ទាល់ទៀតដែរ គឺគ្រាន់តែបានឃើញនាងតាមរយៈការសំដែង ចំរៀងកាយវិការការ៉ាអូខេ និងសំដែងនៅលើឆាកខនសឺត តាមកញ្ចក់ទូរទស្សន៍ខ្លះៗ។

ប៉ុណ្ណោះ ។ ទន្ទឹមនោះ ក៏បានដឹងពីសកម្មភាពរបស់នាងខ្លះៗដែល ទស្សនាវដ្ដីនានាបានចុះផ្សាយជាហូរហែ ដូចជាការចេញទៅសំដែងរបាំនៅតាមរោងមហោស្រពនានា ឬនៅក្រៅប្រទេស ។ ដូចគ្នានឹងខែប្រសិទ្ធដែរ បន្ទាប់ពីបរិយាកាសដុនដាបនៃសិល្បៈវិជ្ជាខ្មែរ គេតែងតែទៅផ្សងព្រេងនៅប្រទេសក្រៅជាប់ជានិច្ច ដើម្បីបានកំរៃជីវភាពពីការសំដែងនានាយកមកជួយផ្គត់ផ្គង់គ្រួសារ ។

...ខ្ញុំនៅចាំបានថា មុនព្រឹត្តិការណ៍ថ្ងៃ៥ ថ្ងៃ៦ កក្កដា១៩៩៧ បីថ្ងៃ ខ្ញុំបានជួបនាងពិសិដ្ឋពាលីកាដោយចៃដន្យ នៅមុខក្រសួងវប្បធម៌និងវិចិត្រសិល្បៈចាស់ ដែលពេលនោះនាងបានសុំខ្ចីរឿងបុប្ផាពស់វែករបស់ខ្ញុំទៅមើល ព្រោះតាំងពីថតចប់រហូតមកទល់ពេលនេះ នាងមិនទាន់ដែលបានមើលសោះ ។

ដោយពេលនោះ ខ្ញុំបានដាក់កាស្សែតចម្លងរឿងបុប្ផាពស់វែកមួយក្លូពីតាមកាតាបយួរទៅក្នុងពេលនោះដែរ ខ្ញុំក៏បានឱ្យនាងភ្លាមដោយគ្មានទើសទាល់ និងបញ្ជាក់បន្ថែមថា ÷

-«អាកា យកទៅមើលចុះ ហើយជួយរិះគន់កែលំអឱ្យអីផងព្រោះរឿងបូរាណប្រឌិតប្រភេទនេះ ពិបាកធ្វើឱ្យដល់គោលដៅដែលចង់បានណាស់ នៅពេលដែលយើងខ្វះខាតទាំងសព្វទាំងគ្រប់បែបនេះ ?»

ពិសិដ្ឋពាលីកាញញឹម ហើយវាចាតិចៗតបមកវិញ ÷

-«ខ្ញុំយល់ហើយ តែទោះយ៉ាងណាក៏ស្នាដៃ...លោកអី...»

ខ្ញុំក៏ឆ្លើយកាត់ទៅវិញភ្លាម ដោយមិនចង់ឱ្យនាងសរសើរខ្ញុំចំពោះមុខទាំងទើសទាល់ ÷

-«,,,និយាយអីចឹង លេខទូរស័ព្ទអាកា,,,ប៉ុន្មាន ឱ្យអីសុំទុកផង ក្រែងលោមានការទាក់ទងទៅថ្ងៃក្រោយ,,! ហើយនេះ,,, លេខទូរស័ព្ទ អី !,,,»

ក្រោយពីការឱ្យលេខទូរស័ព្ទគ្នាទៅវិញទៅមក នាងពិសិដ្ឋពាលីកា ក៏បានបែកពីខ្ញុំទៅ ប៉ុន្តែនៅយប់នេះប្រហែលជាម៉ោង១១ នាងបាន ទូរស័ព្ទមកប្រាប់ខ្ញុំវិញថា ÷

-«,,,ខ្ញុំបានមើលរឿងបុប្ផាពស់វែករបស់លោកអ៊ីចប់ហើយ ហើយ ខ្ញុំសូមសរសើរដោយស្មោះ ត្រង់វគ្គចុងបញ្ចប់ដែលបងដារ៉ូ ចាប់បោះតួ ខ្ញុំទៅក្នុងរណ្ដៅភ្នក់ភ្លើង ! តើលោកអ៊ីចេះធ្វើ **effect** កាត់តយ៉ាងណា បានជានៅពេលដែលខ្លួនខ្ញុំធ្លាក់របូតផុតពីដៃគាត់ ស្រាប់តែប្រែក្លាយ ទៅជាគ្រោងឆ្អឹងដូចអស្សុភយ៉ាងនោះ គឺវាដូចជាខ្លួនខ្ញុំទាំងមូលត្រូវឆ្លង កាត់ឥទ្ធិពលនៃកាំរស្មីអ៊ិច **(X)** ដែលអ្នកជំងឺតែងតែឆ្លុះនៅក្នុងមន្ទីរ ពេទ្យ ?,,,,»

ពេលនោះ ខ្ញុំដូចជាង៉េះង៉ះបន្តិច ហើយសួរទៅវិញភ្លាមថា ÷

-«,,,សូមទោសពាលីកា ក្មួយនិយាយម្ដងទៀតមើល តើក្មួយ និយាយពីរឿងអី អ៊ីស្ដាប់,,,,មិនទាន់ ?,,,»

សម្លេងពីចុងខ្សែតបមកវិញ ÷

-«ចាំះ គឺរឿងបុប្ផាពស់វែករបស់លោកអ៊ី ត្រង់ចុងបញ្ចប់នោះ អស្ចារ្យណាស់ ព្រោះលោកអ៊ី ចេះធ្វើឱ្យខ្លួននាងបុប្ផាពស់វែក ឬរូបខ្ញុំ នោះ ក្លាយទៅជាឆ្អឹងអស្សុភសុទ្ធៗ រួមទាំងអ្នកដែលចាំទ្រខ្ញុំនៅក្នុងរណ្ដៅ ភ្លើង ក៏សុទ្ធតែឆ្អឹងអស្សុភដែរ តែមានកាយវិការរស់រវើកដូចជាមនុស្ស!

កន្លងមកខ្ញុំធ្លាប់តែឃើញក្នុងកុនពួកហូលីវូត តែនេះលោកអ៊ីបែរជាអាចធ្វើបានដែរ ចំជាបច្ចេកទេសខ្ពស់មែន នេះប្រហែលជាម៉ាស៊ីន effect ដែលលោកអ៊ីប្រើនោះ មានគុណភាពកំរិតខ្ពស់ណាស់ហើយ,,,? »

ម្តងនេះ ទើបខ្ញុំឆ្លើយតបវិញដោយមិនអស់មិនហើយក្នុងចិត្ត ÷

-«,,,តែអ៊ី ដូចជាមិនបានធ្វើបច្ចេកទេសអ្ហឹងខ្មោចអី ដូចពាក្យក្មួយនិយាយសោះ គឺអ៊ីថតតាមតែធម្មតា ម៉េចក៏ក្មួយមើលឃើញជាបែបហ្នឹងទៅវិញ ?,,,»

-«ខ្ញុំឃើញច្បាស់ណាំ,,,លោកអ៊ី ! » ពាលីកាតបមកវិញយ៉ាងញាប់មាត់ «,,,បើមិនឃើញ ខ្ញុំមិនថា,,,ទេ !,,,»

សំដីនេះ ធ្វើឱ្យខ្ញុំចាប់ឆ្ងល់ភ្លាម ទើបសួរទៅវិញទាំងមិនបានត្រៀមទុកជាមុន ÷

-«អាកា ក្មួយប្រាកដជាមើលឃើញយ៉ាងហ្នឹងមែនឬ ហើយអ្នកណាបានឃើញខ្លះ ប្តីក្មួយបានឃើញផងទេ ?,,,»

សំនួរនេះ ធ្វើឱ្យពាលីកាវាចាតបវិញ ដោយរយាលឃ្លាបន្តិច ÷

-« ប៉ាអាដូច គេមិនទាន់ត្រលប់មកពីក្រៅផងនោះ គឺខ្ញុំចាក់មើលតែម្នាក់ឯង ព្រោះឈ្នួលនិងកូនខ្ញុំដេកលក់ទៅហើយ ! ហ្នឹង,,,លោកអ៊ី ប្រហែលមិនជឿថាខ្ញុំនិយាយនេះជារឿងពិតទេឬ ?,,,»

ខ្ញុំនៅតែឆ្លើយទៅវិញដោយអាការៈងឿងឆ្ងល់ដដែល ÷

-«មិនមែនថាអ៊ីមិនជឿនោះទេ ប៉ុន្តែអ៊ីដូចជាមិនអស់ចិត្តសោះថាអ្វីៗវាអាចប្រែប្រួលទៅជាបែបហ្នឹងកើត ឥឡូវអាកាបិទទូរស័ព្ទសិនចុះណាំ ទុកពេលឱ្យអ៊ីពិនិត្យមើលរឿងរបស់អ៊ីសិន តើវាដូចគ្នានិងអ្វី

ដែលក្មួយបានឃើញនោះទេ ចាំអ៊ំទូរស័ព្ទទៅប្រាប់វិញ !...»

-«ចាះ !.. ចាះ !...» ពាលីកាឆ្លើយជាចុងក្រោយយ៉ាងត្រជាក់ចិត្ត «...ខ្ញុំគិតថា លោកអ៊ំចាស់ហើយ ការងារនិពន្ធក៏ច្រើន ប្រហែលជាភ្លេចភ្លាំង អ្វីដែលបានធ្វើហើយ បែរជាប្រកែកថាមិនបានធ្វើទៅវិញ ! ជួនកាលលោកអ៊ំរវល់ពេក ក៏ប្រគល់ការងារនេះ ឱ្យគេធ្វើបញ្ចប់ ហើយលោកអ៊ំបែរជាភ្លេច... ? មិនអីទេ ខ្ញុំនឹងរង់ចាំទទួលដំណឹងពីលោកអ៊ំនៅពេលដែលលោកអ៊ំ ពិនិត្យរឿងលោកអ៊ំសាជាថ្មីរួច ! ខ្ញុំសូមលាសិនចាះ !... រាត្រីសួស្តី... លោកអ៊ំ !....»

ក្រោយដែលបិទទូរស័ព្ទហើយ ខ្ញុំសម្ងំគិតតែម្នាក់ឯងយ៉ាងយូរនៅលើតុសរសេរ ដោយមិននិយាយប្រាប់អ្នកណាឡើយ ។ អ្វីដែលធ្វើឱ្យខ្ញុំចាប់អារម្មណ៍មែនទែននោះ គឺពាក្យពិសិដ្ឋពាលីកានិយាយនៅពេលនេះ វាមិនសូវខុសអីពីពាក្យដែលនាងនិយាយប្រាប់ខ្ញុំ កាលថតបញ្ចប់រឿងនៅភ្នំបាសិដ្ឋពីចុងឆ្នាំ ១៩៩៤ នោះឡើយ ។

មិនអស់ចិត្ត ខ្ញុំក៏លបៗយកកាសែ្សតចំលងរឿងបុប្ផាពស់វែកមួយក្ដូពីទៀតពីថតតុ ឈូសទៅខាងចុងបញ្ចប់ ដើម្បីស្ដាបស្ទង់មើល តើវាមានប្រែប្រួលដូចសំដីដែលនាងពិសិដ្ឋពាលិកាបាននិយាយនោះមែនដែរឬទេ ?...។

ប៉ុន្តែក្រោយពីមើលចប់ ខ្ញុំដកដង្ហើមធំយ៉ាងរសាប់រសល់នៅក្នុងចិត្ត ព្រោះមិនឃើញមានអ្វីប្លែក ដូចពាក្យនាងត្រូវបានិយាយសោះ គឺតួនាងបុប្ផាពស់វែកដែលត្រូវតួរាហ៊ូ ចាប់បោះទៅក្នុងរណ្ដៅភ្លើងតាមបច្ចេកទេសតួបផ្សំបន្ទំភ្នែកជាមួយរូបជ័រនោះ នៅជារូបមនុស្សធម្មតា ពុំដែល

ប្រែក្លាយទៅជារូបអសុភគ្រោងឆ្អឹងនោះឡើយ ។

កាលបើអ្វីៗនៅដដែលយ៉ាងនេះ ធ្វើឱ្យខ្ញុំកាន់តែនឹកឆ្ងល់ទ្វេឡើង ថាតើកម្លាំងអាថ៌កំបាំងអ្វី ដែលបណ្ដាលឱ្យនាងពាលីកាមើលរឿងបុប្ផ ពស់វែក ប្រែប្រួលទៅជាដូច្នោះ ឬមួយក៏ខ្សែវីដេអូរឿងនេះ មានវិញ្ញាណ សម្ងាត់អ្វីមួយសណ្ឋិតនៅ ? ។

ខ្ញុំបានសន្យាជាមួយតារារូបស្រស់ថា នឹងទូរស័ព្ទទៅប្រាប់នាងវិញ ក្រោយពេលដែលពិនិត្យរឿងនេះរួចរាល់ ប៉ុន្តែពេលនោះម៉ោងជិត១២ អធ្រាតទៅហើយ បើទូរស័ព្ទទៅរកនាងដូចជាមិនសមសោះ ហើយវាក៏ គ្មានការចាំបាច់ប្រញាប់ប្រញាល់អ្វីផង ។ ទើបខ្ញុំសំរេចចិត្តថា ចាំដល់ ព្រឹកស្អែកពេលទំនេរ ចាំទូរស័ព្ទទៅប្រាប់នាង ។

ប៉ុន្តែជួនអីជាព្រឹកឡើង ប្រមាណជាម៉ោង១០ ស្រាប់តែទូរស័ព្ទដែ ខ្ញុំលាន់ឮឡើង ។ ខ្ញុំក៏លើកឡើងសួរដោយមិនបានពិនិត្យមើលលេខ ក៏ ស្គាល់ជាក់ជាសម្លេងខែប្រសិទ្ធ ទើបខ្ញុំលាន់មាត់ភ្លាមថា ÷

-«អ្ហា,,,សិទ្ធ !,,, មកដល់,,,ពីអង្កាល់ ?,,,»

-«ខ្ញុំមានទៅណា ចា៎អឺ ! ខ្ញុំនៅផ្ទះ,,,ទេ,,,,តើ !,,»

-«ចុះម៉េចក៏យប់មុិញ អាកានិយាយថា សិទ្ធឯងទៅក្រៅមិនទាន់ ត្រឡប់មកវិញ ?,,,»

-«អ្ហូ,,,ខ្ញុំទៅដើរលេង ញ៉ាំអីជាមួយមិត្តភ័ក្តិ,,,បន្តិច,,,ទេតើ ចា៎អឺ ច្រឡំស្មានថាខ្ញុំទៅបរទេសឬ ?,,,»

-«អឺុ មែនហើយ អឺស្មានថាសិទ្ធឯងទៅប្រទេសណាមួយ មិន ទាន់ត្រឡប់មកវិញ,,,? »

ស្រាប់តែ ខែប្រសិទ្ធ សម្ងំបន្តិច ហើយផ្ដើមនិយាយរឿងផ្សេងវិញ ក្រោយពីអស់សំណើចស្រាលៗថា ÷

-«...និយាយអីចឹង ខ្ញុំបានមើលរឿង បុប្ផាពស់វែករបស់ម៉ាអ៊ឹ ហើយ !...»

ខ្ញុំក៏ដេញសួរទៅវិញភ្លាម ÷

-«...សិទ្ធឯងបានមើលនៅឯណា មើលជាមួយអាកាហ្អី ?...»

សម្លេងពីចុងខ្សែឆ្លើយមកទៀតយ៉ាងរហ័ស ÷

-«...អត់ទេ ខ្ញុំមើលម្នាក់ឯង ! ព្រោះព្រឹកឡើង ក្រោយពីជូនអាកាទៅសកលវិទ្យាល័យហើយ ត្រឡប់មកផ្ទះវិញ ខ្ញុំក៏មើលកាសែតវិដេអូរឿងបុប្ផាពស់វែកមួយដុំនៅក្នុងថតតុ ក៏នឹកថាប្រាកដជាអាកាខ្ចីម៉ាអ៊ឹមកមើល !... ខ្ញុំក៏ចាក់មើលភ្លាមទៅ ព្រោះយូរមកហើយខ្ញុំចង់មើលរឿងភាគបន្តពីរឿងឥន្រ្ទីកុមារនោះដែរ !..»

ស្របតាមគោលបំណង ដែលចង់ដឹងពីរឿងហ្នឹងផង ខ្ញុំក៏បន្ទឺទៅវិញជាបន្ទាន់ ÷

-«អ៊ើ...បើសិទ្ធឯងបានមើលហើយ តើសិទ្ធយល់ឃើញយ៉ាងម៉េចខ្លះទៅ ?...»

ខ្ញុំឮខែប្រសិទ្ធបង្ហើរសំណើចស្រាលៗតាមទូរស័ព្ទមកទៀត ភ្ជាប់ដោយប្រយោគថា ÷

-«បើតាមសភាពការណ៍សិល្បៈភាពយន្តវីដេអូខ្មែរ ដែលកំពុងប្រឹងរស់ឡើងដោយត្រដាបត្រដួសសព្វថ្ងៃនេះ ស្នាដៃរបស់ម៉ាអ៊ឹនេះមិនអន់ទេ វាមានកន្លែងប្លែកច្រើនជាងភាគទី១ ប៉ុន្តែខ្ញុំស្ដាយបន្តិច...»

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY

ខ្ញុំចាប់គំនូចឃ្លានេះបាន ទើបដេញសួរទៅវិញភ្លាម ÷

-«ស្ដាយយ៉ាងម៉េចសិទ្ធ ចាមកមើល៍ កុំខ្វាចចិត្តអឹ,,,,អឺ,,,ព្រោះសិល្បៈណាក៏ដោយ បើខ្វះការទិទៀត តែលំអ មិនអាចរីកចំរើនទៅមុខបានឡើយ,,,»

តារាខួចថ្កាល់ម្នាង ក៏ឆ្លើយមកវិញដោយអធ្យាស្រ័យល្អដដែល ÷

-«,,,គឺខ្ញុំស្ដាយនៅភាគបញ្ចប់នៃរឿង ត្រង់បង្ស៊ូចាប់បោះអាកាដែលជាតួនាងបុប្ផាពស់វែក ទៅក្នុងរណ្ដៅភ្លើងសិល្ប៍នោះ មើលទៅរាងធម្មតាបន្តិច សំរាប់ភ្នែកខ្ញុំដែលជាសិល្បករដែរ បើសិនជាចាំអឺធ្វើឱ្យនាងបុប្ផាពស់វែក គ្រាដែលធ្លាក់ផុតពីដៃបង្ស៊ូទៅហើយ ឱ្យខ្លួននាងក្លាយទៅជាឆ្អឹងអសុភនិងពួកដែលនៅចាំទទួល ឱ្យមានសុទ្ធតែគ្រោងឆ្អឹងខ្មោចទាំងអស់ដែរនោះ កាន់តែវិសេសវិសាលមែនទែន ! ព្រោះតាមសាច់រឿង ថានាងបុប្ផាពស់វែកបានភ្ញាក់រលឹកដឹងកំហុសនៅចុងបំផុត ដូច្នេះគួរកុំឱ្យនាងមាននៅសល់សាច់ឈាម ដែលជាគ្រឿងសម្រស់សម្ផស្សលោកបន្ទំភ្នែក ឱ្យនៅសល់តែឆ្អឹងទទេស្អាតចុះ ដើម្បីដល់ចាប់កំណើតជាថ្មី ឱ្យរូបរាងថ្មីនោះពោរពេញដោយក្ដីបរិសុទ្ធស្អាតហ្មត់ហ្មង កុំប្រឡាក់ប្រឡូសដោយក្ដីមន្ទិលសៅហ្មងពីអតីតកាល !,,»

ខ្ញុំកាន់តែនឹកឆ្ងល់ ហើយសួរបន្ត ÷

-«,,,យោបល់សិទ្ធនេះ ល្អប្រសើរណាស់ !,,, អីចឹងសិទ្ធមិនបានមើលឃើញដូចជាអាកាទេអ្ហ៎ នៅចុងបញ្ចប់នោះ ? »

ម្ដងនេះ ខ្ញុំឮសម្លេងសិទ្ធ ដូចជាមានអាការៈឆ្ងល់ប្លែកពីមុន ÷

-«ទេ,,,ចាំអឺ ព្រោះខ្ញុំឃើញតែម្នាក់ឯង មិនដឹងថាអាកាមើលពី

យប់មិញ យល់ដូចខ្ញុំដែរឬយ៉ាងណានោះទេ !,,,»

នៅពេលនោះហើយ ដែលខ្ញុំដឹងពិតថាកាស្សែតរឿងបុប្ផាពស់វែកមួយជុំនោះ មានការមើលឃើញខុសគ្នានៅភាគខាងចុងប្រាកដជាមានអព្ភូតហេតុអ្វីមួយ ដែលបណ្ដាលឱ្យប្ដីប្រពន្ធនេះ មើលឃើញខុសគ្នាដូច្នេះ ? ។

តែខ្ញុំមិនបានប្រាប់ពីរឿងចម្លែកនេះទៅតារាថ្កាល់ខ្លួចឱ្យដឹងទេ ក្រែងមានការជឿងឆ្ងល់កាន់តែធ្ងន់ឡើង គ្រាន់តែខ្ញុំឆ្លៀតសួរទៅបន្ថិចទៀតថា ÷

-«,,,,ពេលជូនអាកាទៅសាលាខាងជើង សិទ្ធមានឮនាងនិយាយថាដូចម្ដេចខ្លះ ពីរឿងនេះទេ ?,,,»

-«ទេ ! ខ្ញុំដូចជាមិនឮនាងនិយាយថាដូចម្ដេចទេ ប៉ុន្តែនាងបែរជានឹកអាណិតតួនាងបុប្ផាពស់វែក ដែលទីបំផុតស៊ូប្ដូជាជីវិតខ្លួនឯងក្នុងភ្លើង ដើម្បីលាងកំហុសដែលបានធ្វើកន្លងមក,,,,»

ខ្ញុំដូចជាឮខែប្រសិទ្ធប្រុងនិយាយអ្វីបន្តខ្លះទៀត ប៉ុន្តែបែរជាអាក់ខានទៅវិញ ដោយពេលនោះឮស្នូរប្រាវ ! ទំនងដូចជាធ្លាក់អ្វីមួយនៅក្បែរខ្លួនគេ ។

ប្រហែលជាដោយសារទូរស័ព្ទនៅជាប់នឹងមាត់ស្រោប់ហើយ ទើបបន្ទាប់ពីស្នូរធ្លាក់ប្រាវ ! នោះ ខែប្រសិទ្ធក៏លាន់មាត់ស្រែកឡើងថា ÷

-«មីង !,,,អ៊ើ,,,មីង !,, មកមើលអាដូចសិន !,,, វាឡើងធើអីនៅក្បែរតុនោះ បានជាប៉ះកញ្ចក់រូបថត ដាក់នៅលើតុនោះបែកខ្ទេច,,,ទៅហើយ !,,,»

ពេលនោះ ខ្ញុំឮសូរដូចជាមាត់ស្រីបំរើ រត់ចេញមកពីផ្ទះបាយ ហើយស្រែកបន្តថា ÷

-«,,,ងាប់ហើយ បែកកញ្ចក់រូបថតរៀបការរបស់ចាម៉ាក់ខ្ទេច ចុះចៅឯងរើរកអី,,,នៅលើតុនោះ !,,, អ្ហ៎,,, ចង់បានកាស្សែតវីដេអូនោះមែនទេ ?,,,»

ខ្ញុំឮខេប្រសិទ្ធរអ៊ូទៅកាន់កូនប្រុសតិចៗថា ÷

-«ចុះកាស្សែត នៅថតតុខាងក្រោមមានគរគោក ម៉េចក៏កូនមិនយកលេង ទៅយកអីកាស្សែតនៅលើតុ ដែលចាទើបមើលរួចហ្នឹង ? ឃើញទេទាល់តែប៉ះកញ្ចក់រូបថតអនុស្សាវរីយ៍នោះបែកខ្ទេច,,,? »

ពេលនោះ ខ្ញុំក៏បានឮតមាត់ទៅពីរបីម៉ាត់ដែរថា ÷

-«អ្ហ៎,,, ប្រហែលជាគេចង់មើលរឿង ដែលម្ដាយគេសំដែងទេដឹងបានជាគេប្រតោងឡើង,,, រហូតទាល់តែប៉ះកញ្ចក់រូបថតនោះ ? ណ្ហើយកុំខឹងអី ក្មេងឆ្លាតតែងតែរពិសអីចឹងឯង កញ្ចក់រូបថតបែកអាចផ្លាស់បានវិញ,,,ទេតើសិទ្ធ !,,,»

ខ្ញុំឮបុរសថ្កាល់ខូច ឆ្លើយមកវិញរបៀបសោកស្ដាយថា ÷

-«,,,ចាអ៊ឺ មិនជ្រាបទេ កាលពីពេលដែលខ្ញុំទៅសំដែងសិល្បៈនៅប្រទេសអូស្ត្រាលីលើកដំបូង ខ្ញុំបានដាក់រូបថតពាក់កណ្ដាលខ្លួនកាលខ្ញុំរៀបការជាមួយម៉ាក់អាដូចទៅមួយសន្ទឹក ហើយមានមិត្តម្នាក់បានចំណាយលុយកាក់យករូបថតនោះ ទៅជួលអ្នកបច្ចេកទេសអូស្ត្រាលីឱ្យផ្ចិតភ្ជាប់លើបន្ទះកញ្ចក់រាយចាន់ ដែលក្រាសជាងកញ្ចក់វ៉ែនតាបន្តិចមានទំហំប៉ុនកាតប៉ុស្ដាល់ សំរាប់ធ្វើជាកាដូចំពោះថ្ងៃមង្គលការរបស់ខ្ញុំ

ដោយបានឆ្លាក់អក្សរតូចៗជាភាសាអង់គ្លេស ដាក់ពីក្រោយកញ្ចក់នោះថា "**គូស្នេហ៍អមតៈ**" ទៀតផង គឺបំណងរបស់គេចង់បញ្ជាក់ថា គេសុំឱ្យជីវិតស្នេហារបស់ខ្ញុំចិតថេររឹងប៉ឹងជាប់ស្អិតរហូត ដូចជារូបថតជាប់ស្អិតនៅលើកញ្ចក់ភ្ជាយបាន់នេះ កុំឱ្យប្រេះឆាបែកបាក់យ៉ាងនោះដែរ ។

ពេលត្រឡប់មកដល់ស្រុកខ្មែរវិញ ខ្ញុំក៏បានយកកញ្ចក់រូបថតដែលគេកាដូឱ្យនេះ ទៅប្រសិទ្ធិប្រស់ព្រំនៅវត្តចំពុះក្អែកទៀតផង ដើម្បីទុកឱ្យវាចិតនៅជារៀងរហូត កុំបែកបាក់ឱ្យសោះ គឺបានន័យថា កញ្ចក់រូបថតនេះហើយ ជានិមិត្តរូបនៃព្រលឹងស្នេហ៍របស់យើងទាំងពីរ មិនមែនដូចកញ្ចក់រូបថតខ្លះដែលបែកហើយផ្លាស់បាននោះទេ !,,, ចង់និយាយថា បើវាប្រេះបែក ក៏ទុកដូចជាសញ្ញាមិនល្អសំរាប់ជីវិតស្នេហារបស់ខ្ញុំដែរ !,,,»

ពេលនោះ ខ្ញុំដូចជាមិនចង់ឱ្យខែប្រសិទ្ធនិយាយវែងឆ្ងាយតទៅទៀត ទើបឆ្លើយកាត់ថា ÷

-«តែបើតាមអ៊ីយល់ រឿងនេះមិនគួរបារម្ភអីប៉ុន្មានទេ ព្រោះកញ្ចក់នេះ មិនមែនធ្លាក់បែកដោយឯងៗឯណា គឺវាធ្លាក់ដោយកូនប្រុសសំណាពចិត្តរបស់សិទ្ធឯង ទាញកាស្បែតប៉ះវាទេតើ !,,,»

ជួនអីពេលនោះ ខ្ញុំដូចជាពួកុមារអាយុជាង៣ឆ្នាំ ដែលចេះនិយាយបានខ្លះហើយ បន្ទឺសម្លេងឡើង ក្រោយពីសម្ងំស្តាប់ឪពុកនិយាយអស់មួយសន្ទុះធំ ÷

-«ទេប៉ា,,, កញ្ចក់នេះកូនមិនបានប៉ះទេ គឺវាធ្លាក់ខ្លួនវាទេតើ កូនគ្រាន់តែប៉ះកាស្បែតសោះ,,,ស្រាប់តែកញ្ចក់នោះធ្លាក់ឯងៗ,,,,»

ខ្ញុំនៅចាំបានថា ក្រោយដែលពួកប្រុសឆ្លើយមកវិញដូច្នោះ ខែប្រសិទ្ធក៏បាត់មាត់ឈឹង លែងពូនិយាយមកកាន់ខ្ញុំតទៅទៀត ហើយខ្ញុំក៏បិទទូរស័ព្ទ មិនហ៊ានដេញដោលសួរតទៅទៀតដែរ ។

# ៣

# ឃាតកម្មកំណាច

**មួយ**អាទិត្យក្រោយ ដោយកាន់តែចង់ដឹងថាតើប្ដីប្រពន្ធទាំងពីរមើលរឿងតែមួយ ឃើញរូបភាពខុសគ្នាយ៉ាងនេះនោះ ខ្ញុំក៏បានឆ្លៀតពេលទៅលេងផ្ទះនាងពិសិដ្ឋពាលីកាដោយផ្ទាល់តែម្ដង ។

ប៉ុន្តែ គួរឱ្យស្ដាយណាស់ ការទៅលេងដោយមិនបានសាកសួរពត៌មានជាមុននេះ ក៏មិនបានជួបអ្នកណាទាំងអស់ ក្រៅតែពីស្រីបំរើម្នាក់នោះ ដែលបាននិយាយប្រាប់ខ្ញុំ បន្ទាប់ពីបានឱ្យកាសែ្សតរឿងបុប្ផាពស់វែកមកខ្ញុំថា ÷

-«ក្មួយកាបានផ្ដាំថា បើឃើញលោកអ៊ំអញ្ជើញមក ឱ្យខ្ញុំប្រគល់កាសែ្សតរឿងនេះជូនលោកអ៊ំវិញ និងសូមទោសលោកអ៊ំផងដែលនាងមិនបានយកទៅជូនផ្ទាល់ ព្រោះប៉ុន្មានថ្ងៃនេះនាងរវល់ពេក ហើយក៏មិនហ៊ានធ្វើតាមអ្នកដទៃឱ្យយកទៅឱ្យដែរ ដោយមិនទុកចិត្ត ក្រែងគេលួចទៅចម្លងមើលបែកព្រោងព្រាត ព្រោះនាងថា រឿងលោកអ៊ំជារឿងថ្មីមិនទាន់បញ្ចាំង !...»

ខ្ញុំក៏សួរទៅវិញ ក្រោយដែលទទួលកាស្សែតនោះហើយ និងបន្ទាប់ពីបានក្រលៀសខ្សែភ្នែកទៅឃើញឡានរបស់ខែប្រសិទ្ធចតស្ងៀមនៅក្នុងរោងឡាន ÷

-«...អីចឹង អាកានិងសិទ្ធ...មិនបាននៅទេឬមីង ? »

ស្រីចំណាស់ឆ្លើយមកទៀតរបៀបរួសរាយថា ÷

-«ចាះ កូ្នយកាចេញទៅសំដែងរបាំជាមួយគណៈប្រតិភូសិល្បៈនៅប្រទេសថៃចំនួនមួយអាទិត្យ ឯកូ្នយសិទ្ធចេញទៅអូស្ត្រាលីទៀតហើយៗ ម្តងនេះប្រហែលយូរ មិនដឹងប៉ុន្មានខែត្រឡប់មកវិញទេ...?..»

ខ្ញុំក៏រពឹសមាត់សួរបន្តិចទៅទៀត ÷

-«...ចុះកូន នាងយកទៅដែរឬទុកឱ្យមីងមើល បានដូចជាស្ងាត់មាត់មិនឃើញ ?...»

ស្រីចំណាស់គ្រលៀសអណ្តាតឆ្លើយមកបន្តិចទៀត ÷

-«ឱ...កូននាង យកទៅផ្ញើនឹងប្អូនស្រីនាង ឱ្យជួយមើលខ្វះនៅពេលថ្ងៃ ឯយប់យកវាមកគេងជាមួយខ្ញុំវិញ...! »

ដូចជាអស់ហើយ ខ្ញុំប្រុងលាស្រីនោះត្រឡប់មកវិញ ប៉ុន្តែជួនអីជាភ្នែកខ្ញុំក្រលៀសទៅប៉ះនឹងវត្ថុអ្វីមួយ ដែលដាក់នៅលើតុខាងក្នុងអែបជញ្ជាំងនោះ ខ្ញុំក៏សួរទៅស្រីនោះបន្តិចទៀតថា ÷

-«...និយាយអីចឹង កាលពីអាទិត្យមុនដែលខ្ញុំនិយាយលេងជាមួយសិទ្ធតាមទូរស័ព្ទ ខ្ញុំដូចជាឮថាកូនប្រុសគេបានធ្វើឱ្យបែកកញ្ចក់រូបថតដែលសិទ្ធស្រឡាញ់បំផុតនៅលើតុនោះ ឥឡូវយ៉ាងម៉េចទៅហើយ បានស្អីយកមកធ្វើឱ្យជិតឡើងវិញទេ ?...»

ស្រីចំណាស់ សម្លឹងមើលតាមភ្នែកខ្ញុំ ទៅកាន់កញ្ចក់រូបថតនៅលើតុ ហើយនិយាយដោយញញឹមថា ÷

-«...ខ្ញុំឃើញកូនសិទ្ធ ទិញកាវវិទ្យាសាស្ត្រមកបិទភ្ជាប់គ្នាឡើងវិញ ហើយដាក់តាំងនៅលើតុនោះវិញដដែល ប៉ុន្តែទោះបីយ៉ាងណា កញ្ចក់ដែលបែកហើយ មិនអាចជិតល្អដូចដើមឡើងវិញដែរ ! តែខ្ញុំឆ្ងល់ណាស់ តាមចៅដូច ប្រកែកថាមិនបានប៉ះវាទេ គឺកញ្ចក់នោះធ្លាក់ខ្លួនឯង ! ម៉េចក៏វាចឹងទៅកើតហ្ន៎ បើវានៅខាងកណ្ដាលតុដែរ ?..»

ខ្ញុំសើចតិចៗតបវិញ ដើម្បីបញ្ចប់ការងឿងឆ្ងល់ ÷

-«...របស់អីក៏ដោយ វាមិនទៀងអីចឹងឯងមីង !... ជួនកាលយើងដាក់ស្រួលបួលហើយ ស្រាប់តែមានហេតុចៃដន្យអ្វីបន្តិច ក៏វាអាចធ្លាក់បែកបាក់បានដោយងាយ មិនចាំបាច់អ្នកណាប៉ះពាល់អីទេ !»

-«ប៉ុន្តែ ខ្ញុំឮកូនសិទ្ធនិយាយថា ពេលទៅសំដែងនៅអូស្ត្រាលីម្ដងនេះ នឹងយករូបថតទៅផ្ដិតបញ្ចូលក្នុងកញ្ចក់វ៉ាយចាន់ ដូចមុនទៀត ហើយៗប្រុងប្រយ័ត្ន មិនឱ្យបែកដូចពេលនេះទៀតទេ !..»

ꩮ ꩮ ꩮ

**ចាប់**ពីថ្ងៃនោះមក ដោយខ្វល់នឹងបញ្ហាជីវភាពពេក ខ្ញុំក៏មិនដែលបានជួបនឹងប្ដីប្រពន្ធរូបស្រស់ទាំងពីរនោះទាល់តែសោះ រហូតមកដល់ឆ្នាំ១៩៩៨ ស្រាប់តែខ្ញុំបានឮល្អិចល្អៀងតាមទស្សនាវដ្ដី និងតាមសារពត៌មានខ្លះថា ដំណើរជីវិតស្នេហារបស់ខេមរសិទ្ធនិងនាងពិសិដ្ឋពាលីកាហាក់ដូចជាមានលំអក់ពណ៌ខ្លះៗ ។

ទោះបីជាបានដឹងដូច្នេះហើយក្ដី ក៏ខ្ញុំមិនដែលយកចិត្តទុកដាក់តាមដានពត៌មាននោះឱ្យល្អិតល្អន់ដែរ ម៉្យាងខ្ញុំដូចជាមិនទាន់ជឿ ព្រោះប្ដីប្រពន្ធទាំងពីរនោះស្រឡាញ់គ្នាស្មើរចាក់ទឹកមិនលិច ហេតុអ្វីត្រូវប្រែប្រួលកើត ? ។

ទន្ទឹមនោះមានទស្សនាវដ្ដីខ្លះ ច្រើនតែចុះរឿងផ្ទាល់ខ្លួនគេមិនពិតដែរ ? ខ្លះគ្រាន់តែឮរបៀបមាត់ចាបមាត់ព្រាប ក៏យកមកបន្ថែមបន្ថយចុះផ្សាយទៅហាក់ដូចជាពិតណាស់ ក្នុងគោលបំណងដើម្បីទាក់ទាញអ្នកអាន ! លុះសាមីខ្លួនគេមិនសប្បាយចិត្ត ក៏ចាប់ផ្ដើមធ្វើការកែតំរូវ ! (sic) ។

ដោយនឹកភ្នកដល់ប្រការបែបនោះខ្លះ ទើបខ្ញុំមិនទាន់ជឿភ្លាមៗថាលលកញីឈ្មោលនោះ មានការបែកចាក់បង្អង់សោះឡើយ ។ ប៉ុន្តែគេតែងតែនិយាយចចេចចចូចពីរឿងនេះ នៅគ្រប់ច្រកល្ហករាល់តែថ្ងៃ។

នៅក្នុងពិភពសិល្បៈ រឿងល្អៗពិរោះគាប់ត្រចៀក គេហាក់ដូចជាពុំសូវចាប់អារម្មណ៍លើកយកមកនិយាយប៉ុន្មានឡើយ តែបើរឿងអាស្រូវវិញ អ្នកណាក៏ចូលចិត្តចង់ដឹងដែរ ។

ឯនៅក្នុងសង្គមមនុស្សទូទៅវិញ រឿងល្អប្រសើររបស់បុគ្គល គេមិនសូវលើកយកមកលាតត្រដាងប៉ុន្មានទេ ប៉ុន្តែបើរឿងដែលអាក្រក់ ប្លុមជូរ រលួយ ស្អុយ សំរាប់ពួកអ្នកត្រេកត្រអាលនិងចង់ដឹងរឿងគេៗឆ្ងាញ់មាត់ខ្លាំងណាស់ ។

ទោះបីយ៉ាងនេះក្ដី ក៏ខ្ញុំនៅតែឮគេនិយាយក្បែរៗត្រចៀកថាខៃប្រសិទ្ធដែលទៅអូស្ត្រាលី មានទំនាក់ទំនងជាមួយស្រីខ្មែរដែលនៅទីនោះយូរ

ហើយ រហូតដល់ថាស្រីនោះបានទិញឡានថ្មីៗឱ្យបុរសថ្លាល់ខូចពិះទៀត ផង ដើម្បីប្តូរយកសេចក្តីស្នេហាដ៏ប្រថុយប្រថាននេះ ។

គេនិយាយបន្ថែមថា ខែប្រសិទ្ធមិនបានក្បត់ចិត្តប្រពន្ធគេ ដែលទុក ដូចជារំដួលក្រុងអង្គរនោះឡើយ ។ ប៉ុន្តែ ដែលគេមានទំនាក់ទំនងជា មួយនារីថ្មីនៅអូស្ត្រាលីនោះ មកពីចង់ធ្វើយ៉ាងណាឱ្យមានភាពស្រប ច្បាប់ រស់នៅលើទឹកដីនោះតែប៉ុណ្ណោះ ។ គឺគេនៅតែមានទំនាក់ទំនង ល្អជាមួយប្រពន្ធកូនគេដែលនៅឯស្រុកខ្មែរ គ្មានប្រែប្រួលបន្តិចណា សោះ ពិសេសគឺថវិកាដែលគេរកបាន តែតែងតែផ្ញើមកឱ្យប្រពន្ធកូនគេ គ្មានដែលខកខានដែរ ។

ចំណែកពិសិដ្ឋពាលីកាឬដួងតារាសិល្បៈខ្មែរវិញ នាងបានឱ្យដឹងថា នាងនិងប្តីនាង នៅតែទូរស័ព្ទចុះឡើងរកគ្នាជាធម្មតា គ្មានអ្វីប្រែប្រួល ឡើយ ឯពាក្យដែលនិយាយថា ប្តីនាងមានស្រីញីនៅបរទេសនោះ គឺ គ្រាន់ជាពាក្យចចាមអារាមប៉ុណ្ណោះ ។

សំដីនេះ ធ្វើឱ្យខ្ញុំនឹកឃើញដល់ពាក្យមួយឃ្លា ដែលពាលីកាបាន និយាយកាលពីឆ្នាំ ១៩៩៤ ពេលថតបញ្ចប់រឿងបុប្ផាពស់វែក នៅលើ ឡានក្បែរវិមានរដ្ឋសភាថា «...ទោះបីយ៉ាងណាក៏ដៀបកប្បាសថ្លាល់ ខូចនេះ មិនបណ្តោយឱ្យផ្កាឈូកឯនាយសមុទ្រ ក្តោបទុកចោលប្រពន្ធ កូននៅទីនេះដែរ !...» ។

ប៉ុន្តែ លំហមេឃនៃជីវិតស្នេហារបស់ប្តីប្រពន្ធនេះ ហាក់ដូចជាមាន បរិយាកាសកាន់តែអួរអាប់ឡើងជានិច្ច មិនភ្លឺស្រលះដូចជាចំណងជើង ខ្សែវីដេអូមួយរឿង ដែលពិសិដ្ឋពាលីកាបានចូលរួមសំដែង ឈ្មោះថា

"មេឃស្រលះនៅក្រាំងយ៉ូវ" នោះឡើយ ។

ខ្ញុំបានមើលក្នុងទូរទស្សន៍ ដើម្បីចង់ដឹងពីការសំដែងរបស់នាងនៅក្នុងខ្សែវីដេអូរឿងនេះ ។ ថ្វីបើនាងបានបញ្ចេញទេពកោសល្យសំដែងយ៉ាងស្រគត់ស្រគុំ ក្នុងនាមជាក្រមុំជនបទដែលមានបេះដូងផូរផង់បរិសុទ្ធចំពោះគូសង្សារ និងប្រកបដោយខ្សែញញឹមឆក់ទាញយ៉ាងណាក្តី ក៏ខ្ញុំហាក់ដូចជាឃើញមានពន្លឺអាថ៌កំបាំងមួយថ្មី កប់ជ្រៅទៅក្នុងកែវភ្នែករបស់នាង ។

ពន្លឺអាថ៌កំបាំងនេះ តាមដែលខ្ញុំធ្លាប់ឃើញនាងសំដែងពីមុនៗមក មិនធ្លាប់មានទាល់តែសោះ គឺជាពន្លឺដែលឆ្លុះបញ្ចាំងឱ្យឃើញនូវស្រមោលកងទុក្ខដែលរួតរិតបេះដូងនិងភាពអត់ទ្រាំ មិនដាច់ស្រេចនៅក្នុងចិត្ត។

ទោះជាកន្ទងមក ពិសិដ្ឋពាលីកាធ្លាប់អះអាងប្រាប់គេឯងថា រូបនាងនិងប្តីនាងមិនមានការប្រេះឆាអ្វីសោះក៏ដោយ ក៏ហាក់ដូចជាមិនទាន់មានសញ្ញាណបង្ហាញឱ្យពិភពអ្នកសិល្បៈ និងសាធារណជនមានជំនឿថាបានល្អប្រសើរឡើងវិញឡើយ ។

នៅពេលនោះហើយ ដែលខ្ញុំនឹកឃើញដល់សុបិនរបស់នាងកាលពីឆ្នាំ ១៩៩៤ ដែលនាងបានបញ្ជាក់ប្រាប់ខ្ញុំថា «នាងយល់សប្តិឃើញដូចជាព្រលឹងនាង ប្តីនាង និងកូននាង បាននាំគ្នាដើរលេងយ៉ាងសប្បាយនៅលើកំពូលភ្នំមួយដ៏ខ្ពស់ ។ ពេលនោះស្រាប់តែមានព្យុះសង្ឃរា បោកបក់មកពីលើស្រទាប់ពពក ធ្វើឱ្យរូបនាង ប្តីនាង និងកូននាង បានប៉ើងរសាត់ព្រាត់បែកពីគ្នា យ៉ាងសាហាវតក់ស្លុតក្រៃលែង គឺរូបនាងបានធ្លាក់ទៅក្នុងជ្រោះជ្រៅមួយ ដែលមានសុទ្ធតែព្រលឹង

សិល្បករចាស់ៗ ដែលស្លាប់ទៅយូរៗហើយ មកឈរលើកដៃច្រូងចាំទទួល » ។...

តាមដំណើរជីវិតដែលប្រែប្រួលបែបនេះ ខ្ញុំចេះតែមមៃនឹកឃើញដល់ប្រផ្នូលចម្លែកៗ និងអព្ភូតហេតុផ្សេងៗដែលប្ដីប្រពន្ធទាំងពីរនេះ បានជួបប្រទះកន្លងមក គួបផ្សំជាមួយទេសកាលចៃដន្យដែលនាងសំដែងនៅចុងបញ្ចប់នៃរឿងបុប្ផាពស់វែករបស់ខ្ញុំទៀតផង ។

ប៉ុន្ដែអ្វីដែលធ្វើឱ្យខ្ញុំចាប់អារម្មណ៍វែងឆ្ងាយជាងគេ គឺនៅពេលណាដែលនាងឡើងច្រៀងខនសឺត ឱ្យប៉ុស្ដិ៍ទូរទស្សន៍លេខ៣ក៏ដោយ ឬក៏សំដែងនៅក្នុងចំរៀងកាយវិការផ្សេងៗក្ដី ហាក់ដូចជាមិនសូវឃើញនាងចេះច្រៀងបទណាឱ្យពិរោះដូចបទចំរៀងតែមួយប៉ុណ្ណោះ ដែលនាងច្រៀងញឹកញាប់ជាងបទណាទាំងអស់ ។

បទនោះ ទោះបីខ្ញុំមិនបានចេះនិងមិនបានចាំទុកច្រៀងឱ្យអស់ពីដើមដល់ចប់ ឬក៏ចំណងជើងមានឈ្មោះយ៉ាងណាក៏ដោយ ក៏ខ្ញុំគិតថាវាជាបទដែលមានលក្ខណៈថ្លុញថ្លែរឈឺចាប់និងអង្សរ ដែលទាក់ទងដល់ក្ដីស្នេហ៍វិយោគសោកសង្រេងយ៉ាងជ្រាលជ្រៅជាទីបំផុត ។

ការពិតបទចំរៀងដែលនាងស្រឡាញ់ ទុកដូចជាបទប្រចាំត្រកូល ឬប្រចាំជីវិតរបស់នាងនេះ មិនមែនជាបទថ្មី ដែលគេទើបតែងនៅសម័យបច្ចុប្បន្ននេះទេ ហើយមិនមែនតែខ្ញុំម្នាក់ប៉ុណ្ណោះទេ សូម្បីអ្នកដទៃដែលបានស្ដាប់ គឺស្គាល់ច្បាស់ថា បទនេះជាបទដែលមានអាយុតាំងពីមុនសម័យប៉ុលពតទៅទៀត ហើយវាជាសំនៀងពិតរបស់អ្នកនាងប៉ែនរ៉ន ដែលបានស្លាប់ទៅយូរលង់មកហើយ ។

តាមការសន្និដ្ឋានមើលទៅបទហ្នឹង បើទំនុកច្រៀងមិនមែនជាស្នាដៃរបស់លោកម៉ាឡៅពី លោកវ៉ោយហួរ លោកពៅស៊ីផូ ឬលោកស្វាយសំអឿ គឺពិតជាស្នាដៃរបស់លោកស៊ិនស៊ីសាមុតតែម្ដង ព្រោះអ្នកចំរៀងឯកនេះ មិនត្រឹមតែនិពន្ធបទសំរាប់ច្រៀងខ្លួនឯង និងទទួលបទរបស់អ្នកនិពន្ធដទៃមកច្រៀងប៉ុណ្ណោះទេ គឺគាត់ថែមទាំងបាននិពន្ធបទជាច្រើន សំរាប់ឱ្យអ្នកចំរៀងស្រីសម័យនោះច្រៀងទៀតផង ។

ការដែលគួរឱ្យរំភើបមែនទែននោះ គឺអ្នកនិពន្ធហាក់ដូចជាមើលឃើញនិងទស្សន៍ទាយត្រូវទុកជាមុនថា មិនមែនត្រឹមតែនៅក្នុងសម័យនាងប៉ែនរ៉ន ប៉ុណ្ណោះទេ ដែលមាននារីរងទុក្ខព្រោះស្នេហាដូចអត្ថន័យនៃបទចំរៀងនោះ ទោះមកដល់សម័យនេះក៏មានសិល្បការិនីរបាំ និងជាតារាវីដេអូដ៏ឆ្នើមម្នាក់ឈ្មោះនាងពិសិដ្ឋពាលីកា អាចមានទុក្ខក្នុងរឿងស្នេហាដូចគ្នានេះដែរ ។ ហើយវាហាក់ដូចជារឿងអស្ចារ្យពន់ពេក ដែលបទចំរៀងនោះបានចុចចំៗដល់គន្លឹះទ្វារជីវិតស្នេហារបស់នាង ឱ្យរបើករហាញធ្លុះធ្លាយ ហូរខ្ចាយក្លាយមកជាទឹកភ្នែកដូចបាក់ទំនប់ ។

ឃ្លាដែលធ្វើឱ្យខ្ញុំចាប់អារម្មណ៍ជាងគេនៅក្នុងចំរៀងនោះ "*គឺការថ្ងូចថ្ងូរព្រោះរលឹកប្ដីដែលឃ្លាតឆ្ងាយ ការកំសត់កម្សត់រស់នៅជាមួយកូនរហូតដល់ប្ដីរបស់ឯងសោះ គេភ្លេងថាជាប្ដីរបស់គេទៅវិញ ?*" ។

ពិតមែនហើយ ថានាងប៉ែនរ៉ន ច្រៀងបទនោះពិរោះលន្លង់លន្លោច ប៉ុន្តែនាងពិសិដ្ឋពាលីកាវិញ ហាក់ដូចច្រៀងពិរោះជាងនាងប៉ែនរ៉នទៅទៀត ដោយសារអត្ថន័យនៃចំរៀង វាធ្លុះបញ្ចាំងចំរៀងរបស់នាងពេក គឺឱ្យតែពេលណានាងឡើងច្រៀងម្ដងៗ ដំណក់ទឹកតែងតែជន់ជោរពុះ

ពោរពេញរង្វង់ភ្នែក លុះត្រាតែហូរហៀរចេញមកដោយឯងៗ ។

ក្តីឈឺចាប់ ដែលមិនអាចថ្លែងប្រាប់អ្នកណាបាន ក្រៅតែពីបង្ហូរវាឱ្យរលាយទៅតាមចំរៀងដ៏ក្តុកក្តួលរំជួលចិត្តនោះ ធ្វើឱ្យតារាសោកមុខស្នេហ៍ពាលីកា ប៉ះទង្គិចនឹងពាក្យខ្សឹបខ្សៀវពីរបែប ដែលប្រៀបដូចជាទ្រនាប់ចិតនៅក្រោមញញួរ គឺមួយគេមើលឃើញថានាងកំពុងត្រូវប្តីព្រងើយកន្តើយ និងពីរ នាងកំពុងក្លាយបណើ្តរៗជានារីដែលមានគេប៉ុនប៉ង ។

បើសិនជាមានការសង្ស័យថា នៅឯប្រទេសអូស្ត្រាលី មាននារីថ្មីម្នាក់លោតចូលមកក្នុងល្មោនជីវិតរបស់តារាថ្កាល់ខួច ក៏នៅឯប្រទេសខ្មែរ អាចនឹងមានស្រមោលបុរសថ្មីណាម្នាក់ចែងចាំងមកក្នុងឆាកជីវិតរបស់ពិសិដ្ឋពាលីកាដែរ ប៉ុន្តែ អាថ៌កំបាំងដ៏ជ្រាលជ្រៅនិងស្មុគស្មាញបំផុតនេះ មិនអាចអ្នកណាដឹងបាន ក្រៅតែពីបេះដូងរបស់ប្តីប្រពន្ធទាំងពីរនេះឡើយ ។

ៜ ៜ ៜ

**ផុត**ឆ្នាំ ១៩៩៨ ចូលឆ្នាំ ១៩៩៩ ទស្សនាវដ្តីខ្លះនៅតែផ្សាយបន្តពីការរង្គោះរង្គើបង្គងស្នេហ៍រវាងខែប្រសិទ្ធ និងពិសិដ្ឋពាលីកា ហើយរឿងរ៉ាវទាំងឡាយនោះ ហាក់ដូចចិតក្នុងភាពស្រពិចស្រពិល មិនសូវជាច្បាស់លាស់ប៉ុន្មានឡើយ ។

រហូតដល់ពេលមួយនោះ គេបានដឹងថា ខែប្រសិទ្ធបានត្រឡប់មកជាន់ដីស្រុកខ្មែរ បានតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ក៏ឡើងយន្តហោះត្រឡប់ទៅ

អូស្ត្រាលីវិញភ្លាម បន្ទាប់ពីមានរឿងទំនាស់រកាំរកូសជាមួយគ្រួសាររបស់ពិសិដ្ឋពាលីកា ។

ពេលនោះ ខ្ញុំដូចជាមានទឹកចិត្តស្រងេះស្រងោចខ្លោចផ្សា អាណិតដល់តារាផ្កាល់ខ្លួចខ្លាំងណាស់ដែរ ព្រោះមើលទៅរូបថតដែលគេចុះផ្សាយក្នុងទស្សនាវដ្ដី ឃើញមានទុកពុកមាត់ស្រមេមស្រមូម និងលក្ខណៈស្លៀកពាក់ហាក់ដូចមិនមែនខ្មែរ ខុសឆ្ងាយពីប៉ុន្មានឆ្នាំមុន កាលថតរឿងអូជាមួយខ្ញុំ ។

ខ្ញុំគិតថា បើបរិយាកាសជីវិតប្ដីប្រពន្ធរបស់គេមានភាពអាប់អួរយ៉ាងនេះ បន្ទាប់ពីត្រឡប់ទៅប្រទេសអូស្ត្រាលីវិញ ខៃប្រសិទ្ធប្រហែលជាលែងមានវាសនាបានត្រឡប់មកជាន់ដីស្រុកខ្មែរ ឬបានមកឃើញមុខប្រពន្ធជាទីស្រឡាញ់និងកូនកំសត់ដែលមុខដូចនោះទៀតហើយ ?។..

ខ្ញុំនៅចាំបានថា កាលក្នុងអំឡុងត្រីមាសទី១ ទី២ នៃឆ្នាំ១៩៩៩នោះដែរ ក្រុមហ៊ុន **MILD SEVEN** បានទាក់ទងខ្ញុំ ឱ្យទៅជួយធ្វើជាប្រធានគណៈមេប្រយោគសំរាប់ឱ្យពិន្ទុ ក្នុងវេទិកាប្រលងចំរៀងការ៉ាអូខេមហាជនមួយ ដែលដំណើរការប្រព្រឹត្តទៅ៥ខេត្តជាបន្តបន្ទាប់គ្នា គឺកំពង់ធំ កំពង់សោម បាត់ដំបង សៀមរាប និងកំពង់ចាម ។

ដោយមានការរវល់ដូច្នោះ ខ្ញុំហាក់ដូចជាមិនសូវបានតាមដានសភាពការណ៍ថ្មីៗ សំរាប់ជីវិតស្នេហារអាក់រអួលរបស់តារារូបស្រស់ទាំងពីរនោះទៀតឡើយ ហើយសារពត៌មាននិងទស្សនាវដ្ដីនានា ក៏ហាក់ដូចជាលែងមានពត៌មានអ្វីប្លែកពីរឿងនេះចុះផ្សាយទៀតដែរ ។

បន្ទាប់ពីបានចុះបំពេញការងារចប់សព្វគ្រប់សំរាប់ខេត្ត៤ហើយ ខ្ញុំក៏

ត្រឡប់ចូលភ្នំពេញវិញ ហើយបានសំរាកនៅផ្ទះមួយរយៈខ្លី ដើម្បីរង់ចាំចេញដំណើរទៅខេត្តកំពង់ចាមទៀត ដែលជាខេត្តចុងក្រោយគេ ហើយដែលនឹងត្រូវចាប់ធ្វើនៅថ្ងៃទី៩ ទី១០ និងទី១១ ខែកក្កដាឆ្នាំ១៩៩៩ ជាកំណត់ ។

ថ្ងៃទី៦កក្កដាឆ្នាំដដែលនោះហើយ ដែលជាថ្ងៃកក្រើករញ្ជួយ លើទំព័រប្រវត្តិសាស្ត្រសិល្បករខ្មែរយ៉ាងខ្លាំងក្លាបំផុត ។

ថ្ងៃនោះ ខ្ញុំងើបពីដេកឡើង សរសៃរអ្វីមិនចេញសោះ ហាក់ដូចជារសាប់រសល់ប្លែកក្នុងខ្លួន ហើយបណ្ដាលចិត្តចង់ចាក់កាសែ្សតរឿងបុប្ផាពស់វែក មើលឡើងគ្រាន់កែអផ្សុក ។

ទើបខ្ញុំទាញយកកាសែ្សតចម្លងមួយពីក្នុងថតទូ ឯកាសែ្សតMASTER ដើមបំផុត ខ្ញុំបានប្រគល់ឱ្យទូរទស្សន៍មួយទុកបញ្ចាំងទៅហើយ ។

ខ្ញុំចាក់មើលម្នាក់ឯងក្នុងបន្ទប់ មិនទាន់ទាំងចប់ស្រួលបួលផងស្រាប់តែទន់ភ្នែករាងងងុយដេក ហើយមនោរម្មណ៍ដូចជារអណ្ដែតចេញផុតពីខ្លួន រសាត់យោលយោកទៅតាមសំនៀងបទចំរៀង ដែលប្រគុំបន្ទរកំដររធាក់នាងបុប្ផាពស់វែក ត្រូវរាហ៊ូបីដើរយឺតៗទៅកាន់រណ្ដៅជ្រោះភ្លើង ។

ជួនជាពេលដែលខ្ញុំលង់លក់មួយភាំងដូចត្រូវមន្តសណ្ដំនោះ វីដេអូក៏មកដល់ត្រឹមរូបដែលទេពវិន្ទដារ៉ូ បោះនាងពិសិដ្ឋពាលីកាទៅក្នុងរណ្ដៅភ្លើងលួម ហើយក៏ស្ទើគ្មានឹងស្នូរកាំភ្លើងលាន់ឮឡើងបីបួនគ្រាប់ជួនៗគ្នា នៅមិនឆ្ងាយប៉ុន្មាន ។

ខ្ញុំស្វាងងងុយអស់រលីង ហើយចុចបិទវីដេអូភ្លាម ក្រោយដែលឮ

សួរអ្នកផ្ទះជិតខាងជជែករសិបរសាវដោយភ្ញាក់ផ្អើលថា មានមនុស្សត្រូវគេបាញ់នៅច្រកក្បែររោងកុនប្រាសាទពេជ្រ ជិតផ្សារអូរឫស្សី ។

តាមការពិតផ្ទះខ្ញុំ ក៏មិននៅឆ្ងាយពីទីកើតហេតុប៉ុន្មានដែរ គឺនៅក្បែរក្រសួងវប្បធម៌និងវិចិត្រសិល្បៈចាស់ ដែលគ្រាន់តែឆ្លងផ្លូវទៅខាងមុខបន្តិចប៉ុណ្ណោះ ក៏ដល់កន្លែងកើតហេតុ ។

ប្រមាណជាមួយរដង្ហើមរំលងទៅទៀត ស្រាប់តែមានសម្លេងមួយថ្មីរត់មកប៉ះត្រចៀកខ្ញុំ ធ្វើឱ្យខ្ញុំស្ទុតវិញ្ញាណស្ទើរដួលទាំងជំហរគឺ ÷

-«គេបាញ់ពិសិដ្ឋពាលីកា !... ពិសិដ្ឋពាលីកាត្រូវគេបាញ់ !..»

អ្នកដែលនិយាយនោះ គឺប្រពន្ធខ្ញុំ ដែលទើបត្រឡប់មកពីផ្សារអូរឫស្សីវិញ ។

ខ្ញុំក៏ដេញសួរទៅភ្លាម ដោយអន្ទះអន្ទែង

-«គេបាញ់ពិសិដ្ឋពាលីកា ! ឯងបានឃើញច្បាស់ផ្ទាល់ភ្នែក... ឬ....ទេ ?...»

ប្រពន្ធខ្ញុំឆ្លើយទាំងទឹកមុខស្លាំងស្លេក ប្រាប់ខ្ញុំនិងកូនចៅដែលស្ទុះចូលមកដោយភ័យច្រួលច្របល់ ÷

-«....ខ្ញុំមិនបានឃើញនឹងភ្នែកទេ តែខ្ញុំបានជិះស៊ីក្លូមកពីផ្សារតាមផ្លូវក្បែរកន្លែងដែលកើតហេតុនោះ ឃើញមនុស្សចោមរោមអ៊ូអែរមើលស្នាមឈាម ហើយគេនិយាយត្រប់មាត់ថា ពាលីកាតារាវីដេអូត្រូវគេបាញ់... នៅក្បែរឡានរបស់នាង ឥឡូវគេដឹកយកទៅពេទ្យផុតហើយ !»

ខ្ញុំចាប់ផ្តើមមានអាការៈភ័យញ័រចំប្រប់ បេះដូងដើរស្ទើរខុសចង្វាក់ហើយនៅតែដេញសួរបញ្ជាក់ប្រពន្ធខ្ញុំទៀតថា ÷

-«នែ៎ ក្រែងឯងឮច្រឡំទេដឹង !... ខ្ញុំដូចមិនជឿសោះ តើពាលីមានរឿងអី បានជាគេបាញ់នោះ...?...»

ប្រពន្ធខ្ញុំ ខំទប់ដង្ហើមហត់ដង្ហក់ ហើយបញ្ជាក់សាជាថ្មី ÷

-«ចុះអ្នកណាទៅដឹង ថាមានរឿងអី ប៉ុន្តែគេនិយាយថា ពិសិដ្ឋ ពាលីកា តារាវីដេអូ តើមានអ្នកណាទៀត ? ប្រាកដជាពាលីហើយ... ពុទ្ធោ !... ខ្ញុំចង់ខ្យល់គហើយ គ្រាន់តែឮប៉ុណ្ណឹង ?...»

ខ្ញុំទាញទូរស័ព្ទប្រុងសួរបញ្ជាក់ទៅកូនប្រសារខ្ញុំ ដែលមានផ្ទះនៅមិនឆ្ងាយប៉ុន្មានពីទីនោះ ប៉ុន្តែមិនទាន់បានចុចលេខផង ស្នូរឡានក៏បានមកឈប់នៅមុខផ្ទះភ្លាម ហើយកូនប្រសារខ្ញុំក៏បានឡើងមកប្រាប់ទាំងទឹកមុខស្រពោនថា ÷

-«...ពាលីកា ត្រូវគេបាញ់ហើយប៉ា !.... ឥឡូវគេដឹកយកទៅពេទ្យកាល់ម៉ែត្រហើយ !...»

ដោយខ្ញុំ ធ្លាប់ជាមនុស្សខ្សោយបេះដូងស្រាប់ គ្រាន់តែឮដំណឹងបញ្ជាក់បន្ថែមនេះពេលណា អាការៈក្នុងខ្លួនហាក់ដូចជាប្រែប្រួលត្រជាក់ស្រៀវយ៉ាងម៉េច មិនដឹងទេ នៅទន្ទឹមនឹងឃ្លាប្រពន្ធ ។ ខ្ញុំសួរទៅកាន់កូនប្រសារទៀតថា ÷

-«...តើកូនមានដឹងថា នាងមានរឿងអី បានជាត្រូវគេបាញ់ទាំងកណ្តាលថ្ងៃ....យ៉ាង...នេះ ?...»

កូនប្រសារខ្ញុំ ញញឹមស្ងួត គ្រវីក្បាលយឺតៗ និយាយតិចៗរបៀបជាអស់សង្ឃឹម ÷

-«...រឿងនេះ ប្រាកដជាមានអាថ៌កំបាំងវែងឆ្ងាយហើយម៉ាក់ !...

តែបើស្តាប់ពាក្យមនុស្សនិយាយ,,,មួយពាន់នាក់ ខុសគ្នាទាំងមួយពាន់ ! ខ្ញុំទៅពេទ្យកាល់ម៉ែត្រមើលនាងសិន តើប៉ាម៉ាក់ទៅជាមួយខ្ញុំ,,,ទេ ?»

ប្រពន្ធខ្ញុំប្រកែក ÷

-«,,,ទៅជាមួយប៉ាមុនចុះ ! ក្រែងរឹករវល់យ៉ាងនេះ គេមិនទាន់ឱ្យចូលណាំ !,,,»

ខ្ញុំក៏ឆ្លើយកាត់បន្តទៀត ÷

-«,,,,កូនទៅស្ទង់សភាពការណ៍សិនមើល៍ ព្រោះប៉ាដូចជាល្ហិល្ហាក់,,,, មិនស្រួលខ្លួនសោះ !,,,»

,,,,មួយម៉ោងក្រោយមក កូនប្រសារខ្ញុំត្រឡប់មកវិញ ហើយនាំពត៌មានមកប្រាប់បន្ថែមថា ÷

-«,,,ពាលី កំពុងស្ថិតនៅក្នុងបន្ទប់សង្គ្រោះបន្ទាន់ពិសេស ហើយគ្រូពេទ្យជំនាញច្រើននាក់ កំពុងប្រតិបត្តិការវះកាត់យកគ្រាប់ចេញពីខ្លួននាងច្រើនគ្រាប់ ដែលសុទ្ធតែប៉ះកន្លែងធ្ងន់ៗបំផុត !,,,»

ខ្ញុំដកដង្ហើមធំ ចង្អៀតណែនទ្រូងនិយាយមិនចេញ កូនប្រសារខ្ញុំបញ្ជាក់បន្ថែមថា ÷

-«,,,តាមពាក្យរបស់ប្អូនថ្លៃពាលី ហើយជាអ្នកបានជួបហេតុការណ៍ផ្ទាល់ ថាគេបានបើកឡានជូននាងទៅរកមើលទិញកូនកង់ឱ្យក្មួយស្រីម្នាក់ ដែលបានជិះទៅជាមួយដែរ !,,, ពេលទៅដល់កន្លែងលក់កង់ម៉ុំខាងក្រោយរោងកុនប្រាសាទពេជ្រ នាងបានបើកទ្វារឡានចុះដោយមិនដឹងខ្លួន ដឹកដៃក្មួយទៅសួរមើលទិញកូនកង់ ហើយដើរត្រឡប់មករកឡានវិញ ។ ពេលដែលនាងដើរឃ្លាតពីក្មួយស្រីបន្តិច ឃាតករម្នាក់

ដែលមិនដឹងជាលបចេញពីជ្រុងណាមួយមក ពាក់មួកសុវត្ថិភាព បាន លើកកាំភ្លើងបាញ់នាងជាច្រើនគ្រាប់ ហើយរត់យ៉ាងលឿនទៅជិះពីក្រោយម៉ូតូមួយដែលបញ្ឆេះចាំជាស្រេច ហើយបើករត់គេចទៅបាត់ស្រមោល ដែលគ្មានឧបសគ្គអ្វីមករារាំងពីមុខឡើយ !...»

ខ្ញុំកាន់តែល្វិតមុខមែនទែន នៅពេលដែលបានទទួលដំណឹងនោះបន្ត ហើយប្រពន្ធខ្ញុំក៏ថ្ងូរទាំងសោកស្តាយ ÷

-«....មើលទៅ របួសនោះធ្ងន់ណាស់.... ទៅ ឬកូន ?...»

-«បើតាមពាក្យរបស់ប្អូនថ្លៃថា នាងរបួសធ្ងន់និយាយបានតែពីរបីម៉ាត់តែប៉ុណ្ណោះ ពេលដឹកយកទៅពេទ្យ ហើយក៏សន្លប់បាត់ស្មារតីរហូត ប៉ុន្តែបានផុតទីរជំនាញធំៗជួយវះកាត់ នាងប្រហែលជាឆ្លងរួចពី....»

ខ្ញុំឃើញប្រពន្ធកូនខ្ញុំ លើកដៃប្រណម្យឡើងទៅលើ ដោយថ្ងូរបួងសួងគ្រប់គ្នា សូមឱ្យពាលីកា ឆ្លងរួចពីគ្រោះថ្នាក់ ÷

-«ពេលបាញ់នោះ....» កូនប្រសារខ្ញុំនិយាយបន្ថែម «...ថាត្រូវទាំងក្មួយស្រីនោះខ្វះដែរ តែរបួសស្រាល...! គិតទៅឃាតករនេះសាហាវណាស់ !...»

ខ្ញុំទាញយកប្រេងខ្យល់មកញីលាបមុខមាត់ ហើយពោលតិចៗ ÷

-«...ថ្ងៃនេះ ប៉ាដូចជារសាប់រសល់ចម្លែកណាស់ នៅមិននៅទៅទាញយករឿងបុប្ផាពស់វែកមកចាក់មើល ស្រាប់តែដល់ត្រង់កន្លែងដែលរាហ៊ូចាប់បោះនាងបុប្ផាពស់វែកទៅក្នុងរណ្តៅភ្លើង ប៉ាបែរជាលង់លក់មួយភាំងដូចត្រូវមន្តសណ្តំ តែក៏ភ្ញាក់ភ្ញាក់កន្ត្រាក់ឡើងវិញ នៅពេលដែល

ឮស្នូរកាំភ្លើងផ្ទុះឡើង,,,»

-«,,,យី ម៉េចក៏ស្របពេលគ្នាម៉្លេះ ឪវ៉ា,,,,? »

ប្រពន្ធខ្ញុំបន្ទឺឡើងដោយកែវភ្នែកអាថ៌កំបាំង តែខ្ញុំប្រញាប់និយាយបន្ទប់ ដើម្បីកុំឱ្យយកចិត្តទុកដាក់ដល់រឿងដែលមិនគួរជឿ ទើបបែរទៅសួរកូនប្រសារខ្ញុំទៀតថា ÷

-«ចុះមុនពេលនឹងសន្ធប់នោះ នាងនិយាយថាដូចម្ដេចខ្លះទៅ ប្អូនថ្លៃនាងមានស្ដាប់បានខ្លះទេ ?,,,»

-«បាទ !,,, គឺគេប្រាប់ថា នាងនិយាយតែពាក្យដដែលៗបានពីរបីម៉ាត់ថា "ហេតុអ្វីបានជាបាញ់ខ្ញុំ តើខ្ញុំខុសអី ?,,,។ !,,»

ក្រោយដែលឮសំដីនេះ ខ្ញុំ ប្រពន្ធខ្ញុំ និងកូនចៅកាន់តែមានចិត្តខ្លោចផ្សាអាណិតនាងពិសិដ្ឋពាលីកាទ្វេឡើង ហើយមានទឹកភ្នែករលេងរលោងចង់យំព្រមគ្នា ។

ទ្រាំមិនបាន រសៀលនេះប្រមាណជាម៉ោង ៤ល្ងាច ខ្ញុំក៏បានឱ្យកូនប្រសារជូនទៅពេទ្យកាល់ម៉ែត្រ ដើម្បីចង់ដឹងពីស្ថានភាពរបួសរបស់តារាអភ័ព្វនោះ ។

គួរឱ្យភ្ញាក់ផ្អើលអ្វីម៉្លេះ ពេលដែលទៅដល់ខ្ញុំឃើញមនុស្សម្នា នៅកកកុញពីមុខមាត់ទ្វារមន្ទីរពេទ្យ មានប្រុសស្រីចាស់ក្មេង មិនដឹងអ្នកណាជាអ្នកណា លាយឡំដោយពួកអ្នកធាក់ស៊ីក្លូ ម៉ូតូឌុប ដែលសុទ្ធតែមានទឹកមុខស្រពាប់ស្រពោនខ្លោចផ្សាអន្ទះសាចង់ដឹងគ្រប់គ្នា ។

ទិដ្ឋភាពទាំងនេះ ហាក់ដូចជាមហាបាតុកម្មដ៏រញ្ជួយចិត្តមួយ ហើយនៅពេលដែលខ្ញុំចូលជ្រៅទៅក្នុងជួរល្វែងនៃសាលសង្គ្រោះបន្ទាន់ ខ្ញុំបាន

ជួបប្រទះសុទ្ធតែពួកសិល្បករ សិល្បការិនី នៅណែនណាន់តាន់តាប់ រកតែផ្លូវដើរស្ទើរតែមិនរួច ។

ពេលនោះខ្ញុំហាក់ដូចជាមិនបាននិយាយរកអ្នកណាម្នាក់ឡើយ ហើយអ្នកទាំងនោះ ក៏ទំនងជាមិនសូវចង់និយាយរកគ្នាប៉ុន្មានដែរ ក្រៅតែពីមានអាការៈត្រហេបត្រហប ដោយខំប្រឹងសម្លឹងចង់ឃើញអ្នកជម្ងឺដែលគេដាក់នៅក្នុងសាលតែប៉ុណ្ណោះ ។

ខ្ញុំគិតថាពេលនោះ ប្រហែលជាមិនបានឃើញតួនាងបុប្ផាពស់វែកទេ ព្រោះទ្វារបន្ទប់បិទជិត ដោយមានអ្នកយាមពីក្រៅយ៉ាងប្រុងប្រយ័ត្ន ទោះជាពួកសិល្បករ-សិល្បការិនីទាំងនោះ ប្រជ្រៀតគ្នានៅកៀកជាប់នឹងទ្វារយ៉ាងណាក៏ដោយ ។

ប៉ុន្តែ នៅពេលដែលខ្ញុំកំពុងអើតឆ្វេងអើតស្តាំដោយក្តីអន្ទះអន្ទែងនោះ ស្រាប់តែមានគ្រូពេទ្យស្រីម្នាក់បើកទ្វារចូលទៅ ស្របនឹងពេលដែលគ្រូពេទ្យប្រុសម្នាក់ចេញមកដែរ ។

ប្រហែលជាប៉ុន្មានវិនាទី ដែលសន្លឹកទ្វារបើកចំហរនេះ ខ្ញុំនិងកូនប្រសារខ្ញុំដែលនៅកៀកមាត់ទ្វារជាងគេបំផុត ក៏បានចោលភ្នែកទៅក្នុងបន្ទប់ ឃើញពិសិដ្ឋពាលីកា ដេកស្ងៀមនៅលើគ្រែ ដោយមានដាក់ប្រដាប់អុកស៊ីហ្សែនជាប់ច្រមុះ និងខ្សែបន្តោងសេរ៉ូមខ្វាត់ខ្វែង ។

ខ្ញុំមើលបានតែប៉ុណ្ណោះ ទ្វារបន្ទប់ក៏បិទវិញ ធ្វើឱ្យខ្ញុំអស់សង្ឃឹមហើយនាំគ្នាប្រជ្រៀតមកឈរនៅល្វែងខាងក្រៅវិញ ដើម្បីស្រូបយកខ្យល់ឱ្យបានធូរស្បើយពីបរិយាកាសអ៊ូអរអាប់ ។

នៅពេលនោះ ខ្ញុំបានជួបនឹងឪពុកមាពិសិដ្ឋពាលីកា ដែលលោក

បានបង្អើបប្រាប់ខ្ញុំទាំងក្រៀមក្រំថា ÷

-«...ក្រោយពីវះយកក្រាប់ហើយ នាងសន្លប់រហូត តែគ្រូពេទ្យបានប្រាប់ថា នាងអាចនឹងដឹងខ្លួនឡើងវិញ !...»

ខ្ញុំបានឱ្យបសួរបន្តិចទៀត ក្រែងលោកបានដឹងអ្វីខ្លះ ពីមូលហេតុនៃឃាតកម្មដ៏កំណាចនេះ តែលោកគ្រវីក្បាលយឺតៗដោយទឹកមុខស្ងួតស្ងប់នៅទន្ទឹមនឹងពេលនោះ ពាក្យចចាមអារាមផ្សេងៗក៏បានលាន់ឮទ្រហឹងជុំទិស ។

ខ្ញុំជិះឡានត្រឡប់មកវិញជាមួយកូនប្រសារ ដោយនិយាយខ្លះៗថា÷

-«យើងគ្រាន់តែមានសេចក្ដីសោករន្ធត់អាណិតនាងប៉ុណ្ណោះ តែមិនអាចបកស្រាយមុខមាត់ឃាតកម្មនេះ មុនអាជ្ញាធរមានសមត្ថកិច្ចបានឡើយ !... ហើយក៏មិនមែនជាមុខនាទីរបស់យើងផង !... សូមឱ្យជីវិតនាងគង់នៅ ដើម្បីបញ្ចប់នូវភាពស្រពិចស្រពិលនេះ !...»

# ៤

# វិលវិញណាំបង !

**ស្នេហ**ឡើង កាសែតចុះផ្សាយព្រោងព្រាតពីដំណឹងឃាតកម្មលើរូបតារាឯកពិសិដ្ឋពាលីកា បន្ថែមពីលើពត៌មានរបស់វិទ្យុនិងទូរទស្សន៍នានាដែលផ្សាយកាលពីក្បាលព្រលប់ ។

ឯប្រជាជនគ្រប់ស្រទាប់វណ្ណៈ នាំគ្នាផ្អើលទៅចោមរោមកកកុញមុខមន្ទីរពេទ្យកាន់តែច្រើនឡើងៗ ដើម្បីចង់ដឹងឱ្យបានផ្ទាល់ តើនាងស្លាប់ឬក៏អាចរួចរស់ជីវិត ? ។

មិនចំពោះតែប្រជាជនដែលរស់នៅក្នុងក្រុងភ្នំពេញ ឬខេត្តជិតៗប៉ុណ្ណោះទេ សូម្បីតែអ្នកនៅខេត្តឆ្ងាយៗដូចជាក្រុងកំពង់សោម ឬរហូតដល់ខេត្តជាប់ព្រំដែនថៃ ក៏នាំគ្នាស្រវាស្រទេញ ធ្វើដំណើរមកពីគ្រប់ទិសគ្រប់តំបន់ ដោយគ្មានគិតខ្វាចនឿយហត់សោះឡើយ ។

ពួកគេប៉ងប្រាថ្នាចង់ឃើញនាងពិសិដ្ឋពាលីកា ទោះជានាងស្លាប់ឬរស់យ៉ាងណាក៏ដោយ ឱ្យតែបានឃើញមុខផ្ទាល់បន្តិចក៏អស់ចិត្តដែរ ។ ខ្លះបានជេរប្រទេចផ្តន្ទាចំពោះឃាតករ ខ្លះទៀតអង្វរបន់ព្រះសំពះទេវតាសុំកុំឱ្យនាងស្លាប់ ដើម្បីចង់ដឹងពីមូលហេតុពិតនៃឃាតកម្មនេះ ព្រោះ

គេគ្រប់គ្នាគិតថា បើសិនជានាងស្លាប់ អ្វីៗដែលជាធាតុពិតនៃអំពើកំណាចព្រៃផ្សៃនេះ នឹងត្រូវកប់រលាយបាត់ទៅជាមួយផ្សែងភ្លើងដែលហុយចេញពីចាំឆាដុតរូបនាង ឬក៏ទៅចិតនៅក្នុងផ្នូរដីអាថ៌កំបាំងមួយដែលគ្មានអ្នកណាអាចដឹងបានទាល់តែសោះ ។

ព្រឹត្តិការណ៍ក្ដុកក្ដួលពុះកញ្ជ្រោលដូចរលកព្យុះសង្ឃរានេះ បញ្ជាក់ឱ្យឃើញថា ពិសិដ្ឋពាលីកាមានគេស្រឡាញ់រាប់អានច្រើន ព្រោះនាងមិនត្រឹមតែជាតារាវីដេអូសម្បូរណ៍ស្នេហ៍ និងពេញដោយទេព្យកោសល្យប៉ុណ្ណោះទេ គឺនាងថែមទាំងជាសាស្ត្រាចារ្យរបាំដ៏សុភាពរាបសារទន់ភ្លន់ និងជានាយរោងដ៏ឆ្នើមប្រចាំក្រុមរបាំបូរាណនេះទៀតផង ។

ស្អែកឡើងទៀត គឺថ្ងៃ៨កក្កដា១៩៩៩ ដំណឹងថាពិសិដ្ឋពាលីកានៅតែមិនទាន់ដឹងខ្លួននោះ កំពុងចិតនៅជាពតីមានដ៏គួរឱ្យព្រួយបារម្ភបំផុត ធ្វើឱ្យខ្ញុំអន្ទះអន្ទែងពេក ទើបរសៀលល្ងាចនោះ ខ្ញុំឱ្យកូនប្រសារខ្ញុំជូនទៅពេទ្យកាល់ម៉ែត្រទៀត ។

ដូចជាថ្ងៃទី១និងទី២ដែរ មនុស្សម្នានៅតែប្រជ្រៀតគ្នាកកស្រទាប់មុខមន្ទីរពេទ្យ ពិសេសនៅតាមផ្លូវល្វែងបន្ទប់ដែលពាលីកាសំរាក និងនៅក្នុងបរិវេណសួនច្បារចង្អៀតណែនទៅដោយពួកតារា សិល្បករសិល្បការិនី និងសិស្សសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ខ្វះឈរ ខ្វះអង្គុយ នៅពាសពេញត្រៀបត្រា ក្នុងអាការៈអន្ទះអន្ទែង ហាក់ដូចជារង់ចាំទទួលពតីមានអ្វីមួយដ៏សំខាន់បំផុត ។

មែន ! តាមខ្ញុំសាកសួរគេឯងទៅ គឺនៅម៉ោង៥កន្ទះល្ងាចនេះលោកគ្រូពេទ្យជំនាញម្នាក់ និងចេញមកជូនពតីមានដល់អ្នករាល់គ្នា

ដែលរង់ចាំនោះ ពីអាការៈជម្ងឺរបស់ពាលិកា តើមានសង្ឃឹមឬក៏អត់ បើនាងនៅតែដេកស្តូកស្តឹងឥតកំរើកអ្វីយ៉ាងនោះ ? ។

ខ្ញុំគ្រាន់តែបានឃើញនាងម្តងទៀតពីចម្ងាយ តាមចន្លោះសន្លឹកទ្វារ ដែលគ្រូពេទ្យម្នាក់បើកចូល តែក៏ហាក់ដូចជាគ្មានសញ្ញាណាថាពាលិកា នឹងបានធូរស្រាលវិញងាយៗឡើយ ព្រោះនាងមិនអាចដកដង្ហើមខ្លួនឯងបាន ក្រៅតែពីពឹងលើឧបករណ៍អុកស៊ីហ្សែនប៉ុណ្ណោះ ។

ប៉ុន្តែ ដោយសារចង់ដឹងពត៌មានសំខាន់នោះដែរ ខ្ញុំនិងកូនប្រសារខ្ញុំនៅឈររេរ៉ េ និយាយលេងជាមួយមិត្តភ័ក្តិខ្លះ ដែលឈរចាំនៅទីនោះរហូតដល់ម៉ោង៦គត់ ក៏មិនឃើញមានអ្នកណាម្នាក់ចេញមកប្រាប់ពីរឿងអ្វីដែរ ដោយប្រហែលជាលោកគ្រូពេទ្យកំពុងរង់ចាំធ្វើការវិភាគពីអាការៈរោគរបស់អ្នកជម្ងឺឱ្យបានច្បាស់លាស់ ។

...ស្អែកឡើង ថ្ងៃទី៩កក្កដាឆ្នាំ១៩៩៩ ខ្ញុំត្រូវចេញដំណើរទៅខេត្តកំពង់ចាម ដើម្បីចូលរួមធ្វើប្រធានគណៈមេប្រយោគក្នុងវេទិកាប្រឡងចំរៀងការ៉ាអូខេមហាជនឱ្យក្រុមហ៊ុន **MILD SEVEN** ចំនួនបីថ្ងៃបន្តទៀតជាការបញ្ចប់ភារកិច្ច ។

ពេលទៅដល់សណ្ឋាគារដែលត្រូវសំរាក ខ្ញុំបានប្រទះឃើញកាសែតមួយ ដែលនាំយកពីភ្នំពេញទៅលក់នៅថ្ងៃនោះ បានចុះផ្សាយដំណឹងថាពិសិដ្ឋពាលិកា បានផុតជីវិតលាចាកលោកនេះទៅហើយ ។

ខ្ញុំស្លុតចិត្តអាណិតនាង ស្ទើរតែធ្វើការឱ្យគេមិនកើតនៅថ្ងៃនោះ ប៉ុន្តែប្លែកត្រង់យប់នោះ ទោះក្រៀមក្រំរសាប់រសល់បែបណាក៏ដោយ ក៏ខ្ញុំហាក់ដូចជាពុំមានយល់សប្តិឃើញអ្វីដែរ ។

លុះស្អែកឡើង ពេលជិតថ្ងៃត្រង់ ខ្ញុំបានទទួលដំណឹងពីពួកអ្នកបំរើសណ្ឋាគារនៅទីនោះ និយាយដោយភ្ញាក់ផ្អើលវិញថា ពិសិដ្ឋពាលីកាមិនទាន់ស្លាប់ទេ តីទូរទស្សន៍ប៉ុស្តិ៍លេខ៣បានផ្សាយ រួមទាំងវិទ្យុមួយទៀតផង ។

ដំណឹងនេះ ធ្វើឱ្យខ្ញុំដូចជាមានសង្ឃឹមឡើងវិញ ហើយហាក់ដូចជាមានអ្វីមកខ្សិបប្រាប់បន្ថែមថា "ដួងតារាដ៏ភ្លឺថ្លាអមតៈនេះ ពិតជាមិនរលត់ចោលផ្ទៃមេឃសិល្បៈវប្បធម៌របស់ខ្មែរជាដាច់ខាត !" ។ ដោយក្តីនឹកភ្នកពន្លកសង្ឃឹមនេះហើយ ទើបធ្វើឱ្យខ្ញុំមានកំលាំងចិត្ត និយាយទៅកាន់លោក នូស៊ិប និងប្អូន សានផានិត ដែលបានទៅរួមការងារធ្វើគណៈមេប្រយោគជាមួយខ្ញុំក្នុងពេលនោះដែរថា ÷

-« ស៊ិប,,, យល់យ៉ាងណាដែរ ខ្ញុំថាពាលីកា មិនស្លាប់ទេណាំ ?»

អ្នកចំរៀងវ័យចំណាស់មកពីទឹកដីដ៏រជាន់ខ្វា ឆ្លើយតបមកវិញដោយទឹកមុខហាក់ដូចមិនភ្ញាក់ផ្អើលប៉ុន្មាន ÷

-«,,, ខ្ញុំក៏យល់ថាយ៉ាងនេះដែរបង ព្រោះបើម៉េចៗ វាតាំងពីថ្ងៃដំបូងទៅហើយ ឥលូវ ចូលដល់ថ្ងៃទី៥,,, នាងនៅតែមានដង្ហើមនៅឡើយ !,,,»

ពេលនោះ ម្ចាស់បទ "ទូរស័ព្ទប្រាប់ផង" បានបន្ទឺតិចៗមកកាន់ខ្ញុំដែរ ÷

-«,,, មានកូនសិស្សរៀនអង់គ្លេសជាមួយខ្ញុំម្នាក់ បានតេពីភ្នំពេញមកប្រាប់ខ្ញុំមុននេះបន្តិចថា បងកាមិនទាន់ស្លាប់មែន តែដង្ហើមរបស់គាត់ពឹងទាំងស្រុងតែលើអុកស៊ីហ្សែនប៉ុណ្ណោះ ហើយពួកវេជ្ជបណ្ឌិត

ហាក់ដូចមិនទាន់ហ៊ានសាកល្បងដកអុកស៊ីហ្សែននេះចេញនៅឡើយ !»

-«តែ... ទោះបីយ៉ាងណា !...» ខ្ញុំពោលបន្ថែម «...ក៏ដោយសារការបន់ស្រន់បួងសួងរបស់បងប្អូនប្រជាជន និងពួកសិល្បករ-សិល្បការិនីទាំងអស់ជាកំលាំងចិត្ត ជីវិតរបស់នាងប្រាកដជាឆ្លងផុតពីគ្រោះថ្នាក់....! »

ដោយសារការយល់ឃើញស្របៗគ្នាដូច្នេះ យប់នោះយើងធ្វើការហាក់ដូចជាមានអារម្មណ៍ល្អជាងកាលពីម្សិលមិញ ប៉ុន្តែជួនអី ក៏មានព្រឹត្តិការណ៍ចំឡែកមួយកើតឡើង ដែលខ្ញុំនឹកស្មានមិនដល់សោះ ។

គឺនៅចុងបញ្ចប់នៃការប្រលងចំរៀង ស្រាប់តែពិធីករបានឡើងប្រកាសថា មានអ្នកចំរៀងស្រីក្រៅការប្រកួតម្នាក់មកសុំឡើងច្រៀងជាកិត្តិយស ដើម្បីឧទ្ទិសជាកំលាំងចិត្ត ជូនដល់នាងពិសិដ្ឋពាលិកា ដែលកំពុងព្យាបាលនៅភ្នំពេញ ឱ្យបានឆ្លងរួចពីមហាគ្រោះថ្នាក់ ។

ខ្ញុំនិងមិត្តទាំងពីរ មានសេចក្តីរីករាយណាស់ កាលបើឮថាមានអ្នកចំរៀងកិត្តិយស ប្រុងឡើងច្រៀងជួយជាកំលាំងចិត្តដល់តារារងគ្រោះអភ័ព្វ ។ ពិសេសជាងនេះទៅទៀត អ្នកចំរៀងនោះក៏មានរូបរាងស្អាតមុខមាត់ស្រដៀងនាងពិសិដ្ឋពាលិកា ប្លែកត្រង់ថា គ្មានអ្នកណាម្នាក់ដឹងសោះ ថានាងជាកូនចៅអ្នកណា និងធ្លាប់ច្រៀងនៅកន្លែងណានោះឡើយ ។

នៅពេលឡើងលើវេទិកា នាងបានប្រាប់ឈ្មោះនាងថាជា "រំដួលភ្នំស្រី" ហើយសុំច្រៀងបទ "វិលវិញណាំបង !" ។

គ្រាន់តែឮឈ្មោះបទនេះភ្លាម ខ្ញុំព្រឺក្បាលខ្នាក ព្រោះកន្លងមកប្អូន

ខេត្តហើយ ពុំមានអ្នកណាច្រៀងបទនេះទេ ម៉្យាងបទនេះទុកដូចជាបទប្រចាំជីវិតរបស់ពិសិដ្ឋពាលីកា ដែលនាងចូលចិត្តច្រៀងជាងគេបំផុត បន្ទាប់ពីមានភាពរកាំរកូសលើឆាកជីវិតស្នេហារបស់នាងមក ។

មិនតែប៉ុណ្ណោះ ដោយការស្គាល់ជំនាញច្រៀងបទនេះ ក្រុមហ៊ុនថតចំរៀងកាយវិការ ក៏បានថតនាងច្រៀងផ្ទាល់នៅក្នុងអាល់ប៊ុមមួយឈ្មោះថា "វិលវិញណាំបង " តាមដំណើររឿងដែលបានចារចែងនៅក្នុងខ្លឹមសារទំនុកច្រៀង ។

អ្នកបច្ចេកទេសចាក់ស៊ីឌី ក៏ចុចរាវរកបទ "វិលវិញណាំបង " នោះភ្លាម ដោយបិទសំលេងច្រៀងរបស់នាងពិសិដ្ឋពាលីកាទាំងស្រុង ទុកតែរូបភាពនិងចង្វាក់ **MELODIE** សំរាប់ឱ្យអ្នកចំរៀងកិត្តិយសច្រៀងតាមទំនុកច្រៀង ដែលមានរាយជាអក្សរនៅពីក្រោម ។

នៅពីមុខតុគណៈមេប្រយោគ មានដាក់តំកល់ទូរទស្សន៍២១អ៊ិញមួយគ្រឿង សំរាប់ខ្ញុំនិងមិត្តពីរបីនាក់ទៀតតាមដានការប្រលងចំរៀងកន្លងមក ហើយពេលនេះខ្ញុំក៏ត្រូវសំលឹងមើលរូបសំដែងរបស់នាងពិសិដ្ឋពាលីកា និងផ្ទៀងស្តាប់អ្នកចំរៀងកិត្តិយសបណ្តើរ តើនាងច្រៀងត្រូវតាមទំនួលទំនុកច្រៀងនោះដែរឬទេ ? ។

ស្រាប់តែ គ្រាន់តែនាងរំដួលភ្នំស្រីចាប់ស្រែកច្រៀងឡើងបានមួយវគ្គដំបូងពេលណា ក៏ឮសូរសំលេងមនុស្សស្រែកលាន់ខ្ទរខ្ទៀវខ្ទានៅពាសពេញទីលានខាងមុខ ធ្វើឱ្យខ្ញុំមានការភ្ញាក់ផ្អើលភ្លាម ព្រោះនោះមិនមែនជាសំលេងកោតសរសើរថានាងច្រៀងពិរោះ ឬយ៉ាងណានោះទេ តែជាសំលេងស្រែកឱ្យអ្នកបច្ចេកទេស បិទសំលេងដើមរបស់នាងពិសិដ្ឋ

ពាលិកាទៅវិញ ។ តែអ្នកបច្ចេកទេសបានបញ្ជាក់ថា គេបានបិទសំលេងដើមអស់ហើយ នេះមកពីនាងរំដួលភ្នំស្រីនោះ ច្រៀងដូចសំនៀងរបស់ពិសិដ្ឋពាលិកាពេក បានជាអ្នកស្តាប់ទាំងអស់ច្រឡំស្មានតែអ្នកបច្ចេកទេសមិនបានបិទ ។

ខ្ញុំហាក់ដូចជាមានអារម្មណ៍មិនស្រួលសោះ នៅពេលដែលពួអ្នកចំរៀងស្រីកិត្តិយសនោះ ច្រៀងដូចសំលេងនាងពិសិដ្ឋពាលិកាមែនទែន ប៉ុន្តែអ្វីៗដែលអ្នករាល់គ្នាកំពុងខំប្រឹងស្តាប់នោះ ប្រែជារលត់រលាយទៅវិញភ្លាមៗ នៅពេលដែលមានខ្យល់ភ្លៀងបោកបក់មកយ៉ាងសាហាវដោយចៃដន្យ ធ្វើឱ្យដាច់ចរន្តអគ្គិសនីអស់រលីង ទាំងនៅលើវេទិកានៅកន្លែងចាក់ស៊ីឌី និងនៅកន្លែងតុរបស់គណៈមេប្រយោគ ។

ទីលានប្រារព្ធពិធីទាំងមូល ប្រែជាងងឹតសូន្យសុង ស្ទើរតែគ្មានអ្នកណាមើលឃើញអ្នកណាឃើញឡើយ ក្រៅតែពីពន្លឺខ្សែទឹកភ្លៀងបក់បាចសាចធាវៗ ! គ្មានឈប់ឈរ ។

ទស្សនិកជនដែលឈរមើលកកកុញ រត់បែកខ្ញែកគ្នារកកន្លែងជ្រកភ្លៀងអស់ហើយ ចំណែកខ្ញុំនិងគណៈមេប្រយោគឯទៀត រាងគត់មត់ជាងកន្លែងដទៃគ្រាន់បើ ព្រោះបានដំបូលធំៗប្លូនប្រាំចាំងការពារតាំងពីថ្ងៃ ។

ប៉ុន្តែអ្វីដែលខ្ញុំនិយាយថា ជាហេតុអស្ចារ្យមិនគួរឱ្យនឹកស្មានដល់នោះ គឺទូរទស្សន៍ទាំងអស់ដែលតាំងនៅក្នុងពិធីនោះ ដាច់ចរន្តអគ្គិសនីរលត់គ្មានសល់ ចំឡែកតែទូរទស្សន៍មួយដែលនៅតំកល់នៅពីមុខតុគណៈមេប្រយោគ ដែលពួកខ្ញុំទាំងបីនាក់កំពុងសំឡឹងមើលប៉ុណ្ណោះ នៅតែមានរូបភាពសំលេងជាប់រហូត ។ អ្នកខ្លះមិនដឹង ស្មានថានៅសល់

ចរន្តអគ្គិសនីសំរាប់ទូរទស្សន៍មួយនោះ ។

រឿងនេះ ធ្វើឱ្យអ្នកបច្ចេកទេសអគ្គិសនីនឹកឆ្ងល់ជាខ្លាំង ព្រោះគេពិនិត្យមើលទៅ ឃើញចរន្តគ្រប់បណ្ដាញត្រូវដាច់ទាំងអស់ ហេតុអ្វីបែរជាទូរទស្សន៍ដែលនៅពីមុខតុខ្ញុំ នៅមានដំណើរការដូចធម្មតាទៅវិញ?។

ទោះបីជាពេលនោះ ទាំងខ្ញុំ ទាំងអ្នកឯទៀត មានការងឿងឆ្ងល់យ៉ាងណាក៏ដោយ តែហាក់ដូចជាមិនបានដេញដោលជីកឫសជីកគល់ឱ្យបានឫត់ចត់ ថាហេតុម្ដេចបានជាទូរទស្សន៍នោះ មិនរលត់ដូចទូរទស្សន៍ឯទៀតនោះឡើយ ។ គេបែរជាមកចោមរោមមើលទូរទស្សន៍នោះទៅវិញ គឺមកមើលកាយវិការសំដែងរបស់នាងពិសិដ្ឋពាលីកា តាមរយៈបទចំរៀង "វិលវិញណាបង ! "... ដែលនាងច្រៀងបញ្ចេញសំលេងយ៉ាងស្រងេះស្រងោចខ្លោចផ្សារ ÷

✱ «នឹកបងណាស់ នឹកបងណាស់អូនមើលតែផ្លូវ
ចាំច្រើនរដូវ បាត់ទៅ បាត់ទៅ
បងអើយអូននៅ រស់ទាំងវេទនា ។ »

✱«ព្រួយអើយព្រួយ ស្រីណាមួយមិនព្រួយនឹងស្នេហ៍
ស្រីខ្ញុំស្រីគេ ចិត្តដូចគ្នាទេ
គឺព្រួយកតល្វែ ពេលស្នេហ៍បាត់បង់ ។ »

R.«ឱ ស្នេហ៍គេឆក់ទាំងស្រស់ ស្នេហ៍ខ្ញុំស្មោះ គេថាស្នេហ៍គេ
ឈឺទេ! ឈឺទេ! ឈឺទេ! ឈឺទេ! ខំស្រែកហៅគេ តែគេ
បែរជាព្រងើយ

បងអើយ អើយបង ជឿអូនផង បងស្លាប់អូនសិន ! ។»

✸«កុំជឿគេ អូនគ្មានទេ ចិត្តក្បត់ណាំបង

អាសូរអូនផង វិលវិញណាំបង

វិលវិញណាំបង បងនឹកអូនណាស់ ! ។»

✸«ស្តាយអើយស្តាយ កូននិងម្តាយគេឱ្យបែកគ្នា

ពេលីក្តៅរងា កូនអើយយ៉ាងណា

អ្នកណា អ្នកណា ថ្នមកូនជួសម្តាយ ?... ។»

ជួនជា នៅពេលដែលខ្ញុំនិងអ្នកនៅឈរជុំវិញ កំពុងតែបណ្តែតអារម្មណ៍លេខ្វេងលង្វោចខ្វោចផ្សា ទៅតាមបទចំរៀងសោកវិយោគនោះ ពន្លឺអគ្គិសនីទាំងអស់បានត្រូវអ្នកបច្ចេកទេសរៀបចំតភ្ជាប់គ្រប់បណ្តាញឱ្យភ្លឺឡើងវិញ ព្រោះខ្យល់ភ្លៀងរួររអាប់ ក៏រាំងស្រឡះវិញហើយ ។

ប៉ុន្តែ ប្លែកតែទូរទស្សន៍ដែលនៅពីមុខខ្ញុំប៉ុណ្ណោះ នៅពេលដែលទូរទស្សន៍ឯទៀតមានចរន្តអគ្គិសនី ស្រាប់តែទូរទស្សន៍នេះក៏រលត់ភ្លិប... លែងមានចលនាសំលេងនិងរូបភាពតទៅទៀត ធ្វើឱ្យអ្នកបច្ចេកទេសកាន់តែងឿងក្បាលមែនទែន ព្រោះចរន្តអគ្គិសនីមិនដាច់សោះ តែបែរជាទូរទស្សន៍នោះគ្មានរូបសូន្យឈឹងខុសគេទៅវិញ ។

ទន្ទឹមនោះ អ្នកចំរៀងកិត្តិយសដែលមានឈ្មោះថារំដួលភ្នំស្រី ក៏បាត់ស្រមោលឈឹងសូន្យពីលើវេទិកា ទោះជាពិធីករបានអំពាវនាវហៅឱ្យមកច្រៀងបន្តទៀតយ៉ាងណា ក៏មិនឃើញឡើងមកទៀតដែរ ។

មិត្តខ្ញុំម្នាក់បានឱ្យយោបល់ថា ប្រហែលជាពេលខ្យល់ភ្លៀងដាច់ភ្លើងងងឹតងងល់អំបាញ់មិញ នាងខ្និលនៅរង់ចាំក៏ត្រឡប់ទៅផ្ទះវិញបាត់ទៅហើយ ? ។

ខ្ញុំក៏ងក់ក្បាលយល់ថាយ៉ាងនោះដែរ ប៉ុន្តែជួនអីក្នុងមួយប៉ប្រិចភ្នែកនោះ ទូរស័ព្ទដៃខ្ញុំក៏រោទិ៍ឡើង ។ ខ្ញុំឃើញលេខប្លែក ក៏ចាប់លើកចុចសួរភ្លាមថា ៖

-«អាឡូ ! អ្នកណាហ្នឹង ?...»

សំលេងស្រីម្នាក់ បានលាន់ឮឆ្លើយមកវិញ យ៉ាងពិរោះគ្រលួចគួរឱ្យព្រឺក្បាល ៖

-«...ខ្ញុំជាវិរដ្ឋលក្ខិស្រី ដែលបានឡើងច្រៀងកាលមុនពេលភ្លៀង ខ្ញុំខំប្រឹងច្រៀង ដើម្បីឧទ្ទិសបួងសួងសុំជួយរំដោះជីវិតនាងពិសិដ្ឋពាលីកាឱ្យរួចពីសេចក្ដីស្លាប់ ប៉ុន្តែពេលនេះមានមារមកជ្រែក !... ខ្ញុំពិតជាគ្មានសង្ឃឹមទេ !...»

ដោយពេលនោះ ខ្ញុំចិតនៅឆាយពីអ្នកឯទៀត ដែលគ្មានអ្នកណាដឹងឮពីការសន្ទនារបស់ខ្ញុំនោះ ខ្ញុំក៏ប្រញាប់សួរទៅម្ចាស់សំលេងវិញថា ៖

-«...ម៉េចក៏នាង ហ៊ានថាយ៉ាងនេះ ?...»

សំលេងនាងវិរដ្ឋលក្ខិស្រី ឮស្រួយស្រិបមកទៀត ដែលធ្វើឱ្យខ្ញុំកាន់តែក្ដុកក្ដួលជាងមុន ៖

-«...ព្រោះខ្ញុំជាអ្នកតាមថែរក្សាព្រលឹងតួអង្គនាយរោង ដែលសណ្ឋិតនៅក្នុងវិញ្ញាណសព្វៈរបស់នាងជាយូរមកហើយ !... សូម

លោកជ្រាបថា ពេលនេះជម្ងឺវប្បធម៌នៃស្ត្រីបូរាណ ច្រើនកន្លែងណាស់ នៅលើមាតុភូមិយើង ដូចជាជម្ងឺភ្នំស្រី ជម្ងឺបន្ទាយស្រី ជម្ងឺប្រាសាទនាងខ្មៅ និងជម្ងឺវាលស្រីស្រណោះ ជាដើម មានក្ដីរំជួលចិត្តសោកវន្ទត់ខ្លាំងណាស់ ក្រោយពីឮថា មានឃាតករបាញ់ប្រហារលើរូបនាងពិសិដ្ឋពាលីកា ព្រោះគេឥតដឹងសោះឡើយថា នាងនេះហើយជានិម្មិតរូបនៃព្រលឹងវប្បធម៌របស់នារីខ្មែរ នៅសម័យបច្ចុប្បន្ននេះ !... អ្វីៗហាក់ដូចជាត្រូវបញ្ចប់ទៅក្នុងស្នូរកាំភ្លើងដ៏អមនុស្សធម៌ ហើយអ្វីៗដែលធ្លាប់តែរីកស្រស់បំព្រង នៅក្នុងបេះដូងសិល្បករ ហាក់ដូចជាត្រូវរុះរោយស្វិតរញ្ជមក្រៀមស្រពោនអស់ហើយ...! »

-«...ប៉ុន្តែ ខ្ញុំគិតថា គ្រូពេទ្យ... ច្បាស់ជាខំជួយឱ្យនាងបាន... រស់ !...»

ខ្ញុំលែងឮសំលេងពីចុងខ្សែទូរស័ព្ទឆ្លើយមកទៀត ធ្វើឱ្យអារម្មណ៍ខ្ញុំអណ្ដែតរសាត់វិលវល់ រកកំណត់គោលដៅអ្វីពុំឃើញឡើយ ។

# ៥

# កំណាព្យក្រោមផ្កាកុលាបក្រៀម

**ក្រោយ**ពីចប់ការងារនៅខេត្តកំពង់ចាមហើយ ខ្ញុំក៏ត្រឡប់ទៅភ្នំពេញវិញ ដោយចិត្តអន្ទះអន្ទែងចង់មកដល់ឱ្យបានឆាប់ ដើម្បីឱ្យបានដឹងពីអាការៈរោគរបស់សិល្បការិនីដ៏ឆ្នើមនោះ តើប្រែប្រួលយ៉ាងណាទៅហើយ ? ។

ពេលមកដល់ កាត់មុខពេទ្យកាល់ម៉ែត្រ ខ្ញុំបានសុំឱ្យម្ចាស់ឡានដែលខ្ញុំដោយសារមកនោះ ឈប់ឡានបន្តិច តែខ្ញុំក៏មិនបានចុះហើយចូលទៅក្នុងពេទ្យដូចមុនដែរ ព្រោះថ្ងៃណាស់ហើយ គឺគ្រាន់តែបានស្ដាប់ដំណឹងពីមនុស្សដែលនៅឈរកកកុញពីមុខនោះថា តារាអភ័ព្វនៅតែដេកស្ដូកស្ដឹង ឥតកំរើកដៃជើង ហើយដង្ហើមពឹងតែលើអុកស៊ីហ្សែនដដែល ។...

ស្អែកឡើង ថ្ងៃ១៣កក្កដា១៩៩៩ ប្រហែលជាជិតថ្ងៃត្រង់ ទើបមានលេចឮដំណឹងជាចុងក្រោយថា ពិសិដ្ឋពាលីកា តារាដ៏ពេញមន្តស្នេហ៍ប្រជាប្រិយ៍ បានរលត់ជីវិតលាចាកលោកយើងនោះមែនទែនហើយ បន្ទាប់ពីក្រុមវេជ្ជបណ្ឌិតបានសាកល្បងដោយយកប្រដាប់ដកខ្យល់អុកស៊ី

ហៀរនចេញពីច្រមុះ មិនបានប៉ុន្មានម៉ោង ។

ពត៌មានដ៏ក្រៀមក្រំនេះ ហាក់ដូចជាធ្វើឱ្យធម្មជាតិនៅក្រុងភ្នំពេញទាំងមូលស្រពាប់ស្រពោនពន់ពេកណាស់ ។ តាំងពីរសៀលរហូតទៅដល់យប់យន់ ភ្លៀងក៏ធ្លាក់រ៉ែៗជាប់រហូត ប្រៀបដូចទឹកភ្នែកដ៏រហាមរហឹកខ្សឹកខ្សួលអួលអាក់ របស់ផ្ទៃមេឃដែលសម្រួមកាយវាចាចិត្ត កាន់ទុក្ខមរណសញ្ញានេះ ។

ថ្វីបើ ពិសិដ្ឋពាលីកា មិនមែនជាវដ្ឋនារីនយោបាយ មិនមែនជាប្រមុខដឹកនាំប្រទេស តែដំណឹងថានាងពិតជាត្រូវស្លាប់ដោយគ្រាប់កាំភ្លើងឃាតករកំណាចមែននោះ បានធ្វើឱ្យខ្ញុំរញ្ជួយបេះដូងថ្វើមប្រម៉ាត់ប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈ មិនអាចយកអ្វីមកប្រៀបផ្ទឹមបានឡើយ។

កំលាំងនៃសេចក្ដីឈឺចាប់សោកស្ដាយ បានប៉ះទង្គិចអារម្មណ៍អ្នកភ្នំពេញយ៉ាងធ្ងន់ធ្ងរជាទីបំផុត រហូតដល់ធ្វើឱ្យពួកមនុស្សដែលធ្លាក់ទឹកចិត្តទាំងប៉ុន្មាន រត់តាមទៅយំសោកបោកខ្លួននៅមុខសាកសពនាងក្រោយដែលគេយកចេញពីមន្ទីរពេទ្យ ទៅដំកល់ក្នុងសាលារបាំនៃសកលវិទ្យាល័យភូមិន្ទនិងវិចិត្រសិល្បៈ ដែលឋិតនៅប្របកីឡាដ្ឋានចាស់ឬស្ដាតឡាំប៊ែរ ។

ពេលនោះ ខ្ញុំមិនបានទៅមើល គេយកសពនាងចេញពីមន្ទីរពេទ្យទេ ព្រោះជាប់រវល់នៅរៀបចំបំបែកបង្ហំសេណារីយ៉ូរឿង បក្សីចាំក្រុងដែលត្រូវថតបន្តនៅថ្ងៃស្អែកទៀត ប៉ុន្តែគ្រាន់តែបានឮគេឯងនិយាយថាសពរបស់ពិសិដ្ឋពាលីកា បានត្រូវគណកម្មាធិការសកលវិទ្យាល័យរៀបចំដំកល់ឱ្យបានគ្រប់៧ថ្ងៃ ទើបបូជា ។ គេមានបំណងចង់ឱ្យប្រជាជន

បានទៅមើលមុខនាងជាចុងក្រោយឱ្យបានច្រើនគ្នា ឬយ៉ាងហោចណាស់ក៏បានឱ្យបុរសសំខាន់ក្នុងជីវិតរបស់នាង គឺខែប្រសិទ្ធ ត្រឡប់ពីអូស្ត្រាលីមកវិញទាន់ដែរ ។

មានគេនិយាយថា គេបានឱ្យដំណឹងទៅខែប្រសិទ្ធ តាំងតែពីពេលដែលតារាអភ័ព្វទទួលគ្រោះថ្នាក់ភ្លាមៗម្ល៉េះ ហើយគេចេះតែរង់ចាំក្រែងខែប្រសិទ្ធបានមកទាន់ដង្ហើមនាង ប៉ុន្តែមច្ចុរាជហាក់ដូចមិនប្រណីចំពោះគូស្នេហ៍អភ័ព្វនេះឡើយ ។

ក្រោយពីពិនិត្យមើលបួងសេណារីយ៉ូ ដែលត្រូវថតស្អែកសព្វគ្រប់ហើយ អារម្មណ៍ខ្ញុំក៏គិតព្រួចត្លួចនឹកទៅដល់តារាអភ័ព្វ ដែលទើបបញ្ចប់ជីវិតទៅក្នុងពេលថ្មីៗនោះទៀត ។ ហើយពេលនោះ ប្រពន្ធខ្ញុំក៏បានប្រាប់ថា ស្អែកគេនឹងនាំកូនៗខ្លះទៅគោរពសពពិសិដ្ឋពាលីកា ហើយប្រហែលជាអាចជួបនឹងខែប្រសិទ្ធផងក៏មិនដឹង ព្រោះមានឮគេនិយាយថា ខែប្រសិដ្ឋ ចេញដំណើរមកពីអូស្ត្រាលីហើយ ។...

ខ្ញុំក៏បានផ្តាំផ្ញើនឹងប្រពន្ធខ្ញុំទុកជាស្រេចថា បើសិនជាស្អែកជួបនឹងខែប្រសិទ្ធ ឬក្រុមគ្រួសាររបស់ពិសិដ្ឋពាលីកា ឱ្យសូមទោសឱ្យផង ថាខ្ញុំមិនទាន់បានទៅ ព្រោះជាប់រវល់ថតពីរបីថ្ងៃសិន តែដល់ថ្ងៃបូជា ខ្ញុំប្រាកដជាទៅដាច់ខាត !... ។

...យប់កាន់តែជ្រៅ ខ្ញុំនៅតែមិនទាន់ងងុយគេងនៅឡើយ ហើយចេះតែនឹកមម៉ៃថា តើគេរកមុខឃាតករដែលបាញ់ប្រហារនាងពិសិដ្ឋពាលីកានោះឃើញឬទេ ? ហើយឃាតករនោះជាឃាតករអាយ៉ង ឬជាឃាតករម្ចាស់ការ ? ។

គិតចុះគិតឡើង ខ្ញុំបែរជានឹកចង់មើលរឿងបុប្ផពស់វែក ត្រង់ឆាកបញ្ចប់នោះម្ដងទៀត តើរូបភាពមានប្រែប្រួលយ៉ាងណាទេ នៅពេលដែលនាងតារាឯកត្រូវគេបាញ់សំលាប់ហើយនេះ ។ ព្រោះកាលពីពេលមុន វាមានហេតុភេទប្លែកៗកើតឡើងច្រើនដងដែរ តើហេតុភេទទាំងនោះ អាចមានជាប់ទាក់ទងអ្វីខ្លះដល់បញ្ហាឃាតកម្មកំណាចនេះ ?។

ពេលនោះ ប្រពន្ធកូនចៅខ្ញុំចូលនិទ្រាអស់ហើយ ខ្ញុំក៏ចាក់រឿងបុប្ផពស់វែកនោះមើលតែម្នាក់ឯង ត្រង់វគ្គចុងបញ្ចប់ដែលទេពរិន្ទដារ៉ូលើកពិសិដ្ឋពាលីកាបោះទៅក្នុងរណ្ដៅភ្លើងសិល្ប៍ ។

ប៉ុន្តែ ក្រោយពីមើលចប់ ក៏ពុំមានឃើញហេតុភេទចំលែកអ្វីកើតឡើង ដូចកាលដែលនាងពិសិដ្ឋពាលីកាបានមើលឃើញនោះឡើយ ។ អាស្រ័យដោយយប់រំលងអាធ្រាតទៅហើយ ខ្ញុំក៏សំងំគេងឱ្យបានលក់ឆាប់ ព្រោះស្អែកត្រូវងើបពីព្រឹកទៀត ។

ជួនអី ពេលខ្ញុំលង់លក់ទៅ ហាក់ដូចជាមិនបានសិប់ស្រួលប្បួលផងក៏ឮសំរែកស្រែកទ្រហោររបស់ស្រីម្នាក់ លាន់គ្រលួចមកពីក្បែររោងកុនប្រាសាទពេជ្រ «ជួយផង !,,, ជួយផង !,,,ជួយខ្ញុំផង !,,,»

កណ្ដាលអាធ្រាតដ៏ស្ងាត់គួរឱ្យខ្លាច ព្រលឹងខ្ញុំក៏ស្ទុះងើបឡើងទាំងញ័ររន្ធត់ ហើយរត់ចេញទៅឈរមើលពីលើយ៉ខាងមុខ ដំរង់ទៅទិសដែលបង្កើតស្នូរ ក៏ឃើញស្រីម្នាក់រត់ត្រហេបត្រហបចេញតាមផ្លូវក្បែររោងកុននោះមក ហើយមកភ្ជាត់ជើងដួលកណ្ដាលថ្នល់ ចំពីមុខក្រសួងវប្បធម៌ចាស់ ដែលស្ងាត់ជ្រៀបគ្មានឡានម៉ូតូអី បើកបរចុះឡើងសោះឡើយ ។

អាស្រ័យដោយពន្លឺអគ្គិសនីនៅតាមដងវិថីភ្លឺច្រឡាក់ ធ្វើឱ្យព្រលឹងខ្ញុំស្គាល់ច្បាស់ថា ស្រីនោះគឺជាតារាឯកពិសិដ្ឋពាលីកា តារាប្រជាប្រិយ៍ដែលទស្សនិកជនខ្មែរទូទាំងប្រទេសបានស្គាល់ច្បាស់ ។

នៅពេលដែលនាងភ្ញាក់ជើងដួលនោះ ស្រាប់តែមានបុរសពីរនាក់ជិះម៉ូតូយ៉ាងលឿនមកដល់ ហើយបុរសដែលអង្គុយក្រោយ ក៏ដកកាំភ្លើងបាញ់មកលើខ្លួននាងជាច្រើនគ្រាប់ បណ្តាលឱ្យនាងស្រែកថ្ងូរទ្រហោរសាជាថ្មីថា «...តើខ្ញុំខុសអី បានជាបាញ់ខ្ញុំ ?...»

សំលេងនេះ ធ្វើឱ្យខ្ញុំរន្ធត់ញាប់ញ័រមែនទែន ក៏លោតផ្លោះចេញពីយ៉មុខផ្ទះ រត់សំដៅទៅរកជួយនាង ដែលកំពុងប្រកាច់នទៀលនៅកណ្តាលថ្នល់ម្នាក់ឯង គ្មានអ្នកណាម្នាក់នៅក្បែរៗនោះហ៊ានចេញពីផ្ទះមកជួយសោះឡើយ ។

ប៉ុន្តែ ជួនជាពេលដែលខ្ញុំជិតទៅដល់ ក៏ឃើញនាងពិសិដ្ឋពាលីកាដែលមុននេះកំពុងប្រកាច់នទៀលក្នុងថ្លុកឈាម បែរជាប្តូរសំលៀកបំពាក់ពីសំពត់អាវធម្មតា ទៅជាតួអង្គព្រះរាមប្រកបដោយសំលៀកបំពាក់ភ្លឺរន្ទាល ហើយខំប្រឹងទប់ខ្លួនរាំយ៉ាងរំពើននៅកណ្តាលថ្នល់ ។ អ្វីដែលពិសេសនោះ គឺតួអង្គព្រះរាមដ៏អង់អាច បានលើកធ្នូសរបាញ់សំដៅទៅរកឃាតករទាំងពីរនាក់នោះវិញជាបន្ទាន់ ប៉ុន្តែឃាតករនោះបែរជារោទិ៍ម៉ូតូខ្លាំងស្ទើររបើកផ្ទះថ្ម ហើយបើកហោះទៅលើមេឃភ្លាមក្រោយពីម៉ូតូនោះ បានបញ្ចេញស្លាបសងខាងដូចយន្តហោះប្រតិកម្ម ។ ក្នុងស្រមោលខ្មៅមួយផ្ទាំងធំដ៏ខ្ពស់ស្កឹមស្កៃ ឯកូនសរជ័យដែលបាញ់ទៅបែរជាចាក់ធ្លាក់មកលើដីភាត់ភាយលាយជាមួយតំណក់ឈាមវិញ ហើយ

ក្លាយជាអក្សរពីរបីម៉ាត់ថា «...អស់សង្ឃឹម !...» ។

ខ្ញុំរត់ទៅទាន់ហេតុការណ៍នេះ នៅពេលដែលតួអង្គនាយរោងប្រែជារលាយសាច់ឆ្អឹងឈាម ហូរចេញពីសំពត់អាវដ៏ភ្លឺរន្ទាលនោះ ជ្រាបចូលទៅក្នុងថ្មល់អស់រលីង ។ ព្រលឹងខ្ញុំរត់ឆ្វេឆ្វានៅកណ្ដាលថ្នល់ម្នាក់ឯង នៅពេលដែលឃើញសំពត់អាវរបស់នាយរោង បែរជាអាចពត់រាងលើកដៃជើងរាំបាន ដោយគ្មានមនុស្សនៅពីក្នុង គឺរាំតាមចង្វាក់ភ្លេងពិណពាទ្យ. ដែលប្រគុំឮរណ្ដំចេញមកពីក្នុងអាគារក្រសួងវប្បធម៌ ។ ហើយបន្ទាប់ពីពត់រាងរាំអស់មួយសន្ទុះ សំពត់អាវទាំងនោះ ក៏រលាយបាត់សូន្យសុងទៅតាមរលកសំលេងពិណពាទ្យ ដែលរោទិ៍ខ្ទរកាន់តែខ្លាំងឡើង ធ្វើឱ្យខ្ញុំភ័យរន្ធត់ភ្ញាក់ញ័រទាំងខ្លួន...។

ខ្ញុំភ្ញាក់ស្មឹងមមើង ក្រោមស្រមោលទ្រនិចនាលិកាដែលចង្អុលម៉ោង ៣... ក៏ងើប...ក្រោកដើរ ទៅយ៉ខាងក្រៅ សំលឹងមើលទៅចន្លោះផ្លូវមុខរោងកុនប្រាសាទពេជ្រ ។ គ្មានឃើញអ្វីទាំងអស់ក្រៅពីស៊ីក្លូ ឬឡានបើកបរមួយៗ ដោយភាពងោកងុយទើបខ្ញុំត្រឡប់ចូលមកដេកវិញ ដោយគិតខ្លួនឯងថា មកពីអារម្មណ៍ខ្ញុំជក់ជាប់តែលើរឿងឃាតកម្មនោះពេក ទើបបណ្ដាលឱ្យយល់សប្តិឃើញផ្ដេសផ្ដាសយ៉ាងនេះ ។

ម្ដងនេះ ខ្ញុំមិនដឹងជាខ្លួនឯងដេកលក់ពីថ្មើរណាផង ប៉ុន្តែនៅពេលដែលភ្ញាក់ឡើងឃើញម៉ោងជិត ៦ព្រឹកទៅហើយ ហើយក៏ជាការភ្ញាក់ដែលពោរពេញដោយក្ដីរវើរវាយធ្ងន់ស្រិបក្នុងខួរក្បាល ព្រោះខ្ញុំដូចជាបានឃើញតារាប្រជាប្រិយ៍នោះ មកក្នុងសុបិនដ៏ចម្លែកម្ដងទៀត ។

គឺខ្ញុំបានឃើញ នាងពិសិដ្ឋពាលីកា ក្នុងសំលៀកបំពាក់ជាតួនាង

បុប្ផាពស់វែក បានដើរមកឈរនៅក្បែរគុសរសេររបស់ខ្ញុំ ហើយនិយាយមកកាន់ខ្ញុំ ដោយទឹកមុខស្រពាប់ស្រពោនថា ÷

-«លោកអឺអើយ!,,, ខ្ញុំស្លាប់ហើយ !,,, ខ្ញុំមិនបាននៅដើរត្តូវិដេអូតទៅទៀតទេ !,,, នេះប្រហែលមកពីចុងបញ្ចប់នៃរឿងបុប្ផាពស់វែក លោកអឺបានឱ្យតួរាហ៊ូ បោះខ្ញុំទម្លាក់ទៅក្នុងរណ្ដៅភ្លើងសិល្ប៍ទេដឹង បានជាប្រផ្នូលហេតុ បណ្ដាលឱ្យមានឃាតករមកបាញ់សម្លាប់ខ្ញុំ,,,, របៀបនេះ ?,,,»

ពេលនោះ ព្រលឹងខ្ញុំរន្ធត់ញាប់ញ័រពេក មិនបានឆ្លើយតបទៅកាន់នាងវិញថាដូចម្ដេចឡើយ ជាហេតុធ្វើឱ្យនាងនិយាយមកកាន់ខ្ញុំមួយឃ្លាទៀតថា ÷

-«,,,,តែទោះបីយ៉ាងណាក៏ដោយ ក៏ខ្ញុំយល់ថា នេះជាកម្មផលរបស់ខ្ញុំទេ,,,,! ហើយបើសិនជាលោកអឺ មានឱកាសទៅកាន់ភ្នំបាសិដ្ឋទៀត លោកអឺកុំភ្លេចទៅមើលកន្លែងដែលលោកអឺថតបញ្ចប់រឿងបុប្ផាពស់វែកនោះ ខ្ញុំបានទុកកំណាព្យបីសន្លឹកនៅត្រង់កន្លែងដែលខ្ញុំត្រូវគេច្រានទម្លាក់ទៅក្នុងជ្រោះ កំណាព្យទី១ ទុកផ្ញើជូនប្ដីខ្ញុំ ទី២ ទុកឱ្យកូនប្រុសខ្ញុំ ឯកំណាព្យទី៣ សុំផ្ញើជូនដល់សិល្បករ-សិល្បការិនីខ្មែរទាំងអស់ ! បើលោកអឺមិនយល់ទាស់ទេ សូមជួយកែសំរួលអត្ថបទទាំងបីនោះ ទៅជាទំនុកច្រៀងឱ្យខ្ញុំផង ខ្ញុំនឹងយកទៅច្រៀងបញ្ចូលក្នុងស៊ីឌីឱ្យបានយ៉ាងឆាប់បំផុត ! ពិសេស គឺទាន់មុនពេលដែលប្ដីខ្ញុំត្រឡប់ទៅអូស្ត្រាលីវិញ ព្រោះខ្ញុំជឿថា ប្ដីខ្ញុំដែលត្រឡប់មកនេះក៏មិនអាចនៅយូរបានដែរ ហើយដល់ពេលត្រឡប់ទៅវិញ ក៏ពិតជាមិនអាចត្រឡប់មក

ស្រុកខ្មែរ,,, ជាថ្មីទៀតបានឡើយ !,,,»

និយាយដល់រឿងនេះ ព្រលឹងខ្ញុំក៏ដេញសួរទៅវិញ ÷

-«,,,តើនាងប្រាកដថាប្ដីនាងមកដល់ស្អែកនេះ មែនឬ ?,,»

-«ចាស ប្រាកដហើយ !,,,» ព្រលឹងនាយរោងឆ្លើយតបមកវិញ «,,,គាត់ចង់មកតាំងតែពីបានទទួលដំណឹងភ្លាមៗម៉្លេះ តែមកមិនទាន់ខ្ញុំទ្រាំចាំគាត់ !,,, ដើម្បីឱ្យបានឃើញមុខគាត់ជាចុងក្រោយ មុនដែលត្រូវបែកគាត់ជារៀងរហូត ទោះបីជាខ្ញុំមិនអាចនិយាយប្រាប់គាត់បានថាមូលហេតុអ្វីបានជាគេបាញ់ខ្ញុំនោះក៏ដោយ !! ប៉ុន្តែ មច្ចុរាជហាក់ដូចជាមិនអាណិតខ្ញុំបន្តិចសោះ !,,,»

នៅពេលដែលខ្ញុំឃើញព្រលឹងនាង ឈរបង្ហូរទឹកភ្នែកខ្សឹកខ្សួលអួលអាក់នោះ ខ្ញុំក៏ដាច់ចិត្តសួរបន្ថែមទៀតថា ÷

-«,,,រឿងជួយកែអត្ថបទកំណាព្យទៅជាទំនុកច្រៀង ខ្ញុំជួយបាន ប៉ុន្តែខ្ញុំឆ្ងល់ថា បើនាងស្លាប់ទៅហើយ តើធ្វើយ៉ាងណា អាចច្រៀងបញ្ចូលក្នុងស៊ីឌីបាន ?,,,»

-«មិនពិបាកទេ ព្រោះមានអ្នកភ្លេង អ្នកចំរៀងយើងច្រើនណាស់ដែលស្លាប់ទៅហើយ គេស្ម័គ្រមកជួយខ្ញុំ !,,, កាលណាលោកអ៊ីជួយពិនិត្យកែសំរួលអត្ថបទទាំងនោះហើយ លោកអ៊ីយកវាទៅដាក់កន្លែងដើមចុះ ពីរថ្ងៃទៀត ដែលជាថ្ងៃសីលនោះ លោកអ៊ីអាចទៅយកស៊ីឌីមកចាក់ស្ដាប់បាន !,,, ខ្ញុំសូមលាលោកអ៊ី,,,ហើយ !,,»

,,,ម៉ោង៧កន្លះ ខ្ញុំបានចេញដំណើរទៅជាមួយក្រុមថតវីដេអូ ដោយនឹកគិតដល់រឿងយល់សប្តិជាប់តាមតែផ្លូវ តែឥតនិយាយប្រាប់អ្នកណាជា

ពីរជាបីឡើយ ព្រោះខ្លាចគេមិនជឿថា យករឿងអរូបីមកនិយាយផ្ដេសផ្ដាស់ ។

ចិត្តខ្ញុំចង់តែទៅឃើញកន្លែងនោះបានឆាប់ តើវាដូចពាក្យដែលព្រលឹងនាងនិយាយក្នុងសុបិននោះមែនទេ ។ ជួនជាពេលនោះកន្លែងដែលខ្ញុំត្រូវថត គឺជ្រើសរើសយកបរិវេណប្រាសាទភ្នំរាប ឯកន្លែងដែលខ្ញុំថតកាលពោះទម្លាក់នាងពាលីកា វាចិតនៅលើប្រាសាទត្រៃត្រឹង្សឯណោះ ។

ទោះបីយ៉ាងនេះក្ដី ក៏ខ្ញុំគិតថា ឱ្យតែថតចប់មួយវគ្គ ដល់ពេលសំរាកញ៉ាំបាយម្ដង ខ្ញុំច្បាស់ជាឱ្យគេបើកឡានជូនខ្ញុំទៅកាន់កន្លែងនោះដោយខានមិនបានឡើយ ។

កំពុងថត ប្រមាណជាម៉ោង១១ ខ្ញុំបានទទួលទូរស័ព្ទពីប្រពន្ធកូនខ្ញុំដែលនាំគ្នាទៅគោរពសពនាងពិសិដ្ឋពាលីកា នៅឯសាលាខាងជើងថា «ខែប្រសិទ្ធបានមកដល់ហើយ គេយំបោកខ្លួនអោបសពប្រពន្ធ គួរឱ្យស្រងេះស្រងោចក្រៃលែង ហើយស្ទើរតែមិនអាចនិយាយរកអ្នកណារួចឡើយ ក្រៅតែពីយំ !,,,» ។

នៅពេលនោះ ទើបខ្ញុំគិតថា អ្វីដែលព្រលឹងនាងពាលីកានិយាយប្រាប់ខ្ញុំក្នុងសុបិនកាលពីយប់មិញ គឺជាការពិត ដូច្នេះរឿងអត្ថបទកំណាព្យនោះវាអាចនឹងពិតទៀត ហើយជារឿងពិតដែលគ្មានអ្នកណាដឹងក្រៅតែពីខ្ញុំម្នាក់នោះឡើយ ។

បន្ទាប់មក ខ្ញុំបានទទួលទូរស័ព្ទពីមិត្តម្នាក់ គេផ្ដើមគំនិតថា គួតែខ្ញុំសើរើរៀបចំបញ្ចាំងរឿង បុប្ផាពស់វែកឡើងវិញ ព្រោះកាលៈទេសៈនេះ

ប្រហែលជាមានផ្លូវ? ។ គិតមួយគ្រួសទៅ ខ្ញុំដូចជាចង់យល់ព្រមតាមគំនិតនោះដែរ ប៉ុន្តែក្រោយពីពិចារណាសព្វគ្រប់ ខ្ញុំក៏បោះបង់យោបល់នោះវិញ គឺមិនត្រូវធ្វើអាជីវកម្មឆ្មៀតយកចំណេញលើទឹកភ្នែកនិងឈាមរបស់សិល្បការិនីដែលរងគ្រោះនោះឡើយ ។ ម្យ៉ាងដោយពេលនោះ ខ្ញុំគ្មានអារម្មណ៍គិតឃើញអ្វី ក្រៅតែពីរង់ចាំឱ្យមានឱកាស អាលនឹងទៅមើលកន្លែងដែលព្រលឹងនាងពាលីកាបានផ្ដាំនោះ ទើបខ្ញុំប្រញាប់មិនទូរស័ព្ទទៅវិញភ្លាម ។

...ពេលសំរាកបានមកដល់ ខ្ញុំស្រស់ស្រូបបាយដោយប្រញិបប្រញាប់ក៏ឱ្យអ្នកជំនួយការម្នាក់បើកឡានជូនខ្ញុំឡើងទៅលើភ្នំត្រៃត្រឹង្ស ក្នុងល្បិចថាដើរទៅរកមើលទីតាំងសំរាប់ទុកបំរុងថតនៅថ្ងៃស្អែក ។

លុះទៅដល់ជិតកន្លែងដែលខ្ញុំថតឆាកបញ្ចប់រឿងបុប្ផាពស់វែក ខ្ញុំក៏ឱ្យអ្នកជំនួយការឈប់ឡាននៅក្រោមម្លប់ឈើមួយ ដោយប្រាប់គេថាចុះដើររកមើលកន្លែងបន្តិចសិន ។ ហើយដោយមិនចង់ឱ្យជននោះដើរតាម ខ្ញុំក៏បន្ថែមថា ដូចជាឈឺពោះទៅរកកន្លែងស្ងាត់បត់ជើងផង...។

ការពិត គឺខ្ញុំខំដើរយ៉ាងលឿន កាត់តាមរបៀងផ្ទាំងថ្មធំៗ ទៅរកបរិវេណល្អាងមួយទៀត ដែលនៅជិតនោះ ខ្ញុំបានយកវាធ្វើជារណ្ដៅភ្លើងសិល្ប៍សំរាប់ប្រានាងបុប្ផាពស់វែក ទម្លាក់ពីលើថ្មខ្ពស់សន្ធឹមនោះចុះមក ។

ថ្វីបើកន្លងមកជាង៤ឆ្នាំហើយក្ដី ក៏ខ្ញុំនៅចាំកន្លែងបានច្បាស់មិនច្រឡំទេ ព្រោះទ្រង់ទ្រាយដើមឈើ និងផ្ទាំងថ្មនៅដូចដើមដដែល ខុសប្លែកតែមានស្មៅនិងវល្លិដុះបន្តិចបន្តួចប៉ុណ្ណោះ ។

តាមខ្ញុំគិតមើលទៅ កន្លែងនេះ ក្រៅតែពីផលិតកម្មខ្ញុំបានមកជ្រើសរើសថតម្តង ទំនងជាគ្មានផលិតកម្មណាដទៃមកថតទៀតទេ ព្រោះតាំងពីសិល្បៈភាពយន្តវីដេអូខ្មែរ ត្រូវធ្លាក់ចុះ ស្ទុឌីយោ (STUDIO) ធម្មជាតិនៅតាមរមណីយដ្ឋាននានា ហាក់ដូចត្រូវគេបោះបង់ចោលទាំងស្រុង ។

នៅពេលដែលខ្ញុំកំពុងឈរសម្លឹងរកមើលក្រដាស់បីសន្ទឹក តាមបណ្តាំរបស់ព្រលឹងខ្មោចនាងពិសិដ្ឋពាលីកានោះ ស្រាប់តែខ្ញុំឮសម្លេងស្រីម្នាក់ស្រែកត្រលួច ដូចជាសម្លេងស្រែកក្នុងសុបិនកាលពីយប់មិញ «ជួយផង ! ជួយផង !,,, ជួយខ្ញុំផង !,,,» ។

ខ្ញុំងើតក្បាលមើលទៅលើភ្នាម ក៏ឃើញស្រមោលស្ទុងៗរបស់ស្រីម្នាក់រត់មកដល់មាត់រណ្តៅ និងមានស្រមោលមនុស្សប្រុសម្នាក់រត់ដេញតាម ហើយលើកកាំភ្លើងបាញ់ផាំងៗពីក្រោយ បណ្តាលឱ្យស្រីនោះដួលរលំធ្លាក់មកក្នុងរណ្តៅជ្រោះយ៉ាងសាហាវព្រៃផ្សៃ ។

ភ្លាមៗនោះ ខ្ញុំមើលមិនស្គាល់ថាស្រីនោះជាអ្នកណាទេ ប៉ុន្តែនាងធ្លាក់បណ្តើរ ហើយស្រែកដង្ហោយបណ្តើរ ដោយសំលេងរន្ធត់គួរឱ្យព្រឺក្បាលពន់ពេក «,,,តើខ្ញុំ,,,ខុសអី បានជាបាញ់ខ្ញុំ !,,? » ដែលធ្វើឱ្យខ្ញុំស្គាល់ជាក់ថាជាសម្លេងរបស់តារាឯករបាំខ្មែរ ។

ជួនជានៅពេលស្រមោលម្ចាស់សម្លេងនោះ ធ្លាក់មិនទាន់ដល់ដីស្រួលបួលផង ស្រាប់តែឃើញស្រមោលហ្វូងសិល្បករ-សិល្បការិនីចាស់ៗដែលស្លាប់ទៅយូរៗហើយ ហើយដែលខ្ញុំស្ទើរតែចាំមុខមិនបានផងនោះ បាននាំគ្នាស្ទុះពីឆ្វេងពីស្តាំមកត្រកងជ្រោងយកខ្លួនស្រីរងគ្រោះ

សែងចូលទៅក្នុងល្វាងមួយដែលនៅក្បែរ ។

ខ្ញុំតាមសម្លឹងស្ទើរមិនដាក់ភ្នែក ឃើញគ្រោងឆ្អឹងអសុភជាច្រើនឈរច្រូងនៅក្នុងល្វាងនោះ ស្លៀកពាក់សព្រោងព្រាតដូចជាពួកគ្រូពេទ្យដែលរង់ចាំធ្វើការវះកាត់ នៅក្នុងបន្ទប់សង្គ្រោះបន្ទាន់ ។

ខ្ញុំកាន់តែព្រឺក្បាលមែនទែន ហើយនឹកថាប្រហែលជាខ្មោចនាងពិសិដ្ឋពាលីកាចង់ធ្វើកលលលេងទេដឹង បានជាចេះតែឱ្យខ្ញុំឃើញទិដ្ឋភាពគួរឱ្យរន្ធត់ញាប់ញ័របែ្លកៗដូច្នេះ ? ។

ទ្រាំមិនបាន ខ្ញុំក៏ថយក្រោយយឺតៗ ក្នុងជំហានដើរទៅរកឡានដែលចតចាំនៅជ្រុងម្ខាងនោះវិញ ព្រោះរកក្រដាសបីសន្លឹកនោះមិនឃើញសោះ មិនដឹងនៅធ្វើអីទៀត ? ហើយពេលនោះក៏ឮសូរដូចជាមាត់អ្នកជំនួយការ ស្រែកហៅរកខ្ញុំពីចម្ងាយដែរ ។

ប៉ុន្តែចៃដន្យអី នៅពេលដែលខ្ញុំដើរមកអែបនឹងផ្ទាំងថ្មមួយ ស្រាប់តែលេចស្រមោលនាងពិសិដ្ឋពាលីកា ក្នុងគ្រឿងតែងជាតួអង្គព្រះរាមបានផុះលេចឆ្វោមកភ្លាម ហើយមាននារីម្នាក់ទៀតឈរនៅក្បែរ ហើយដែលខ្ញុំស្គាល់ច្បាស់ថានារីនោះ គឺជានាងរំដួលភ្នំស្រី ÷

-«សូមទោស លោកអឺ ដែលមកចាំខ្ញុំយូរ ! » នាយរោងពាលីកាបន្លឺឡើង ក្នុងរលកវាចាអន្ទះអន្ទែង «...ក្នុងពេលដែលរូបកាយខ្ញុំកំពុងត្រូវគេតាំងឱ្យប្រជាជនចូលមើល នៅសាលាខាងជើងព្រលឹងខ្ញុំក៏បានហោះហើរទៅកាន់ម្ចាស់វិមានភ្នំស្រី ម្ចាស់ប្រាសាទបន្ទាយស្រី និងម្ចាស់ប្រាសាទនាងខ្មៅ ដើម្បីឱ្យជួយតែងកំណាព្យទាំងបីបែបនេះ ព្រោះពួកគាត់ជាអ្នកគ្រប់គ្រងព្រលឹងវាសនាជតាជីវិតខ្ញុំតាំងពីក្មេង

មក ពួកគាត់អាចដឹងពីជំរៅក្រអៅមនោសញ្ចេតនា និងសុខទុក្ខក្នុងថ្លើមប្រម៉ាត់របស់ខ្ញុំច្បាស់ជាងខ្ញុំទៅទៀត !,,»

ខ្ញុំមិនអាចសួរអ្វីតបទៅវិញបានឡើយ ព្រោះពេលនោះនាងរំដួលភ្នំស្រី ក៏វាចាបន្ថែម ÷

-«,,,ដោយជម្រុំនិមួយៗនៅឆ្ងាយពីគ្នា ម៉្លោះហើយការហោះហើរប្រមូលកំណាព្យក៏មានការយឺតយ៉ាវបន្តិច ឥលូវ ! ខ្ញុំបានគ្រប់យកមកជូនលោកអឹកវីនិពន្ធហើយ សូមជួយកែសំរួលតាមបណ្តាំរបស់នាងផងចុះ ! ពួក,,,យើង លាទៅវិញហើយ !,,,»

និយាយស្ទើរមិនទាន់ផុតពីមាត់ ស្រមោលរបស់នារីទាំងពីរក៏រលាយបាត់ទៅវិញភ្លាម ធ្វើឱ្យខ្ញុំស្រឡាំងកាំងអស់មួយសន្ទុះធំទៀត ព្រោះនៅតែមិនឃើញក្រដាសកំណាព្យនោះដដែល ។

ប៉ុន្តែ នៅពេលដែលខ្ញុំឃើញស្រមោលអ្នកជំនួយការថតភាពយន្តដើរលិមៗមកពីចម្ងាយ ស្រាប់តែខ្ញុំដាក់ភ្នែកទៅលើថ្មមួយផ្ទាំងតូចនៅក្បែរនោះ ឃើញក្រដាសបីសន្លឹកសង្កត់ដោយផ្កាកុលាបក្រៀមមួយទងដែលទើបតែនិម្មិតផុះឡើងថ្មីៗ ។

ខ្ញុំក៏ស្រវារចាប់ក្រដាសនោះមកដាក់ក្នុងហោប៉ៅភ្លាម ព្រោះយល់ថាក្រដាសនោះគ្មានអ្វីក្រៅពីកំណាព្យ ដែលព្រលឹងនាយរោងពឹងឱ្យខ្ញុំជួយកែសំរួលនោះទេ ហើយក៏ដើរត្រឡប់ទៅរកអ្នកជំនួយការវិញ ដោយនិយាយយ៉ាងខ្លីថា «ទីតាំងថតត្រង់ណោះ មិនត្រូវទេ សំរាប់ឆាកថតស្អែក ចាំទៅរកកន្លែងផ្សេងទៀត !,,,»

✿ ✿ ✿

# ៦

# ចម្រៀងបីបទ

**ក្រោយ**ពេលត្រឡប់មកផ្ទះវិញ ប្រមាណជាម៉ោង១០យប់ ខ្ញុំចាប់ផ្តើមអានកំណាព្យអាថ៌កំបាំងទាំងបីសន្លឹកនោះ ដោយពិនិត្យពិច័យនិងស្ងប់ស្ងាត់បំផុត ។

ខ្ញុំមានអារម្មណ៍រំភើបញាប់ញ័រ និងកោតស្ញប់ស្ញែងជាខ្លាំងចំពោះខ្លឹមសារអត្ថន័យនិងរបៀបចងចុងជួនរបស់កំណាព្យទាំងបីនោះ ហើយខ្ញុំគិតថានឹងមិនបាច់កែសំរួលអ្វីទាំងអស់ ព្រោះវាល្អលើសពីអ្វីដែលខ្ញុំគិតស្មានទៅទៀតហើយនោះ ។

ដោយរំភើបពេក ពេលនោះ ខ្ញុំចង់តែនិយាយប្រាប់គេឯងថា ខ្ញុំបានជួបអត្ថបទកំណាព្យដែលមិនមែនសរសេរដោយដៃមនុស្ស ពិសេសគឺកំណាព្យរបស់នាងពិសិដ្ឋពាលីកា ដែលទើបស្លាប់នេះ ។ ប៉ុន្តែដោយខ្លាចភ្ញាក់ផ្អើលវែងឆ្ងាយ ខ្ញុំក៏នៅស្ងៀមទេវិញ ហើយខំប្រឹងអានកំណាព្យនោះសាជាថ្មីទៀត ។

ស្រាប់តែ មានមេភ្លេងម្នាក់បានទៅជួបខ្ញុំ នៅក្នុងពេលនោះដែរ

ដោយសុំឱ្យខ្ញុំជួយសរសេរទំនុកច្រៀងមួយបទ និយាយពីជីវិតនាងពិសិដ្ឋពាលីកាដែលត្រូវគេសម្លាប់ ។ បទនេះ គេសុំឱ្យខ្ញុំតែងទំនុកឱ្យរួចស្រេចក្នុងយប់នេះ ដើម្បីស្អែកគេយកទៅឱ្យអ្នកចំរៀងហាត់ថតក្នុងស្ទូឌីយោឱ្យបាន ។ ហើយគេនឹងចាប់ចាក់ផ្សាយក្នុងវិទ្យុជារៀងរាល់ថ្ងៃ ដើម្បីជាការចូលរួមមរណទុក្ខ រហូតទៅដល់ថ្ងៃ ១៨កក្កដា១៩៩៩ ដែលជាថ្ងៃបូជាសពនាងពិសិដ្ឋពាលីកាតែម្តង ។

ពេលនោះ ខ្ញុំកាន់តែមានក្តីរំភើបខ្ទេឡើង ព្រោះអ្វីដែលមេភ្លេងមកទាក់ទង វាជួនស្ទួននឹងពេលដែលខ្ញុំកំពុងតែពិនិត្យកំណាព្យទំនុកច្រៀងនោះដែរ ទ្រាំមិនបាន ខ្ញុំក៏បង្ហើបប្រាប់មេភ្លេងនោះតិចៗថា ÷

-«...ល្អហើយ បើប្អូនចង់បានដូច្នេះ ព្រោះខ្ញុំទើបបានទទួលទំនុកច្រៀង ពីរ...បី... ពីជនម្នាក់យកមកឱ្យដែរ ទំនុកច្រៀងទាំងនេះមានអត្ថន័យល្អ អាចយកជាការបាន ប្អូនយកតែម្តងទៅ មិនចាំបាច់ខ្ញុំសរសេរទេ នាំយូរ !...»

ខ្ញុំមិនបានប្រាប់គេថា ទំនុកច្រៀងទាំងនោះ ជារបស់ព្រលឹងនាងពិសិដ្ឋពាលីកាឱ្យនោះទេ ព្រោះខ្លាចគេមិនជឿ តែក៏នៅតែធ្វើឱ្យមេភ្លេងរាងប្រែប្រួលទឹកមុខ ហាក់ដូចមិនយកចិត្តទុកដាក់ចង់ដឹងពីរឿងទំនុកច្រៀងទាំងបីដែលខ្ញុំនិយាយនោះឡើយ គេបន្ទឹភ្នាមថា ÷

-«...តែគណៈកម្មការរៀបចំពិធីបុណ្យសពនោះ គេចង់បានស្នាដៃលោកអ៊ីផ្ទាល់ មិនចង់បានរបស់អ្នកដទៃណាទេ ព្រោះបទនេះគោងតែមានការទទួលខុសត្រូវដែរ...! សូមលោកអ៊ីជួយផង ឱ្យបានឆាប់ !... ព្រឹកស្អែកខ្ញុំមក...យក !...»

និយាយហើយ មេភ្លេងក៏លាខ្ញុំត្រឡប់ទៅវិញភ្លាម ធ្វើឱ្យខ្ញុំស្ទឹងស្មាធ មួយសន្ទុះ ដោយមិនដឹងគិតយ៉ាងណា ។

បើនឹងយកទំនុកច្រៀងទាំងបីទៅឱ្យគេ គេក៏មិនយក ព្រោះគេត្រូវ ការតែមួយ ហើយបើនឹងដកស្រង់ខ្លឹមសារល្អៗពីបទទាំងបីនោះមកធ្វើតែ មួយបទ ក៏ដូចជាមិនសម ព្រោះតាំងពីដើមមក ខ្ញុំមិនទម្លាប់យកបញ្ញា ញាណរបស់អ្នកដទៃ មកធ្វើជារបស់ឯងឡើយ ។ ម៉្យាង ខ្ញុំចង់ទុកស្នា ដៃរបស់ព្រលឹងម្ចាស់ស្រីនៃជម្រុំវប្បធម៌បូរាណទាំងបីនោះ ឱ្យនៅជាទី សក្ការៈដាច់ដោយឡែក ទើបខ្ញុំសំរេចចិត្ត អង្គុយសញ្ជឹងគិត និពន្ធទំនុក ច្រៀងថ្មីមួយបទភ្លាមឡើង សំរាប់ឧទ្ទិសដល់វិញ្ញាណខ័ន្ធរបស់នាងពិសិដ្ឋ ពាលីកា ដែលមានន័យជាអាទិ៍ថា ÷

## តើខ្ញុំខុសអ្វី ?

INTRO : (និយាយខ្សឹកខ្សួល)

-តើខ្ញុំខុសអី បានជាគេបាញ់ប្រហារខ្ញុំ យ៉ាងនេះ ?

✶ ម្ដាយឈឺចាប់ណាស់ណាំកូនសម្លាញ់
មិនគួរគេតាមមកបាញ់ ឱ្យម៉ែចុះចាញ់គ្រប់យ៉ាងជាតិនេះ
ចាំកូននៅឆ្ងាយ ទ្រូងម្ដាយចុកណែនស្ទើរប្រេះ
ឃាតករគេពិតជាឈ្នះ តើឈ្នះនេះ បានអ្វីថែមទៀត ? ។

✶ ម្ដាយគ្រាន់ជាស្រីរបាំធម្មតា
នាមពិសិដ្ឋពាលីកា បូជាជីវាជូនវប្បធម៌ជាតិ
ខំសាងក្ដីល្អ តែឃាតករចិត្តខ្មៅចង្អៀត

គួរខ្មាស់គួរអៀនធម្មជាតិ មកពិឃាតស្រីទាំងយង់ឃ្នង ។

R. តើខ្ញុំខុសអ្វី ?

សូមខ្មែរប្រុសស្រី ជួយគិតខ្ញុំផង

តើខ្ញុំខុសអ្វី បានជាគេប៉ង ?

ឃាតករមានខ្នង សាហាវជាងខ្លាដំរី ។

★ ផ្តាច់ជីវិតម្តាយឆ្ងាយពីស្ងួនភ្ងា

កូនក្លាយជាក្មេងកំព្រា រងទុក្ខវេទនាកណ្តាលលោកិយ៍

ព្រហ្មលិខិតអើយ ម្តេចឡើយទុរយសអប្រិយ៍

តើពួកឃាតករចង្រៃ មានវិប្បដិសារីដែរឬយ៉ាងណា ? ។

R. តើខ្ញុំខុសអ្វី ?

សូមខ្មែរប្រុសស្រី ជួយពិចារណា

តើខ្ញុំខុសអ្វី គេតាមប្រហារ

ឱ្យខ្ញុំមរណា ខ្មោចផ្សាចុកចាប់ពេកក្រៃ ។

★ លាស្នូរតន្ត្រីធ្លាប់លើកដៃរាំ

លាហើយសាលារបាំ ដែលធ្លាប់ណែនាំដល់សិស្សប្រុសស្រី

ពេលនេះឃាតករ ត្រេកអរព្រោះបានជោគជ័យ

ខ្ញុំស្លាប់ចោលកូននិងប្តី ស្លាប់ក្នុងន័យអយុត្តិធម៌ ។

<u>CODA បញ្ចប់</u> : (ឱ្យកខ្សួល)

-សូមបង ជួយថែរក្សាកូនយើង,,,ផង !

អូនសូមលាហើយ លាគ្មានថ្ងៃវិលត្រឡប់មកវិញទេ ! »

...ខ្ញុំសរសេរទំនុកច្រៀងនេះចប់ នៅប្រមាណម៉ោងជិត២អាធ្រាត។ ប៉ុន្តែ ទោះបីខ្ញុំខំប្រឹងសរសេរយ៉ាងណា ក៏ខ្ញុំគិតថានៅមិនដល់ទំនុកច្រៀងដែលសរសេរដោយម្ចាស់ជម្រុំវប្បធម៌បូរាណទាំងបីនោះឡើយ ។

ព្រឹកឡើង មេភ្លេងមកទទួលយកចំរៀងនោះតាំងពីព្រលឹម ហើយគេសំដែងទឹកមុខរីករាយពេញចិត្តជាខ្លាំង ក្រោយពីពេលបានអានត្រួសៗមួយចប់ ។ មេភ្លេងបានបញ្ជាក់បន្ថែមទៀតថា «គេនឹងឱ្យអ្នកចំរៀងស្រីដែលល្បីៗបំផុតច្រៀង ហើយការងារថតប្រហែលជារួចរាល់នៅវេលារសៀល នឹងបានចាក់ផ្សាយតាមវិទ្យុ នៅយប់នេះឯង !...»។

ព្រឹកនោះ ខ្ញុំក៏មិននៅទំនេរដែរ គឺត្រូវទៅបន្តដឹកនាំថតវីដេអូនៅភ្នំបាសិដ្ឋមួយថ្ងៃទៀត តាមផែនការដែលប្រធានផលិតកម្មបានគ្រោងទុក ។

នៅពេលទៅដល់ ខ្ញុំក៏ឆ្លៀតឱកាស ពេលដែលតួសំដែងកំពុងផាត់មុខផាត់មាត់ តុបតែងខ្លួន គឺបានឌុឺម៉ូតូបុរសម្នាក់ជិះសំដៅទៅកាន់កន្លែងដែលខ្ញុំបានជួបនឹងព្រលឹងពាលីកាជាបន្ទាន់ ។

ខ្ញុំបានយកកំណាព្យទាំងបីសន្លឹកនោះ ទៅដាក់នៅលើថ្ម និងបានដាក់ផ្កាកុលាបស្រស់សង្កត់ពីលើ ជាសញ្ញាថាកំណាព្យទាំងអស់ខ្ញុំបានពិនិត្យរួចរាល់អស់ហើយ ។គ្រាន់តែខ្ញុំដកដៃមកវិញស្ទើរមិនទាន់ កំណាព្យទាំងបីសន្លឹកនិងផ្កាកុលាបស្រស់បំព្រង ក៏ស្រូបរលាយបាត់ចូលទៅក្នុងថ្មភ្លាម ។

ខ្ញុំក៏ត្រឡប់ក្រោយជាបន្ទាន់ដែរ ព្រោះកន្លែងនោះស្ងាត់ជ្រៀបគួរឱ្យខ្លាច ក្រោយពីបានឮសម្លេងស្រីម្នាក់ខ្សិបៗនៅក្បែរត្រចៀក ប្រហាក់

ប្រហែលនឹងខ្យល់បក់ថា ÷

-«ខ្ញុំទើបដឹងថា លោកអ៊ំនឹងឈប់វិលមកថតនៅកន្លែងនេះទៀតហើយ ដូច្នេះ ពេលខ្ញុំយកចំរៀងទាំងបីបទនេះ ទៅថតជាស៊ីឌីហើយ ខ្ញុំនឹងយកទៅប្រគល់ឱ្យលោកអ៊ំ នៅថ្ងៃបូជាសពខ្ញុំតែម្តង !..»

ទោះខ្ញុំមិនបានឃើញស្រមោលព្រលឹងនាងពាលីកា ខ្ញុំក៏អាចស្គាល់ច្បាស់ថា សម្លេងនេះគឺពិតជាសម្លេងរបស់នាងហើយ តែខ្ញុំមិនបានដេញដោលអ្វីនាំឱ្យយូរការ ក្រៅតែពីជិះម៉ូតូត្រឡប់ទៅកាន់កន្លែងថតវិញនោះឡើយ ។

លុះវិលមកផ្ទះវិញពេលព្រលប់ ខ្ញុំក៏បានឮគេចាក់ចំរៀងដែលខ្ញុំតែងតាមវិទ្យុ ដូចពាក្យមេភ្លេងសន្យាមែន ។

...យប់នេះ ខ្ញុំមិនបានយល់សប្តិឃើញអ្វីទេ ហើយស្អែកឡើងថ្ងៃ១៦ កក្កដាឆ្នាំ១៩៩៩ ខ្ញុំនិងប្រពន្ធកូន រួមទាំងកូនប្រសារ ដោយមានតារាសំដែងរឿងបក្សីចាំក្រុងខ្វះផង បាននាំគ្នាទៅសាលាខាងជើង ដើម្បីគោរពសពនាងពិសិដ្ឋពាលីកាជាផ្លូវការ លាយឡំជាមួយគណៈប្រតិភូដទៃទៀត និងប្រជាជនប្រុសស្រីក្មេងចាស់ ប្រជ្រៀតគ្នាចេញចូលយ៉ាងចង្អៀតណែនណាន់តាន់តាប់ ។

នៅក្នុងសាលាដែលតំកល់សព ធុំតែក្លិនផ្សែងធូបទៀនឈៀមស្មើរវិលមុខ ។ ត្ងួរ៉ោននិងបាច់ផ្កាច្រើនរយពាន់ បានដាក់បញ្ឈរតំរៀបគរនៅល្វែងម្ខាង គេឃើញតែស្រមោលមនុស្សចេញចូលម្តងមួយក្រុមៗ ដើរឆ្វៃលមឈូសដែលធ្វើពីផ្កាឌឺស្រស់ពណ្ណរាយ ប្រកបដោយទឹកមុខស្រពាប់ស្រពោន ។ គ្រប់គ្នាតែងលំអោនកាយសម្រួមចិត្ត ស្ងឹងស្ងាធ

ទៅកាន់ស្រីម្នាក់ដែលដេកស្តូកស្តឹង ដាក់ដៃប្រណម្យលើដើមទ្រូង ប្រកបដោយទឹកមុខញញឹមស្ងួត ក្រោមរស្មីកែវភ្នែកហាក់ដូចជាបិទមិនជិត ។

គេបានស្លៀកពាក់ឱ្យនាងយ៉ាងស្រស់បំព្រង ឯវង្ងង់មុខក៏លាបក្រេមផ្ដាត់ម្សៅស្អាតល្អផូរផង់ ទំនងដូចនាងកំពុងដេកលក់ ។ ភ្នែងសក់ក៏គួចបួងកញ្ចុំដូចក្រមុំឈៀងម៉ែ អមដោយភួងមាឡែព័ទ្ធជុំវិញ ធ្វើឱ្យទំរង់មុខនាងកាន់តែផុះស្រស់ឡើង រង់ចាំស្វាគមន៍ចំពោះភ្ញៀវដែលចូលមកបន្តបន្ទាប់គ្នា ។

ក្រោមបរិយាកាសអ្វីៗអែរតែស្រងេះស្រងោច ដោយមានសម្លេងភ្លេងពិណពាទ្យកំដររង៉ុផងនោះ ធ្វើឱ្យរូបខ្ញុំដែលជាអ្នកធ្លាប់បានជួបប្រផ្នូលហេតុប្លែកៗទាំងនៅក្នុង និងនៅក្រៅសុបិនជាមួយនាងច្រើនដងផងនោះ កាន់តែមានអារម្មណ៍រន្ធត់ញាប់ញ័រជាងអ្នកដទៃ ។

ពេលនោះ ខ្ញុំស្ទើរតែមិនហ៊ានសំលឹងមុខសព ព្រោះមើលយូរទៅនាងដូចជាមិនមែនស្លាប់ ដើមទ្រូងនាងដូចជាមានដង្ហើមដក ហើយភ្នែកនាងដូចជាលួចបើកព្រិមៗសម្លឹងមករកខ្ញុំ ក្នុងគោលបំណងចង់និយាយប្រាប់ខ្ញុំនូវរឿងអាថ៌កំបាំងអ្វីខ្លះទៀត ។

ទ្រាំមិនបាន ក្រោយពីគោរពសពតាមប្រពៃណីរួចហើយ ខ្ញុំក៏ប្រញាប់ទាញដៃប្រពន្ធខ្ញុំរំកិលចេញទៅក្រៅវិញភ្លាម ហើយក៏ទៅជួបនឹងខែប្រសិទ្ធព្រមទាំងកូនប្រុស ដែលឈរចាំទទួលភ្ញៀវនៅក្បែរមាត់ទ្វារចូល ។

ឪពុកនិងកូននេះ ស្លៀកសំពត់ក្បិនស ពាក់អាវសដៃវែងបាំនដៃដោយចំរៀកកំណាត់ខ្មៅសញ្ញាមរណៈទុក្ខ ស្ទុះមកអោបខ្ញុំនិងប្រពន្ធខ្ញុំយំ

ដូចជាកូនក្មេង ហើយយើងពេលនោះពុំបាននិយាយអ្វីរកគ្នាឱ្យច្បាស់លាស់ឡើយ ក្រៅតែពីបង្ហូរភាសាទឹកភ្នែកយ៉ាងក្តៅគគុក ។

ដោយពេលនោះ អ្នកមកគោរពសព ចេះតែសំរុកមកច្រើនពេកម៉្លោះហើយ ក្រុមខ្ញុំចាំបាច់ត្រូវតែរំលៀកខ្លួនចេញទៅក្រៅសិន ដើម្បីឱ្យទូលាយកន្លែងបន្តិច ។ ប៉ុន្តែមុននឹងដើរចេញ ខ្ញុំបានប្រាប់ទៅខែប្រសិទ្ធទាំងអួលអាក់ថា «ថ្ងៃបូជាសព អ៊ំនឹងមកទៀត !..» ។

តាមពិត ខ្ញុំមិនចង់ឈានជើងចេញទៅក្រៅសោះ ព្រោះខ្ញុំដូចជាចង់និយាយអ្វីច្រើនជាមួយខែប្រសិទ្ធ ពិសេសរឿងដែលខ្ញុំបានជួបប្រទះហួរហែកទ្រូងមក តែរកឱកាសគ្មាន ។ ដោយពេលនោះ អ្នកកាសែតចេះតែចោមរោមគេច្រើនពេក ទើបខ្ញុំបង្ខំចិត្តជាចុងក្រោយដើរចេញទៅបន្ទាប់ពីបានក្រឡេកមើលទៅមឈូសដាក់សពនៅ[illegible]ងក្នុង ដែលពោរពេញដោយគំនរបាច់ផ្កា មើលមួយភ្លែតទៅមិនខុសអ្វីពី "ទេពធិតាក្នុងព្រៃនិទ្រា "នៃរឿងព្រេងនិទានគំនូរជីវចលន៍របស់ វ៉លឌីស្សនី នោះឡើយ ។

បើតាមសភាពអធិអធម៌ នៃប្រជាជនចេញចូលគ្រប់ម៉ោងគ្រប់នាទីមានចំនួនរាប់ម៉ឺនសែនរបៀបនេះ បានធ្វើឱ្យព្រឹត្តិការណ៍មរណភាពរបស់តារាប្រជាប្រិយ៍ពិសិដ្ឋពាលីកា ក្លាយទៅជាឆាកជីវិតដ៏មហារំជួលចិត្តមួយក្នុងប្រវត្តិសាស្ត្រសិល្បការិនីខ្មែរ ។

រហូតដល់ថ្ងៃទី ១៨ កក្កដា ១៩៩៩ ដែលជាថ្ងៃបូជាសព មានអ្នកខ្លះនិយាយថា ពិសិដ្ឋពាលីកាជានារីអភ័ព្វណាស់ ព្រោះត្រូវឃាតករយង់ឃ្នងបាញ់ប្រហារគ្មានត្រាប្រណី ព្រាត់ប្តីព្រាត់កូន ព្រាត់ទាំងសេច

ក្ដីស្រេកឃ្លានដែលចង់បានសច្ចៈ យុត្តិធម៌ ។ ប៉ុន្តែក៏មានអ្នកខ្លះ បាន កោតសរសើរស្ងប់ស្ងែង ថានាងជានារីដែលមានបុណ្យព្រេងវាសនាខ្ពស់ ទៅវិញ ព្រោះតាំងពីថ្ងៃដែលនាងត្រូវគេបាញ់រហូតមកដល់ពេលបូជាសពនេះ ប្រជាជនគ្រប់ជាន់ថ្នាក់បានឱ្យកិត្តិយសសពនាងយ៉ាងខ្ពង់ខ្ពស់ឧត្តុង្គឧត្តមប្រពៃថ្លៃថ្លាណាស់ ហើយអ្វីទាំងអស់នេះ គឺបណ្ដាលមកតែពីសេចក្ដីឈឺចាប់សោកស្ដាយដ៏មហាធំធេងរកទីបំផុតគ្មានប៉ុណ្ណោះ ។

នៅក្នុងថ្ងៃបូជាសពដ៏មហោឡារឹក ដែលចូលរួមពីសិស្សនិស្សិតនៅសាលារបាំ ពីសិល្បករ-សិល្បការិនី និងពីប្រជាជនប្រុសស្រីគ្រប់ជាន់ថ្នាក់នោះ ខ្ញុំក៏បានទៅចូលរួមនឹងគេដែរ ប៉ុន្តែខ្ញុំហាក់ដូចជាមិនបានឮគេថ្លែងវិយោគកថា មានខ្លឹមសារស្រងេះស្រងោចយ៉ាងណា និងមិនបានដឹងថាអ្នកណាជាអធិបតីក្នុងការឱ្យភ្លើងបូជាសពនោះដែរ ព្រោះអារម្មណ៍ខ្ញុំរវល់តែអណ្ដែតត្រសែតគិតទៅដល់ រឿងចំរៀងបីបទ ដែលព្រលឹងនាងពិសិដ្ឋពាលិកា បានសន្យាថានឹងយកជាស៊ីឌីទៅឱ្យខ្ញុំនៅពេលនោះ ។

ខ្ញុំមិនដឹងថា តើព្រលឹងនាងយកមកឱ្យខ្ញុំតាមវិធីណានោះទេ ព្រោះពេលនោះ ខ្លួនប្រាណរបស់នាងដែលនៅក្នុងក្ដាមឈ្លូសកំពុងត្រូវព្រះអគ្គីត្របាក់លេបយកសម្រស់ដ៏ល្អស្រស់ពណ្ណរាយ រលេះរលួយរលាយក្លាយជាកាកសំណល់នៃធាតុទាំង៤ជាបណ្ដើរៗទៅហើយនោះ ហើយក៏គ្មានហេតុភេទអ្វីកើតឡើងគួរឱ្យភ្ញាក់ផ្អើល ក្រៅតែពីផ្សែងខ្មៅខ្វលខ្វាញ់ដែលហុយទ្រលោមទៅលើ ក្រោមសម្លេងសោកវិយោគនៃភ្លេងខ្លងខែកដ៏លន្លង់លន្លោចខ្លោចផ្សានោះឡើយ ។

ប៉ុន្តែ នៅមួយរយៈពេលដែលខ្ញុំអង្គុយគិតសន្និដ្ឋានថា សពតារាកំសត់ ប្រហែលឆេះសុះបានពាក់កណ្ដាលហើយនោះ ហាក់ដូចមានអ្វីបណ្ដាលចិត្តឱ្យខ្ញុំចង់ក្រោកពីកន្លែងអង្គុយ ដើរទៅឈរសំលឹងមើលរូបថតនាងមួយផ្ទាំង ដែលគេតាំងជាលំអនៅកណ្ដាលត្នូរ៉ោនផ្កាជាច្រើនសំរាប់ឱ្យអ្នកមកចូលរួមពិធីបុណ្យគោរព ។

នៅពេលនោះ ប្រហែលមានតែខ្ញុំម្នាក់ទេ ដែលមើលឃើញរូបថតនាងហាក់ដូចជាមានទឹកភ្នែកហូររហាមចេញមក ។ ខ្ញុំសែនរន្ធត់ចិត្តហើយចង់ហៅគេឯងឱ្យទៅមើលអព្ភូតហេតុដ៏ចម្លែកដូចខ្ញុំដែរ ប៉ុន្តែទោះបីជានាងយំ តែខ្សែទឹកមុខនៅក្នុងរូបថតនោះ បានបង្ហាញនូវសញ្ញាសំងាត់អ្វីមួយនៅចុងក្រសែភ្នែក ថានាងមិនចង់ឱ្យខ្ញុំប្រាប់អ្នកណាឡើយ។

ជួនជានៅពេលដែលអ្នកបច្ចេកទេសកាន់ប្រដាប់បំពងសំលេង បានផ្អាកឈប់ចាក់ភ្លេងខួងខែក ហើយរាវរកស៊ីឌីបទថ្មី ដែលខ្ញុំតែងនោះចាក់កំដរពិធីបន្ត ស្រាប់តែខ្ញុំឃើញតំណក់ទឹកភ្នែករបស់សព ស្រក់ចុះពីរូបថតទៅលើត្នូរ៉ោនផ្កាមួយ ដែលតាំងនៅពីក្រោម ។ ហើយយ៉ាងរហ័សស្ទើរមើលមិនទាន់ ត្នូរ៉ោនផ្ការាងមូលនោះ ក៏បំព្រួញរួញក្លាយជាស៊ីឌីភ្លេង និងបន្ទំហោះចូលទៅក្នុងដៃអ្នកបច្ចេកទេស ធ្វើឱ្យគេភ័ន្តច្រឡំថា នោះជាស៊ីឌីភ្លេងថ្មី ដែលគេទើបថតចេញពីកាសែ្សត **MASTER** ពិតហើយ ព្រោះស៊ីឌីចម្លងថ្មី ពុំទាន់មានរូបភាពឬសញ្ញាអ្វីជាសំគាល់ឡើយ ។

គ្រាន់តែស៊ីឌីនោះចាប់ដំណើរគាវភ្លាម បរិយាកាសភ្ញាក់ផ្អើលនៅក្នុងពិធីបូជាសពនាងពិសិដ្ឋពាលីកា ក៏ចាប់ផ្ដើមឡើងដែរ ដែលជា

ដំបូង គេបានឮសម្លេងនាងនិយាយដំអូញខ្ទ័រ នៅក្នុងប្រដាប់បំពងសម្លេង ដោយមានសូរសៀងទ្រសោ SOLO បន្ទរបទនគររាជបណ្ដើរតិចៗយ៉ាងពិរោះគ្រលួច គួចតាមផ្សែងហុយពីចាំផា ថា ÷

-«នេះជាបទចំរៀងថ្មីបីបទ ដែលម្ចាស់ជម្រុំវប្បធម៌បូរាណនៅប្រាសាទបន្ទាយស្រី នៅវិមានភ្នំស្រី និងនៅប្រាសាទនាងខ្មៅ បានរួមដៃគ្នាជួយតាក់តែងឱ្យព្រលឹងខ្ញុំច្រៀង ក្រោយដែលខ្ញុំបានស្លាប់ទៅនេះ ! បទទាំងនេះខ្ញុំច្រៀងឧទ្ទិសដល់បេះដូងដ៏ក្រៀមក្រំរបស់ប្ដីខ្ញុំ កូនខ្ញុំ និងចំពោះសិល្បករ-សិល្បការិនីខ្មែរទាំងអស់ គឺបទទី១ឈ្មោះថា "**លាហើយជាតិនេះ !** " បទទី២ឈ្មោះថា "**ពាលីភាមាសបទ** "ដែលខ្ញុំច្រៀងធ្វើជាសម្លេងប្ដីខ្ញុំ ប៉ុន្តែដោយមិនសូវដូច ព្រលឹងលោកឡោសារិទ្ធ ក៏បានមកជួយច្រៀងផ្ទាល់ ! ឯបទទី៣ឈ្មោះថា "**បណ្ដាំនាយរោង !** "។

ភ្លាមនោះ ស្រាប់តែមានសម្លេងរសិបរសាវពាសពេញអង្គពិធី ប៉ុន្តែចំរៀងទី១ ក៏ចាប់ផ្ដើមឡើងដែរ ÷

## លាហើយជាតិនេះ !

* ឱ ! កម្មឱ្យកើត ដូចកាលដាច់ខ្មើត កម្មពើតឈឺផ្សា
កម្មតាមពិឃាត ឱ្យឃ្លាតជីវ៉ា ឃ្លាតទាំងបុត្រា
ធ្លាប់ត្រកងបី ។

* កម្មកាយឆ្ងាយបង ឆ្ងាយពីទ្រូទល្ហង ឆ្លងដល់ភពថ្មី
អូនទ្រាំចាំបង ជ្រងចិត្តភក្ដី តែកម្មប្រល័យ
ឱ្យព្រាត់ប្ដីបាន ។

R. ឈរ៉ាព្រាត់គ្នា ពីវត្ថុតន្ទា គង់វិលវិញថ្កាន
អម្ពរភិរុណា ព្រាត់គង់ជួបបាន ឯយើងពីរប្រាណ
ព្រាត់គ្នារហូត ។

★ បើបងនឹកអូន សូមបងជួយកូន ធ្វើជាចង្កួត
ឱ្យមានរស្មី ដូចកែវមណីជោត្ស សូមលារហូត
លាហើយជាតិនេះ ! ។

គ្រាន់តែបទទី១ចប់ទៅពេលណា មានស្នូរជញ្ជក់មាត់កោតសរសើរ និងសម្លេងងឿងឆ្ងល់កើតឡើងព្រមគ្នា គឺគេឆ្ងល់ថា ហេតុម្តេចបានជានាងពិសិដ្ឋពាលីកាស្លាប់ទៅហើយ អាចត្រឡប់មកច្រៀងវិញបាន ? ។

ប៉ុន្តែ ទោះមានអ្នកឆ្ងល់បែបណាក៏ដោយ ក៏គ្មានអ្នកណាម្នាក់អាចឆ្លើយជំនួសខ្ញុំបានដែរ ដែលពេលនោះ ខ្ញុំខំសម្ងំស្ងៀមដើម្បីស្តាប់បទទី២បន្តទៀត ហើយម្តងនេះមិនមែនជាសំលេងរបស់នាងទេ គឺជាសម្លេងរបស់លោកឡោសារិទ្ធ ដែលបានស្លាប់ដោយគ្រោះថ្នាក់ចរាចរមកយូរហើយ ÷

## ពាលីកាមាសបង !

★ ទទួលទូរស័ព្ទប្រាប់ថាអូនក្ស័យ
បងរន្ធត់ក្រៃរកអ្វីប្រៀបគ្មាន
មកដល់ឃើញអូនសូន្យផុតវិញ្ញាណ
បងយំបោកប្រាណអោបមឈូសស្ងួនភ្ងា ។

★ ភ័ក្ត្រអូនញញឹមចាំបងទាំងស្ដាយ
ពេលនេះបងក្លាយជាប្ដីកំព្រា
វិប្បដិសារីជេរស្ដីគ្រប់គ្រា
កម្មគ្មានមេត្តា ភរិយាខ្ញុំឡើយ ។

R. ពាលីកាមាសបង នួនល្អងទោះឃ្លាត
សូមផ្សងគ្រប់ជាតិ ជួបតែត្រាណត្រើយ
កូនប្រុសយើងមួយ អូនកុំព្រួយឡើយ
ឮបងដង្ហោយប្រាប់ដល់អូនទេ ? ។

★ ស្ដាយណាស់មកមិនទាន់ដង្ហើមស្រី
ខានស្ដាប់សម្ដីធ្លាប់ច្រៀងបំពេ
ទឹកភ្នែកបងហូរជាស្ទឹងទន្លេ
ស្ដាយរូបមាសមេមិនគួរឃ្លាតឆ្ងាយ ។

<u>CODA បញ្ចប់</u> : ពាលីកាមាសបង !
យើងជួបគ្នានៅជាតិក្រោយទៀត !

...ពេលដែលចប់ចំរៀងនេះទៀត ខ្ញុំសំគាល់ឃើញថាអ្នកដែលមកចូលរួមក្នុងពិធីឈាបនកិច្ចសពនាងពាលីកាទាំងប៉ុន្មាន កាន់តែភ្ញាក់ផ្អើលច្រួលច្របល់ខ្លាំងឡើង ពិសេសគឺឆ្ងល់ថា ឡោសារិទ្ធ បានស្លាប់ទៅយូរហើយ ហេតុអ្វីមកច្រៀងបទថ្មីនេះបាន ? ឬមួយក៏មានអ្នកណាផ្សេងសម្លេងដូចគ្នា ? ។

នៅគ្រាដែលគ្រប់គ្នា កំពុងជជែកពិភាក្សាមិនដាច់ស្រេចនោះ បទទី៣ ក៏ចាប់ផ្ដើមបន្លឺឡើងទៀត ដែលពេលនោះ ជាសំនៀងរបស់នាងពិសិដ្ឋពាលីកាសុទ្ធ ÷

## បណ្ដាំនាយរោង

* ឱ សិល្បករខ្មែរទាំងឡាយអើយ
ខ្ញុំសូមលាហើយគ្មានថ្ងៃត្រឡប់
សូមជួយជ្រោងទង់វប្បធម៌ឱ្យជាប់
កុំដួលក្រឡាប់បាត់ព្រលឹងជាតិ ។

* ខ្ញុំជានាយរោងតួអង្គព្រះរាម
ត្រូវគេគំរាមតាមបាញ់ពិឃាត
ស្លាយមិនបាននៅបំរើខ្មែរទៀត
ស្ដាយវប្បធម៌ជាតិកំពុងខ្វោចផ្សា ។

R. ទោះជាតិខ្មែរខ្សត់ទុរគតក៏ដោយ
ក៏សូមជាតិក្រោយកើតជាខេមរា

បេះដូងរីងមាំដូចអង្គអប្សរា
ការពារថ្មដាប្រាង្គប្រាអមតៈ ។
✶ វប្បធម៌ឡើងខ្ពស់ឈ្មោះជាតិក៏ល្បី
សូមខ្មែរប្រុសស្រីចងចាំឱ្យជាក់
ពេលវប្បធម៌ខ្សោយជាតិមុខជាធ្លាក់
គិតតែបាញ់ចាក់កាប់ដូចសព្វថ្ងៃ ! ។

...ពេលដែលចំរៀងបីបទនេះចប់ទៅពេលណា ខ្ញុំឃើញមនុស្សជាច្រើននាំគ្នារត់ព្រួស សំដៅទៅកាន់កន្លែងអ្នកបច្ចេកទេសចាក់ស៊ីឌី ហើយអ្នកដែលរត់លឿនមុនគេ គឺខៃប្រសិទ្ធមានទាំងកាន់ដៃកូនទៅជាមួយផង។ ឃើញដូច្នោះ ខ្ញុំក៏ដើរសំដៅទៅកាន់ទីនោះដែរ ព្រោះយល់ថា ច្បាស់ជាបញ្ហាស្មុគស្មាញនឹងកើតមានឡើង ។

ទៅដល់ស្ទើរមិនទាន់ ខៃប្រសិទ្ធបានសួរអ្នកកាន់ម៉ាស៊ីនស៊ីឌីថា ÷

-«ប្អូនបានស៊ីឌីភ្លេងចំរៀងហ្នឹងមកពីណា ?...»

ជននោះគ្រវីក្បាល ឆ្លើយដោយងឿងឆ្ងល់ ÷

-«ខ្ញុំមិនដឹងទេ !... អំបាញ់មិញខ្ញុំចាក់ស៊ីឌីបទថ្មី ដែលច្រៀងដោយស្រីណិចសោះ ស្រាប់តែបែរជាពួបទច្រៀងដោយសម្លេងពាលីកា និង ឡោសារិទ្ធ ទៅវិញ ?...»

-«ប្អូនឯងដកស៊ីឌី...នោះចេញមកមើល៍...»

អ្នកបច្ចេកទេស ចុចឧបករណ៍ចាក់ស៊ីឌី ឱ្យខ្ទុរស៊ីឌីចេញមកភ្លាម ប៉ុន្តែឃើញតែបន្ទះទ្រស៊ីឌីទទេស្អាត មិនឃើញស៊ីឌីនៅពីលើសោះឡើយ ធ្វើឱ្យអ្នករាល់គ្នា ឈរភាំងដោយស្រឡាំងកាំង ។

ទ្រាំមិនបាន ខ្ញុំក៏ដើរទៅឈរជិតខែប្រសិទ្ធ ហើយនិយាយតិចៗ ថា ÷

-«...យប់មិញ អ៊ំយល់សប្តិឃើញព្រលឹងពាលីកា មកប្រាប់ថា នៅថ្ងៃបូជាសពនាង នាងនឹងធ្វើឱ្យមានចំរៀងបីបទសំរាប់កំដរពិធីនេះ ហើយចំរៀងទាំងនេះ នាងទុកធ្វើជូនប្តីនាងនៅទីបំផុត !... អ៊ំមិនបាន និយាយប្រាប់អ្នកណា ព្រោះស្មានតែយល់សប្តិធម្មតា... ឥឡូវ...អ្វីៗ ដូចសំដីរបស់ព្រលឹងនាងមែន !...»

ខែប្រសិទ្ធ បែរមើលមុខខ្ញុំ ហើយពោលយ៉ាងស្រងូត ÷

-«...ខ្ញុំចង់បានចំរៀងនេះណាស់...! ស្រាប់តែមិនឃើញ ?..»

ខ្ញុំគិតបន្តិចទើបពោលបន្ត តែមិននិយាយវែងឆ្ងាយពីអព្ភូតហេតុផ្សេងៗកន្លងមកនោះទេ នាំតែឱ្យខែប្រសិទ្ធនឹកឆ្ងល់ថែមទៀត ថាហេតុម្តេចបានជានាងមិនទៅពន្យល់សប្តិគេ បែរជាមកពន្យល់សប្តិប្រាប់ខ្ញុំទៅវិញ ÷

-«...តាមអ៊ំយល់ថា ប្រហែលមិនទាន់ដល់ពេលនាងត្រូវប្រគល់ឱ្យណា៎ គឺនាងរង់ចាំជិតដល់ពេលដែលសិទ្ធឯងត្រូវត្រឡប់ទៅវិញទេដឹង ឬមួយក៏សិទ្ធឯងលែងត្រឡប់ទៅវិញហើយ ?...»

បុរសថ្កាល់ខ្ជួច ឆ្លើយមកវិញដោយទឹកមុខស្ងួត ÷

-«...ខ្ញុំលែងត្រឡប់ទៅវិញហើយចាំអ៊ំ !... ខ្ញុំនៅមើលកូនតាម

បណ្ដាំរបស់នាង !...»

ខ្ញុំដកដង្ហើមធំដោយព្រួយ កាលបើឮសំដីនេះ ជាហេតុធ្វើឱ្យខែប្រសិទ្ធ បន្ថែមមួយឃ្លាទៀតថា ៖

-«...ខ្ញុំនៅតែមិនអស់ចិត្ត ពីរឿងភ្លេងចំរៀងនេះសោះ នាងស្លាប់ហើយ បែរជាអាចច្រៀងផ្ញើសំនៀងតាមស៊ីឌីអាចឺកំចាំងមកកាន់ទីនេះបានទៀត ចម្លែកណាស់ !...»

-«មិនចម្លែក...ទេ !..» ព្រះសង្ឃវ័យចំណាស់មួយអង្គនិមន្តមកក្បែរនោះ ដោយមានអាចារ្យម្នាក់មកជាមួយផង មានពុទ្ធដិការឡើង «...ព្រះធម៌បានថ្លែងថា អ្នកដែលស្លាប់ដោយគេធ្វើឃាតតក្កលាហលដូចនាងពិសិដ្ឋពាលីកានេះ ព្រលឹងវិញ្ញាណរបស់នាងមិនទាន់រសាត់ទៅណាឆ្ងាយទេ គឺនៅអាលោះអាល័យដល់ញាតិមិត្ត និងក្រុមគ្រួសារទាំងអស់ ដូច្នេះសកម្មភាពឬរូបភាពអ្វី ដែលនាងធ្វើឱ្យញាតិញោមឃើញជាក់ស្ដែងទាំងប៉ុន្មាននៅពេលនេះ សុទ្ធសឹងជានិម្មិតរូបនៃសេចក្ដីអាលោះអាល័យដ៏មិនចេះអស់មិនចេះហើយនោះឯង !..»

តាអាចារ្យបានបញ្ជាក់បន្ថែមទៀតថា ៖

-«...ម្យ៉ាងទៀត នាងពិសិដ្ឋពាលីកា សឹងជាមនុស្សមានកុសលធម៌ច្រើន ទើបអ្វីដែលនាងសំដែងចេញមក សុទ្ធតែគាប់ភ្នែក គាប់ត្រចៀកអ្នកឃើញ អ្នកស្ដាប់ ដូចជាភ្លេងចំរៀងយ៉ាងនោះដែរ ឯអ្នកដែលសាងអំពើបាបច្រើនកាលនៅរស់ មិនអាចសំដែងអ្វីឱ្យគាប់ចិត្តបងប្អូនក្រុមគ្រួសារបានទេ គឺមានតែភាពភ័យខ្លាច ព្រឺស្ញើបជារៀងរហូត ដូចពាក្យគេហៅថាខ្មោចលងហ្នឹង !...»

ខែប្រសិទ្ធ កាលបើឮព្រះសង្ឃនិងតាអាចារ្យថ្លែងពីបុណ្យបាបតាមផ្លូវធម៌នេះ ក៏ហាក់ដូចជាមិនឮទឹកដល់ស៊ីឌីចំរៀងនោះទៀត ធ្វើឱ្យតាអាចារ្យបន្ទឺជាចុងក្រោយថា ÷

-«...អ៊ើ... កាត់ចិត្តកាត់ថ្លើមទៅ !.. បន្តិចទៀត សពឆេះសុះហើយ នាំគ្នាទៅរើសអដ្ឋិធាតុទុកដាក់តាមប្រពៃណីទៅ... ហើយព្រះសង្ឃនឹងទៅសូត្រព្រះធម៌ប្រៀបឱ្យនាង ដើម្បីឱ្យនាងដឹងកាន់តែច្បាស់ថា នាងស្លាប់ពិតប្រាកដហើយ ព្រោះកន្លងមកប៉ុន្មានថ្ងៃនេះ ព្រលឹងនាងប្រហែលមិនទាន់ដឹងជាក់លាក់ថាខ្លួនឯងស្លាប់នៅឡើយ បានជាវិញ្ញាណនាងចេះតែនៅវិលវល់ជាមួយអ្នកនៅរស់ដូច្នេះ...? »

ꕥ ꕥ ꕥ

**ប៉ុន្មាន**ថ្ងៃក្រោយ បន្ទាប់ពីពិធីឈាបនកិច្ចដ៏មហោឡារិកនោះមក ខ្ញុំក៏លែងបានជួបព្រលឹងនាងពិសិដ្ឋពាលីកានៅក្នុងសុបិនទៀតហើយ ។

ស្រាប់តែដល់ថ្ងៃ២៣កក្កដា ឆ្នាំ១៩៩៩ ខ្ញុំបានឃើញគេសម្ភាសន៍ខែប្រសិទ្ធដាក់ក្នុងទូរទស្សន៍មួយ តាមរយៈនាទី **OZONE** ។ ខ្ញុំសង្កេតឃើញថា ពេលនោះមានទស្សនិកជនជាច្រើនបានតាមដានចង់ស្តាប់បទសម្ភាសន៍នេះខ្លាំងណាស់ ព្រោះគេសង្ស័យក្រែងខែប្រសិទ្ធ បានដឹងអ្វីខ្លះពីមូលហេតុនៃឃាតកម្មលើរូបប្រពន្ធគេនោះ ? ។

ប៉ុន្តែ នៅពេលនោះ គេហាក់ដូចជាមិនបានឮខែប្រសិទ្ធនិយាយទាក់ទងដល់រឿងឃាតកម្មដ៏អាថ៌កំបាំងនោះឡើយ គឺឮតែគេនិយាយពីក្តីសោកស្តាយរបស់គេចំពោះនាងតែប៉ុណ្ណោះ ។ ហើយពិសេសជាង

នេះ បុរសអភ័ព្វស្នេហ៍ ក៏បាននិយាយពីព្រលឹងរបស់ពិសិដ្ឋពាលីកា ដោយហេតុតែទឹករលឹកគេពេក ក៏បានមកពន្យល់សប្តិគេ និងបានយកស៊ីឌីចំរៀងពិសិដ្ឋមកដាក់លើដៃគេដែលកំពុងដេក ដែលវត្ថុនោះ គេទុកដូចជាគ្រាប់ពេជ្រដ៏មានដម្លៃបំផុតសំរាប់ជីវិតរបស់គេទៀតផង ។

ទោះបីយ៉ាងណាក្តី ក៏ខ្ញុំហាក់ដូចជាបានធួរទ្រូងច្រើន ព្រោះព្រលឹងនាយរោងមិនបានបំភ្លេចបណ្តាំរបស់នាងឡើយ នាងធ្វើឱ្យប្តីនាងមានជំនឿច្រើន ថាទោះបីជានាងស្លាប់ទៅហើយក្តី ក៏នាងនៅតែស្មោះស្ម័គ្រចំពោះលើរូបគេជានិច្ច ។

ខ្ញុំគិតថា តែប៉ុណ្ណោះ ច្បាស់ជាខែប្រសិទ្ធមិនត្រឡប់ទៅនៅអូស្រ្តាលីវិញទេ ព្រោះព្រលឹងនាយរោងបានអនុគ្រោះចំពោះអ្វីដែលគេបានធ្វើកន្លងមកហើយ ។ ប៉ុន្តែ ជួនជានៅថ្ងៃទី២៨កក្កដាឆ្នាំ១៩៩៩ ខ្ញុំស្រាប់តែបានឮគេនិយាយស្ទើរគ្រប់មាត់ តាំងពីអ្នកធាក់ស៊ីក្លូ ម៉ូតូឌុបជាដើមទៅថា ខែប្រសិទ្ធមានជនមិនស្គាល់មុខលបបាញ់ត្រូវស្មាមួយគ្រាប់ ហើយដណ្តើមយកស៊ីឌីចម្រៀងពិសិដ្ឋនោះទៅបាត់ ។

ដំណឹងនេះ នាំក្តីតក់ស្លុតរន្ធត់មកឱ្យខ្ញុំសាជាថ្មី ធ្វើឱ្យខ្ញុំមមៃគិតថា បុរសពោះម៉ាយដ៏អភ័ព្វនេះ បើមិនប្រញាប់គេចខ្លួនទេ មុខជាត្រូវប្រឈមមុខនឹងយថាហេតុអ្វីមួយទៀតជាមិនខាន ប៉ុន្តែគួរឱ្យអស្ចារ្យណាស់ នៅថ្ងៃ២៩ខែនិងឆ្នាំដដែល កាសែតជាច្រើនបានចុះផ្សាយថា ខែប្រសិទ្ធពុំបានត្រូវគេលបបាញ់ ដូចពាក្យចចាមអារាមមាត់ចាបមាត់ព្រាបនោះទេ មិនតែប៉ុណ្ណោះ បានទាំងចាកចេញពីមាតុភូមិខ្មែរឆ្ពោះទៅកាន់ប្រទេសអូស្រ្តាលី ដែលជាកំពង់ផែថ្មី នៃនាវាជីវិតរបស់គេទៀតផង ។

ការចាកចេញទាំងប្រញាប់ប្រញាល់ ដោយមិនអាចនៅរង់ចាំការបំពេញទំរង់បែបបទកូនឱ្យរួចរាល់ ដើម្បីយកទៅជាមួយនេះ ធ្វើឱ្យព្រលឹងនាយរោងមានក្តីកង្វល់ច្រើន ប៉ុន្តែនាងសង្ឃឹមថាក្នុងពេលដ៏ខ្លីខាងមុខនេះ កូននាងច្បាស់ជាបានទៅនៅជាមួយឪពុកគេជាមិនខាន ។

ប៉ុន្តែ មិនប៉ុន្មានថ្ងៃក្រោយមក ខ្ញុំក៏ឮថាប្អូនបង្កើតនាងពិសិដ្ឋពាលីកា ក៏បាននាំស្វាមីនិងកូន ចាកចេញពីមាតុភូមិទៅសុំសិទ្ធិជ្រកកោននៅប្រទេសទីបី គឺប្រទេសបារាំង តាមរយៈឧត្តមស្នងការជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិនៅទីក្រុងបាងកកដែរ ។

ចំណែករូបខ្ញុំ ទោះបីគ្មានពាក់ព័ន្ធអ្វីជាមួយព្រឹត្តិការណ៍ដ៏អាថ៌កំបាំងនេះ ក៏មួយឆ្នាំក្រោយមក គឺនៅថ្ងៃទី១សីហាឆ្នាំ២០០០ ក៏បាននាំគ្រួសារចាកចេញពីប្រទេសកម្ពុជា ទៅសុំសិទ្ធិជ្រកកោននៅប្រទេសថៃមួយរយៈដែរ បន្ទាប់ពីមានការគំរាមកំហែងដល់អាយុជីវិត ព្រោះតែការសរសេរប្រលោមលោកប៉ះពាល់ដល់មន្ត្រីដ៏ខ្លាំងម្នាក់នោះ ។

នៅពេលទៅដល់ប្រទេសថៃមុនដំបូង ខ្ញុំបាននាំប្រពន្ធកូនទៅស្រោចទឹកមន្តនៅវត្តមួយ ដែលព្រះគ្រូចៅអធិការជាខ្មែរសុទ្ធ តែបានបួសរៀននៅប្រទេសថៃជាង៥០ឆ្នាំមកហើយ ។

គ្រានោះ ខ្ញុំមានការចាប់អារម្មណ៍ជាខ្លាំង ឃើលោកគ្រូចៅអធិការបានកាន់រូបថតនាងពិសិដ្ឋពាលីកាពីរសន្លឹក ដែលដាក់ជាមួយគ្នា ក្នុងក្របកញ្ចក់តែមួយ គឺរូបមួយជារូបពាក់កណ្តាលខ្លួន ទំនងជាកាត់ចេញពីចំរៀកទស្សនាវដ្តីឬកាសែតណាមួយ ឯរូបមួយទៀត ជារូបនាងតែងគ្រឿងជានាយរោងតួអង្គព្រះរាម កំពុងកាច់ក្បាច់ទន្ទាំ រាំលើកធ្នូជ័យ

បាញ់ ។

ឃើញភ្លាម ខ្ញុំក៏ទូលសួរទៅលោកគ្រូចៅអធិការថា ÷

-«ម៉េចក៏លោកគ្រូឪ មានរូបនាងពិសិដ្ឋពាលិកា តារាប្រជាប្រិយ៍របស់ខ្មែរនេះ ?,,,»

លោកគ្រូចៅអធិការ ឆ្លើយមកវិញដោយញញឹមស្លួតថា ÷

-«អាត្មាបានមើលកាសែតនិងទស្សនាវដ្ដីថៃជាច្រើន គេផ្ដើលចុះផ្សាយពីឃាតកម្មបាញ់ប្រហារ លើរូបតារាដ៏ល្បីនៅស្រុកខ្មែរនេះ ហើយដោយអាត្មាមានឈាមជ័រជាខ្មែរដែរ ទើបកាត់រូបនាងទុក ដោយអាណិត,,,!! អ៊ឺ,,, តើគេរកឃើញអ្នកដែលបាញ់ប្រហារនាងហើយនៅ ?,,,»

ខ្ញុំតបវិញ ដោយអស់សង្ឃឹម ÷

-«,,,នៅទេលោកឪ ហើយប្រាកដ,,,ជា,,រកមិនឃើញ ?,,,»

លោកគ្រូចៅអធិការ ថ្ងូរមួយឃ្លាទៀតថា ÷

-«ឱស្រុកខ្មែរអើយ ម៉េចក៏នៅតែរំលោភឈ្លានពាន កាប់សម្លាប់បាញ់ប្រហារ,,,គ្នាទៀតនោះ ?! លាក់បាំងអី ឱ្យតែដល់ថ្ងៃសីលដូចជាថ្ងៃនេះដែរ,,, អាត្មាតែងតែយករូបថតនាងរបាំនេះ ដាក់លាយជាមួយរូបថតញាតិញោមខ្មែរដទៃទៀត ដែលស្លាប់ទៅក្នុងពេលសង្គ្រាម ដូចជាលោកស៊ិនស៊ីសាមុតជាដើម មកបង្សុកូលបញ្ជូនមគ្គផលកុសលផលបុណ្យឱ្យ ដើម្បីឱ្យនាងឆាប់បានទៅចាប់កំណើតកើតជាថ្មីទៀត ហើយកុំឱ្យជួបប្រទះនឹងបាបកម្មពៀរវេរាដូចជាជាតិនេះ !,,»

,,,**នៅ**ពេលដែលជិះកាណូតត្រឡប់មកលំនៅថានវិញ ខ្ញុំក៏ងោក

ងុយលង់លក់នៅលើកាណូតនោះមួយស្របក់ ដោយយល់សុបិនឃើញដូចជារូបនាងពិសិដ្ឋពាលីកា តែងខ្លួនជានាយរោងរាំបណ្តែតខ្លួនលើផ្ទៃទឹកទន្លេចៅប្រាយ៉ា ហើយស្រែកមកកាន់ខ្ញុំថា ÷

-«លោកអ៊ំ ព្រលឹងខ្ញុំបានទៅជួបប្តីនិងកូនខ្ញុំ ដែលនៅឯប្រទេសអូស្ត្រាលីនោះហើយ គេទាំងពីរបានសេចក្តីសុខណាស់ !... នេះខ្ញុំប្រញាប់ត្រឡប់ទៅស្រុកខ្មែរវិញ ព្រោះដល់កិរិតពេលដែលខ្ញុំត្រូវចាប់កំណើតជាថ្មីហើយ !...»

-«តើនាងទៅចាប់កំណើតនៅកន្លែងណា ?..»

-«មិនប្រាកដទេ ! ប៉ុន្តែ ខ្ញុំត្រូវតែចូលចាប់កំណើតក្នុងផ្ទៃអ្នកសិល្បៈ អ្នកវប្បធម៌ ព្រោះដើម្បីថ្ងៃក្រោយខ្ញុំមានឱកាសបានធ្វើការបំរើវប្បធម៌ខ្មែរតទៅទៀត !... សូមលោកអ៊ំកុំភ្លេច សរសេររឿងខ្ញុំទុកផង !....»

ខ្ញុំក៏ឆ្លើយទៅវិញជាចុងក្រោយថា ÷

-«មិនអីទេ អ៊ំនឹងសរសេរទុក !.. មិនមែនចង់រកខុសត្រូវឬវែកញែកពីរឿងឃាតករនៃឃាតកម្មនោះទេ អ៊ំគ្មានសមត្ថភាពយល់ពីរឿងនេះទេ ព្រោះជាភារកិច្ចរបស់អាជ្ញាធរប៉ូលិស តែអ៊ំចង់សរសេរទុកជាឯកសារ សំរាប់ប្រាប់អនុជនខ្មែរជាន់ក្រោយថា " *នៅនាកាលសម័យនៃ*

*ថ្ងៃខែឆ្នាំ...មួយនោះ មានសិល្បការិនីរបាំ និងជាតារាភាពយន្តវីដេអូដ៏ល្បីល្បាញម្នាក់ បានត្រូវគេបាញ់ប្រហារយ៉ាងព្រៃផ្សៃ និងដើម្បីដាស់ស្មារតីឱ្យសិល្បករដទៃទៀត... មានការប្រុងប្រយ័ត្ន កុំភ្លេចខ្លួនឱ្យសោះ !* » ។...

# ចប់

សរសេរចប់ នៅថ្ងៃទី ២៨ មិនា ឆ្នាំ ២០០៤

នៅក្រុងបាងកកប្រទេសថៃឡង់ដ៍

**គន្ធ ប៊ុនឈឿន**

## ស្នាដៃរបស់អ្នកនិពន្ធ គង្គ ប៊ុនឈឿន ចាប់ពីឆ្នាំ ១៩៩៥


| | | |
|---|---|---|
| **120.** | ផ្គរសត្យា ........................................ | 1995 |
| 121. | រន្ទះដាវពញាយ៉ាត ............................ | 1995 |
| 122. | រំដួលឯកភ្នំ ........................................ | 1995 |
| 123. | អំពិលអំពែក ...................................... | 1996 |
| 124. | ព្រាយក្លាមស្រងៃ .............................. | 1997 |
| 125. | បេះដូងក្រៅទ្រូង .............................. | 1998 |
| 126. | ប្រាសាទប្រក់ស្លឹក ............................ | 1998 |
| 127. | កេសរកូលបិសាច ............................ | 1999 |
| 128. | វាសនានាងម៉ារីណា ......................... | 2000 |
| 129. | រំដួលសុរិន្ទ ...................................... | 2000 |
| 130. | វិមានធិតាអាថីកំបាំង ....................... | 2000 |
| 131. | ដំណក់ឈាមលើភ្នំនាគរាជ ............. | 2001 |
| 132. | កំណាព្យស្នេហ៍មាស ......................... | 2001 |
| 133. | បណ្ដាំគីរី ........................................ | 2001 |
| 134. | ទន្លេចាំជាតិ .................................... | 2002 |
| 135. | បន្ទាយស្រីគ្រប់លក្ខណ៍ .................... | 2002 |
| 136. | តេជោមាស តេជោយ៉ត ................ | 2002 |
| 137. | អមរាវត្តី ........................................ | 2002 |

138. មេឃនិងដី .................................... 2002

139. ឥន្ទ្រីខ្មៅលើភ្នៅកាមទេព ............... 2002

140. ព្រះរាជសម្ភារ ............................... 2002

141. រៃមាសទួលស្វែង .......................... 2002

142. ម្ចាស់ក្បួនអប្រិយ៍ ......................... 2003

143. ជម្ងឺខ្មែរ ....................................... 2003

144. ត្រពាំងត្រាំវិញ្ញាណ ....................... 2003

145. មេឃាចៅជ្រោយ៉ាតារាចតុមុខ .......... 2004


## កំពូលចោះពុម្ព


**146.** ពេលដែលថ្ងៃភ្លេចរះ

147. ទឹកភ្នែកឃាតករ

148. ស្ពឹងសម្ងាត់

149. មរណភាពនៃសង្សារខ្ញុំ

150. ទ្រខ្មែរឯនាយព្រំដែន

151. កម្ពុជាខ្វងខែត្

152. ទំនួញចាកក្ដាស្នេហ៍

153. គូស្នេហ៍អាឃាត

154. កាមទេពបង្ក្រាបអសុរកាយ

155. ៥០ និទានសំរាប់អប់រំកុមារ ភាគ១-ភាគ២

*សូមរង់ចាំអានរឿង*

**" ទុំទាវ "** *(ភាគក្រោយ)*

រៀបរៀងតាមលំនាំវណ្ណកម្មដើម របស់
ព្រះបទុមត្ថេរ ***សោម*** ដែលនឹងចេញ
ផ្សាយក្នុងពេលឆាប់ៗនេះ ។ ជាស្នា
ដៃរបស់លោក ***គង្គ ប៊ុនឈឿន***